# សរើតាគតិ

ទី២



## ខ្លឹមសារខ្មែរ

ប៊ុត សាវង្ស

# បារមី

បារមី គឺជាគុណធម៌ទាំងឡាយ មានទានជាដើម កំណត់ដឹងដោយបញ្ញានៃបុគ្គលអ្នកឆ្លាតក្នុងឧបាយ មានករុណាដ៏ធំក្រៃលែងជាគ្រឿងទ្រទ្រង់ ដែលតណ្ហាមានះ និងទិដ្ឋិមិនអាចកម្ចាត់បង់បាន ។

បារមី រមែងញុំាងសត្វទាំងឡាយឱ្យបរិសុទ្ធ ហ្មត់-ចត់ និងរមែងប្រកបសត្វទាំងឡាយទុកក្នុងព្រះនិព្វានដោយពិតប្រាកដ ។



# លំដាប់លំដោយនៃបារមី

⁎ សីលមានក្នុងលំដាប់នៃទានព្រោះ ÷

១-សីលធ្វើឱ្យមានភាពបរិសុទ្ធ ទាំងអ្នកឱ្យ ទាំងអ្នកទទួល បានសម្រេចជាទក្ខិណាវិសុទ្ធិដ៏ពិសេស ។

២-ពោលដល់ការអនុគ្រោះអ្នកដទៃដោយទាន ក៏ត្រូវតែពោលដល់ការមិនបៀតបៀនអ្នកដទៃផងដែរ ។ ជាការមិនសមគួរឡើយ កាលបើអនុគ្រោះហើយ បែរជាមានការបៀតបៀនទៅវិញនោះ ដូច្នោះ ឱ្យទានត្រូវតែមានសីល ទើបសមគួរដោយពិត ។

៣-ពោលដល់ធម៌ដែលគួរធ្វើហើយ ត្រូវពោលដល់ធម៌ដែលមិនគួរធ្វើផង ។ ទានជាធម៌គួរធ្វើ ឯការបៀតបៀន ការសម្លាប់លួចប្លន់ ប្រព្រឹត្តខុសក្នុងកូនប្រពន្ធអ្នកដទៃជាដើម ជាធម៌មិនគួរធ្វើ ទើបត្រូវពោលអំពីសីលក្នុងលំដាប់នៃទាន ។

៤.កាលបើពោលពីហេតុនៃភោគសម្បត្តិ គឺត្រូវពោលអំពីហេតុនៃភវសម្បត្តិផងដែរ ។ បុគ្គលបរិភោគនូវភោគសម្បត្តិដែលជាផលរបស់ទាន ត្រូវបរិភោគក្នុងសុគតិភព ដែលសុគតិភពជាភវសម្បត្តិនេះ សម្រេចបានដោយប្រពៃព្រោះអំណាចកម្លាំងរបស់សីល ។

* នេក្ខម្មៈ មានក្នុងលំដាប់នៃសីលព្រោះ ÷

១.ការសម្រេចនូវសីលសម្បត្តិដោយនេក្ខម្មៈ ពោលគឺនេក្ខម្មៈជាឧបការៈជួយឱ្យបានសម្រេចនូវសម្បត្តិសីល ។ ដូចជា នាគរាជព្រះបរមពោធិសត្វ រក្សាឧបោសថសីលនៅឋាននាគមិនបានស្រួល ទើបគេចចេញពីទីនោះ មករក្សាឧបោសថសីលនៅលើផែនដី បំពេញនេក្ខម្មបារមីជាឧបការៈ ជួយញ៉ាំងឱ្យសីលបារមីបានសម្រេចដោយល្អបែបនេះជាដើម ។

២.ពោលដល់កាយសុចរិត និងវចីសុចរិតរួចហើយ ទើបពោលដល់មនោសុចរិតតាមក្រោយជាលំដាប់ ។ នេក្ខម្មៈ គឺជាមនោកម្ម វៀរចាកកាមតាមផ្លូវចិត្ត រម្ងាប់



អកុសលនីវរណៈ មានកាមច្ឆន្ទៈ និងព្យាបាទជាដើម ។

៣.សីលបរិសុទ្ធរមែងឱ្យសម្រេចបាននូវឈាន ។ ឈាន គឺជានេក្ខម្មៈតាមផ្លូវចិត្ត ព្រោះឈានបានដុតនូវសេចក្តីត្រេកអរក្នុងកាមគុណទាំងឡាយ ។ ឈាន គឺជាចិត្តវិសុទ្ធិ ដែលអាស្រ័យឧបការៈអំពីសីលវិសុទ្ធិ ។

៤.ពោលដល់ការលះបង់នូវកិលេស ដែលគ្របសង្កត់ចិត្ត រួបរឹតចិត្ត តាមលំដាប់នៃការលះបង់កិលេសគ្រោតគ្រាតបានហើយ ។ សីលលះបង់នូវកិលេសគ្រោត-គ្រាត ឯនេក្ខម្មៈលះបង់នូវកិលេសដែលគ្របសង្កត់ចិត្ត និងរួបរឹតចិត្ត ។

* បញ្ញាមានក្នុងលំដាប់នៃនេក្ខម្មៈព្រោះ ÷

១.ការសម្រេច និងសេចក្តីបរិសុទ្ធនៃនេក្ខម្មៈដោយបញ្ញា ។ បញ្ញាមានការចូលដល់សេចក្តីពិត ពោលគឺដឹងច្បាស់នូវទោសរបស់កាមទាំងឡាយ ជួយឧបការៈដល់នេក្ខម្មៈឱ្យសម្រេចនូវភាពបរិសុទ្ធ ។

២.ពោលដល់បញ្ញាដែលមានសមាធិជាបទដ្ឋាន គឺ

ហេតុផិត និងពោលដល់សមាធិមានបញ្ញាជាបច្ចុប្បដ្ឋាន គឺផល ។

៣.ពោលដល់ការឆ្លាតក្នុងឧបាយនៃការបំពេញនូវប្រយោជន៍ផ្សេងៗ ដោយការតាំងចិត្តមាំក្នុងការធ្វើនូវប្រយោជន៍នោះៗ ។

*វីរិយៈមានក្នុងលំដាប់នៃបញ្ញាព្រោះ ÷

១.សេចក្ដីសម្រេចកិច្ចដោយបញ្ញា អាស្រ័យមកអំពីការប្រារព្ធនូវសេចក្ដីព្យាយាម ។

២.ពោលដល់ការពិចារណាមុនធ្វើ ហើយទើបពោលដល់ការព្យាយាម ព្រោះការព្យាយាមរបស់អ្នកដែលពិចារណាហើយទើបធ្វើ រមែងនាំមកនូវផលវិសេស ។

៣.ពោលដល់ការពិនិត្យ សម្លឹងមើលពួកសត្វដែលមានទុក្ខក្នុងវដ្តសង្សារ ហើយទើបពោលដល់ការប្រារព្ធនូវសេចក្ដីព្យាយាមដើម្បីប្រយោជន៍ដល់ពួកសត្វ ។

*ខន្តីមានក្នុងលំដាប់នៃវីរិយៈព្រោះ ÷

១.សេចក្ដីសម្រេចនៃការអត់ធន់ ដោយសេចក្ដី



ព្យាយាម ពោលគឺការព្យាយាមនាំឱ្យបានសម្រេចនូវខន្តីដោយការគ្របសង្កត់នូវទុក្ខលំបាក ។

២.សេចក្ដីព្យាយាម ជាអលង្ការនៃសេចក្ដីអត់ធន់ពិតណាស់ សេចក្ដីអត់ធន់របស់អ្នកដែលមានព្យាយាមរមែងប្រសើរស្រស់ស្អាត ។

៣.ពោលដល់ការលះឧទ្ធច្ចៈ និងទោសៈដោយសេចក្ដីព្យាយាម ។ ឧទ្ធច្ចៈ និងទោសៈលះបានដោយសេចក្ដីអត់ធន់ក្នុងការសម្លឹងមើលធម៌ ព្រោះថាខន្តីជាគុណជាតិស្ងប់ ពោលគឺស្ងប់នូវការរវើរវាយ និងការខឹងក្រោធជាដើមហ្នឹងឯង ប៉ុន្តែក៏ត្រូវអាស្រ័យការព្យាយាមដ៏ខ្លាំងក្លាក្នុងការសម្លឹងមើលធម៌ទើបសម្រេចបាននូវសេចក្ដីស្ងប់នេះ ។

៤.ពោលដល់ការធ្វើនូវសេចក្ដីព្យាយាម ជាប់តគ្នានៃអ្នកដែលមាននូវសេចក្ដីព្យាយាម បានសេចក្ដីថា អ្នកធ្ងន់ដោយខន្តីជាអ្នកមិនរវើរវាយ គឺជាអ្នកមានព្យាយាមជាប់តគ្នាហ្នឹងឯង បើខ្វះខន្តីហើយ មិនអាចជាអ្នកខ្លាំងក្លា

ដោយការព្យាយាមឡើយ ។

៥.ពោលដល់សេចក្តីអត់ធន់ចំពោះទុក្ខវេទនា ដែលទុក្ខវេទនានោះសម្រេចដោយសារអ្នកដទៃប្រហារ បៀត-បៀនដ៏សាហាវក្រៃលែង ក្នុងពេលដែលប្រារព្ធនូវសេចក្តីព្យាយាម ដើម្បីបានសម្រេចនូវប្រយោជន៍ដល់អ្នកដទៃ ។

⋆សច្ចៈមានក្នុងលំដាប់នៃខន្តីព្រោះ ÷

១.ខន្តីតាំងនៅបានយូរដោយសច្ចៈ គឺថា ព្រោះរក្សានូវសច្ចៈទើបបានជាឧបការៈដល់ការតាំងនៅនៃខន្តី។

២.ពោលដល់សេចក្តីអត់ធន់ ចំពោះសេចក្តីវិនាសអន្តរាយផ្សេងៗ សូម្បីដល់ថ្នាក់ត្រូវលះបង់ជីវិតដើម្បីរក្សាសច្ចៈ ពោលគឺអាចអត់ធន់ចំពោះអន្តរាយឬចំពោះឧបសគ្គបាន ទើបអាចរក្សាសច្ចៈទៅបាន ទោះជាត្រូវលះបង់នូវជីវិតក៏ដោយ ។

៣.ពោលដល់សេចក្តីអត់ធន់ក្នុងការសម្លឹងបរមត្ថ-ធម៌ ហើយពោលដល់ញាណសច្ចៈ គឺសច្ចៈដែលជាវិបស្សនា ក្នុងការទំនុកបម្រុងឱ្យកម្លាំងដល់ខន្តី គឺសេចក្តី



អត់ធន់នោះឯង ។

⋆អធិដ្ឋានមានក្នុងលំដាប់នៃសច្ចៈព្រោះ ÷

១.សេចក្តីសម្រេចនៃសច្ចៈដោយអធិដ្ឋាន គឺថាការសម្រេចបាននូវវិរតិសច្ចៈក្តី ញាណសច្ចៈក្តី និងវចីសច្ចៈក្តី ដោយការតាំងចិត្តមិនញាប់ញ័រ ។

២.ពោលដល់ការនិយាយពាក្យពិតដែលជាវចីសច្ចៈ ហើយ ក៏ពោលដល់ភាពនៃបុគ្គលមិនញាប់ញ័រនៅក្នុងការពោលពាក្យពិតនោះ ពិតណាស់ បុគ្គលដែលទុកចិត្តបានមិនញាប់ញ័រ ប្រព្រឹត្តសមគួរតាមពាក្យប្តេជ្ញា មានការសន្យាថានឹងឱ្យទានជាដើម ។

៣.ពោលដល់ញាណសច្ចៈ ដែលជាភាពពិតប្រាកដមួយ គឺបញ្ញា ហើយទើបពោលដល់ការប្រព្រឹត្តទៅនៃពោធិសម្ភារទាំងឡាយ ។ ពោធិសម្ភារ គឺការសន្សំបន្ទុំបុណ្យបារមី ដើម្បីឱ្យបានត្រាស់ដឹងជាព្រះសម្មាសម្ពុទ្ធ ពិតណាស់ បុគ្គលមានញាណតាមសេចក្តីពិត រមែងអធិដ្ឋាននូវពោធិសម្ភារទាំងឡាយនិងញ៉ាំងនូវពោធិសម្ភារ

ទាំងឡាយនោះឱ្យបានសម្រេច ព្រោះមិនញាប់ញ័រដោយបដិបក្ខទាំងឡាយ ។

⁎មេត្តាមានក្នុងលំដាប់នៃសច្ចៈព្រោះ ÷

១.សេចក្តីសម្រេចនៃអធិដ្ឋាន ដោយការសមាទាននូវអំពើជាប្រយោជន៍ដល់អ្នកដទៃដោយមេត្តា ។

២.ពោលដល់អធិដ្ឋានហើយ ទើបពោលដល់ការនាំនូវប្រយោជន៍ចូលទៅដល់អ្នកដទៃ ព្រោះថា អ្នកដែលតាំងមាំនៅក្នុងពោធិសម្ភារ គឺជាអ្នកមានប្រក្រតីនៅដោយមេត្តា ។

⁎ឧបេក្ខាមានក្នុងលំដាប់នៃមេត្តាព្រោះ ÷

១.សេចក្តីបរិសុទ្ធនៃមេត្តាដោយឧបេក្ខា ។ កាលដែលសត្វទាំងឡាយប្រព្រឹត្តទៅតាមបាបកម្ម ដែលខ្លួនបានធ្វើ រមែងមិនប្រព្រឹត្តទៅតាមមេត្តាដែលបំណងប្រាថ្នានូវប្រយោជន៍ឱ្យដល់សត្វលោកនោះៗឡើយ ដោយឧបេក្ខាបានកើតឡើង កាន់យកនូវការប្រព្រឹត្តទៅនៃសត្វលោកព្រោះកម្មហ្នឹងឯងជាអារម្មណ៍ ជំនួសទោមនស្សនោះ



ដែលធ្វើឱ្យមេត្តាបរិសុទ្ធ ព្រោះបានរួចផុតពីទោមនស្សជាសត្រូវ ។ បើមិនពិចារណាឱ្យឃើញច្បាស់ថា សត្វលោករមែងប្រព្រឹត្តទៅតាមកម្មទេ មេត្តារមែងជាបច្ច័យឱ្យកើតទោមនស្ស ដោយឧបនិស្សយប្បច្ច័យ នៅពេលបុគ្គលដែលខ្លួនមានមេត្តាជាមួយនោះ បានជួបនូវវិបត្តិអ្វីមួយ ។

ម្យ៉ាងទៀត រាគៈរមែងកើតឡើងធ្វើឱ្យមេត្តាសៅហ្មងទៅបាន កាលណាបើមិនពិចារណាអំពីការប្រព្រឹត្តទៅនៃសត្វលោកព្រោះកម្មទេនោះ ។

ដូច្នេះ ឧបេក្ខារមែងធ្វើឱ្យមេត្តាបានបរិសុទ្ធរួចផុតពីសត្រូវរបស់ខ្លួន (ទោមនស្ស និងរាគៈជាសត្រូវរបស់មេត្តាដោយពិត រមែងធ្វើឱ្យមេត្តាមានការសៅហ្មងជារឿយៗ) ។

២.ពោលដល់ការនាំនូវប្រយោជន៍ ឱ្យដល់សត្វទាំងឡាយ ហើយទើបពោលដល់ការមិនសម្លឹងចាប់ទោសកំហុសរបស់អ្នកដទៃនោះ ដោយសេចក្តីថា មេត្តាជាបច្ច័យនៃឧបេក្ខាក្នុងមហាកុសលចិត្ត ។

៣.ពោលដល់មេត្តាភាវនា ហើយពោលដល់សេចក្តីចម្រើនដែលជាផលរបស់មេត្តាភាវនានោះ ដោយសេចក្តីថា មេត្តាជាបច្ច័យនៃឧបេក្ខាក្នុងរូបាវចរកុសលចិត្ត ដោយឧបនិស្សយប្បច្ច័យ ។

៤.ពោលដល់សភាពនៃគុណ ដែលគួរអស្ចារ្យថា បុគ្គលអ្នកប្រងើយកន្តើយក្នុងសត្វដោយឧបេក្ខា គឺជាអ្នកដែលប្រាថ្នានូវប្រយោជន៍ឱ្យដល់សត្វហ្នឹងឯង ព្រោះថា បុគ្គលអ្នកមានបញ្ញា យល់អំពីដំណើរជីវិតនៃសត្វលោកតាមសេចក្តីពិតនោះ រមែងជាអ្នកសាងនូវប្រយោជន៍ឱ្យដល់មនុស្សសត្វទាំងឡាយជាទូទៅ ដោយមនុស្សសត្វទាំងនោះសុទ្ធតែជាញាតិក្នុងសង្សារវដ្ត លុះមនុស្សសត្វនោះមានវិបត្តិ ឬមានដំណើរជីវិតទៅតាមកម្មយ៉ាងណាៗ ឧបេក្ខាប្រកបដោយបញ្ញារមែងកើតឡើង ព្រោះអំពើល្អដែលជាប្រយោជន៍ បានធ្វើស្រេចហើយឱ្យដល់ជីវិតទាំងនោះ ។

មនុស្សយើងបានកើតមកហើយ មានការជួបមុខ



គ្នាយ៉ាងណាៗ គួរតែធ្វើនូវអំពើជាប្រយោជន៍ឱ្យដល់គ្នា ដែលអំពើជាប្រយោជន៍នោះ ប្រាសចាកនូវរាគៈដោយពិត ហើយគួរប្រព្រឹត្តនូវសុចរិតឱ្យជាប្រចាំ ដែលជាការបញ្ជាក់ថា មិនជាទាសៈរបស់លោកនេះ និងជាការឈ្នះ ព្រមទាំងរួចផុតស្រឡះអំពីលោកនេះផង ។

បុគ្គលអ្នកប្រាថ្នានូវប្រយោជន៍ គប្បីជ្រាបលំដាប់នៃបារមីទាំងឡាយនោះ ដោយប្រការដូច្នេះឯង ។

# លក្ខណាទិចតុក្កៈរបស់បារមី

## ទានបារមី

មានការបរិច្ចាគជាលក្ខណៈ មានការកម្ចាត់លោភៈក្នុងទេយ្យធម៌ជាកិច្ច មានភាពអង់អាចឬមានភាពសម្បូណ៌នៃភព និងការផុតចាកភពជាបច្ចុប្បដ្ឋាន និងមានសទ្ធាជ្រះថ្លាក្នុងការបរិច្ចាគនូវវត្ថុដែលគួរឱ្យជាបទដ្ឋាន ។

## សីលបារមី

មានការវៀរចាកដោយការសមាទាន និងមានការតាំងមាំ ដែលជាទីតាំងនៃកុសលធម៌ទាំងពួងជាលក្ខណៈ មានការកម្ចាត់បង់នូវភាពទ្រុស្តសីល ឬមានការមិនមាន



ទោសជាកិច្ច មានភាពស្អាតបរិសុទ្ធនៃការប្រព្រឹត្តដោយកាយវាចាជាបច្ចុប្បដ្ឋាននិងមានហិរិឱត្តប្បៈជាបទដ្ឋាន ។

## នេក្ខម្មបារមី

មានការចេញចាកកាមជាលក្ខណៈ មានការប្រកាសទោសនៃកាមនោះជាកិច្ច មានការបែរខ្នងដាក់កាមដែលប្រកបដោយទោសនោះជាបច្ចុប្បដ្ឋាន និងមានសេចក្តីសង្វេគជាបទដ្ឋាន ។

## បញ្ញាបារមី

មានការដឹងច្បាស់ ចាក់ធ្លុះនូវសភាវធម៌ជាលក្ខណៈ មានការធ្វើអារម្មណ៍ឱ្យភ្លឺស្វាងជាកិច្ច មានការមិនវង្វេងជាបច្ចុប្បដ្ឋាននិងមានសមាធិ ឬមានយោនិសោមនសិការជាបទដ្ឋាន ។

## វីរិយបារមី

≈≈≈≈≈≈≈≈≈≈

មានឧស្សាហៈជាលក្ខណៈ មានការឧបត្ថម្ភទំនុកបម្រុងនូវសហជាតធម៌ជាកិច្ច មានការមិនលិចចុះ មិនរួញថយជាបច្ចុប្បដ្ឋាន និងមានសេចក្ដីសង្វេគជាបទដ្ឋាន។

## ខន្តិបារមី

≈≈≈≈≈≈≈≈≈≈≈

មានសេចក្ដីអត់ធន់ជាលក្ខណៈ មានការអត់ទ្រាំចំពោះអារម្មណ៍ដែលគួរប្រាថ្នា និងមិនគួរប្រាថ្នាជាកិច្ច មានការអត់ទ្រាំបាន ឬមានការមិនក្រោធជាបច្ចុប្បដ្ឋាន និងមានការឃើញតាមសេចក្ដីពិតជាបទដ្ឋាន ។

## សច្ចបារមី

≈≈≈≈≈≈≈≈≈

មានការមិននិយាយខុសជាលក្ខណៈ មានការ



ប្រកាសតាមសេចក្ដីពិតជាកិច្ច មានការត្រជាក់ត្រជុំក្នុងចិត្តជាបច្ចុប្បដ្ឋាន និងមានការឃើញតាមសេចក្ដីពិតជាបទដ្ឋាន ។

## អធិដ្ឋានបារមី

≈≈≈≈≈≈≈≈≈≈

មានការតាំងចិត្តក្នុងពោធិសម្ភារ ( ការសន្សំបន្ទុំបារមីដើម្បីត្រាស់ដឹង )ជាលក្ខណៈ មានការគ្របសង្កត់នូវអ្វីដែលជាបដិបក្ខរបស់ពោធិសម្ភារជាកិច្ច មានការមិនញាប់ញ័រក្នុងការគ្របសង្កត់នូវបដិបក្ខនោះជាបច្ចុប្បដ្ឋាន និងមានពោធិសម្ភារជាបទដ្ឋាន ។

## មេត្តាបារមី

≈≈≈≈≈≈≈≈≈≈≈≈

មានការប្រព្រឹត្តទៅនៃអាការ ដែលជាប្រយោជន៍ដល់សត្វទាំងឡាយជាលក្ខណៈ មានការនាំប្រយោជន៍ចូល

ទៅ ឬមានការកម្ចាត់អាឃាតព្យាបាទជាកិច្ច មានការសុភាពជាបច្ចុប្បដ្ឋាន និងមានការឃើញសត្វទាំងឡាយជាទីគួរឱ្យមានមេត្តា (ព្រោះគ្រប់ជីវិតសុទ្ធតែប្រាថ្នាសេចក្តីសុខ មានចិត្តមានគំនិត ចេះភ័យខ្លាច ចេះស្រឡាញ់ខ្លួនឯង និងចេះស្រឡាញ់អ្នកដទៃ) ជាបទដ្ឋាន ។

## ឧបេក្ខាបារមី

≈≈≈≈≈≈≈≈≈≈≈≈≈

មានការប្រព្រឹត្តទៅជាកណ្តាលក្នុងសត្វទាំងឡាយជាលក្ខណៈ មានការមើលឃើញនូវភាពស្មើគ្នាក្នុងពពួកសត្វដែលប្រព្រឹត្តទៅតាមកម្មជាកិច្ច មានការស្ងប់នូវសេចក្តីចង្អៀតចង្អល់ជាបច្ចុប្បដ្ឋាន និងមានការពិចារណាឃើញថា សត្វមានកម្មជារបស់ខ្លួនជាបទដ្ឋាន ។



## បារមីទាំងអស់

≈≈≈≈≈≈≈≈≈≈≈≈≈

មានការអនុគ្រោះអ្នកដទៃជាលក្ខណៈ មានការធ្វើនូវឧបការៈដល់អ្នកដទៃជាកិច្ច ឬមានការមិនញាប់ញ័រជាកិច្ច មានការស្វែងរកនូវប្រយោជន៍ជាបច្ចុប្បដ្ឋាន ឬមានភាពជាព្រះសម្មាសម្ពុទ្ធជាបច្ចុប្បដ្ឋាន និងមានមហាករុណាជាបទដ្ឋាន ឬមានភាពជាអ្នកឆ្លាតក្នុងឧបាយនៃករុណាជាបទដ្ឋាន ។

# បច្ច័យនៃបារមីទាំងឡាយ

បច្ច័យនៃបារមីទាំងឡាយមាន ៧ គឺ :

**១-អភិនីហារ**

**២-បញ្ញា និងករុណា**

**៣-ឧស្សាហៈជាដើម**

**៤-អជ្ឈាស្រ័យ ៦ យ៉ាង**

**៥-អជ្ឈាស្រ័យក្នុងបារមី**

**៦-ពិចារណាទោសនិងអានិសង្ស**

**៧-ចរណធម៌ ១៥**

## ១-អភិនីហារ

អភិនីហារជាបច្ច័យនៃបារមីទាំងឡាយ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា អភិនីហាររមែងសម្រេចព្រោះធម្មសមោធាន ៨ ប្រការ គឺ ភាពជាមនុស្ស ១ លិង្គ-



សម្បត្តិ ១ ហេតុ ១ សត្ថារទស្សនំ ១ បព្វជ្ជា ១ គុណសម្បត្តិ ១ អធិការ ១ និង ឆន្ទតា ១ ។

**មនុស្សត្តំ លិង្គសម្បត្តិ ហេតុ សត្ថារទស្សនំ**
**បព្វជ្ជា គុណសម្បត្តិ អធិការោ ច ឆន្ទតា**
**អដ្ឋធម្មសមោធានា អភិនីហារោ សមិជ្ឈតិ ។**

ក្នុងបទទាំង ៨ នោះគឺ :

១-មនុស្សត្តំ បានដល់អត្តភាពរបស់មនុស្ស ព្រោះសេចក្តីប្រាថ្នារមែងសម្រេចដល់អ្នកដែលតាំងនៅក្នុងអត្ត-ភាពរបស់មនុស្សតែប៉ុណ្ណោះ ហើយដែលការប្រាថ្នានោះគឺប្រាថ្នាជាព្រះសម្មាសម្ពុទ្ធ ។ រមែងមិនសម្រេចដល់អ្នកដែលតាំងនៅក្នុងជាតិផ្សេងមាននាគ និងគ្រុឌជាដើមឡើយ ។ បើសួរថាព្រោះហេតុអ្វី ? គប្បីតបថា ព្រោះមនុស្សសមគួរដល់ភាពជាព្រះពុទ្ធ ។

២-លិង្គសម្បត្តិ សូម្បីតាំងនៅក្នុងអត្តភាពជាមនុស្សហើយ តែសេចក្តីប្រាថ្នារមែងសម្រេចបានចំពោះតែមនុស្សប្រុសប៉ុណ្ណោះ ។ រមែងមិនសម្រេចដល់ស្ត្រី

ឬខ្ទើយ ឬមនុស្សដែលមានភេទពីរឡើយ ។ បើសួរថា ព្រោះអ្វី ? គប្បីឆ្លើយថា ព្រោះភេទប្រុសសមគួរដល់ភាពជាព្រះពុទ្ធ និងព្រោះមានភាពបរិបូណ៌នៃលក្ខណៈ ។

៣.ហេតុ គឺដល់ព្រមដោយឧបនិស្ស័យ ពិតណាស់ សេចក្តីប្រាថ្នារមែងសម្រេច ដល់មនុស្សប្រុសដែលសម្បូណ៌ដោយឧបនិស្ស័យ បើមិនប្រាថ្នាជាព្រះពុទ្ធទេ អាចបានជាព្រះអរហន្តក្នុងជាតិនោះ ព្រោះហេតុសម្បត្តិ ។ ក្រៅអំពីនេះគឺមិនអាចសម្រេចបានឡើយ ។

៤.សត្ថារទស្សនំ គឺការដែលមានព្រះសាស្តានៅចំពោះមុខ ព្រោះសេចក្តីប្រាថ្នារមែងសម្រេចដល់បុគ្គលណា ដែលប្រាថ្នាក្នុងសំណាក់នៃព្រះសម្មាសម្ពុទ្ធទ្រង់គង់ព្រះជន្មនៅឡើយ ។ កាលបើព្រះដ៏មានព្រះភាគទ្រង់បរិនិព្វានហើយ សេចក្តីប្រាថ្នារមែងមិនសម្រេចក្នុងមុខព្រះចេតិយ គល់ព្រះពោធិព្រឹក្ស ទីព្រះបដិមា ឬទីសំណាក់នៃព្រះបច្ចេកពុទ្ធ និងព្រះសាវ័ករបស់ព្រះសម្មាសម្ពុទ្ធឡើយ ។ ព្រោះហេតុអ្វី ទើបមិនសម្រេច ? ព្រោះមិន



មានអធិការ គឺការពេញចិត្តដ៏មានកម្លាំងក្នុងការធ្វើដ៏ក្រៃលែង ។

៥.បព្វជ្ជា គឺសេចក្តីប្រាថ្នារមែងសម្រេច ដល់អ្នកប្រាថ្នាក្នុងសំណាក់របស់ព្រះដ៏មានព្រះភាគ ត្រូវតែជាអ្នកបួសជាតាបស ឬបួសក្នុងសំណាក់ភិក្ខុទាំងឡាយ និងជាអ្នកជឿកម្មនិងផលរបស់កម្ម ។ មិនសម្រេចដល់អ្នកដែលតាំងនៅក្នុងភេទជាគ្រហស្ថឡើយ ។ ព្រោះហេតុអ្វី? ព្រោះគ្រហស្ថមិនសមគួរជាព្រះសម្មាសម្ពុទ្ធ ។ មានតែបព្វជិតប៉ុណ្ណោះជាព្រះមហាពោធិសត្វ ហើយបានសម្រេចនូវព្រះសម្មាសម្ពោធិញ្ញាណ ព្រោះដូច្នោះ ក្នុងពេលតាំងប្រណិធានគួរជាភេទបព្វជិតតែប៉ុណ្ណោះ ជាការអធិដ្ឋានដោយគុណសម្បត្តិដ៏យ៉ាងពិតប្រាកដ ។

៦.គុណសម្បត្តិ គឺដល់ព្រមដោយគុណ មានអភិញ្ញាជាដើម ។ សេចក្តីប្រាថ្នារមែងសម្រេចដល់បព្វជិតដែលបានសមាបត្តិ ៨ និងអភិញ្ញា ៥ ។ រមែងមិនសម្រេចដល់អ្នកដែលប្រាសចាកនូវគុណសម្បត្តិទាំងនេះឡើយ ។

ព្រោះហេតុអ្វី ? ព្រោះអាចស្រាវជ្រាវរកបារមីឃើញបាន។ ព្រះមហាបុរសបំពេញអភិនីហារ ជាអ្នកអាចស្រាវជ្រាវរកឃើញនូវបារមីដោយខ្លួនឯង ជាអ្នកប្រកបដោយឧបនិស្សយសម្បត្តិ និងអភិញ្ញាសម្បត្តិ ។

៧.អធិការោ គឺមានឧបការៈដ៏ក្រៃលែង ។ ពិតណាស់ បុគ្គលណាដល់ព្រមដោយគុណសម្បត្តិតាមដែលបានពោលហើយ ទោះបីជីវិតរបស់ខ្លួនក៏ហ៊ានលះបង់បូជាចំពោះដល់ព្រះសម្មាសម្ពុទ្ធដែរ រមែងធ្វើនូវឧបការៈដ៏យ៉ាងក្រៃលែងក្នុងកាលនោះ ។ អភិនីហាររមែងសម្រេចដល់បុគ្គលនោះឯង រមែងមិនសម្រេចដល់បុគ្គលក្រៅអំពីនេះឡើយ ។

៨.ឆន្ទតា គឺពេញចិត្តក្នុងកុសល ដោយបំណងប្រាថ្នានឹងធ្វើ ។ សេចក្តីប្រាថ្នារមែងសម្រេចដល់អ្នកដែលប្រកបដោយធម៌តាមដែលបានពោលហើយ មានការពេញចិត្តខ្លាំង បំណងនឹងធ្វើដ៏ក្រៃលែងដើម្បីប្រយោជន៍ដល់ធម៌ដែលធ្វើឱ្យបានសម្រេចជាព្រះសម្មាសម្ពុទ្ធតែប៉ុណ្ណោះ។



អភិនីហារប្រកបដោយអង្គ ៨ នេះ គប្បីជ្រាបថាចិត្តុប្បាទដែលប្រព្រឹត្តទៅបានប្រជុំដោយអង្គ ៨ នេះឯង។ ចិត្តុប្បាទនោះ មានការតាំងចេតនាយ៉ាងមាំ ដើម្បីសម្មាសម្ពោធិញ្ញាណជាលក្ខណៈ មានសេចក្តីប្រាថ្នាមានជាអាទិ៍យ៉ាងនេះថា «ឱ! យើងគប្បីត្រាស់ដឹងជាព្រះសម្មាសម្ពុទ្ធ យើងគប្បីញុំាងប្រយោជន៍សុខឱ្យសម្រេចដល់សត្វ » ជាកិច្ច មានភាពជាហេតុនៃពោធិសម្ភារជាបច្ចុប្បដ្ឋាន និងមានមហាករុណាជាបទដ្ឋាន ឬមានឧបនិស្សយសម្បត្តិជាបទដ្ឋាន ។

ក្នុងអភិនីហារនោះ គប្បីជ្រាបបច្ច័យ ៤ ហេតុ ៤ និង ពលៈ ៤ ។

### បច្ច័យ ៤ នៃអភិនីហារ

១.ព្រះមហាបុរសក្នុងលោកនេះ រមែងឃើញព្រះតថាគតដែលកំពុងសម្តែងបាដិហារ្យដ៏អស្ចារ្យ ដោយពុទ្ធានុភាព ។ ចិត្តរបស់ព្រះមហាបុរសនោះ រមែងតាំងនៅក្នុងមហាពោធិញ្ញាណ ធ្វើបាដិហារ្យនោះឱ្យជា

អារម្មណ៍ ។ ព្រះមហាបុរសមានការនឹកដល់ព្រះតថាគតនោះថា ព្រះដ៏មានព្រះភាគជាម្ចាស់ មានធម៌គួរអស្ចារ្យមិនធ្លាប់មានមកពីមុន និងមានអានុភាពជាអចិន្តេយ្យយ៉ាងនេះ ព្រោះបានជាក់ច្បាស់នូវធម្មធាតុណា ធម្មធាតុនេះមានអានុភាពដ៏ក្រៃលែងហ្ន ។ ព្រះមហាបុរសបង្អោនទៅក្នុងសម្ពោធិញ្ញាណ ធ្វើធម្មធាតុនោះឱ្យជាបច្ច័យ ដោយអាស្រ័យការឃើញនូវមហានុភាពនោះឯង ហើយក៏បានតាំងចិត្តទុកក្នុងអភិនីហារនោះ ។ នេះជាបច្ច័យទី ១ នៃអភិនីហារ ។

២.ព្រះមហាបុរស មិនបានឃើញនូវអានុភាពដ៏ធំ-ធេងនៃព្រះតថាគត តាមដែលបានពោលហើយ ប៉ុន្តែបានស្តាប់ថា ព្រះដ៏មានព្រះភាគជាម្ចាស់អង្គនោះ ដូចនេះនិងប្រព្រឹត្តទៅយ៉ាងនេះ ។ ព្រះមហាបុរសនោះ បង្អោនទៅក្នុងសម្ពោធិញ្ញាណ ធ្វើធម្មធាតុនោះឱ្យជាបច្ច័យ អាស្រ័យព្រះដ៏មានព្រះភាគ ក៏រមែងតាំងចិត្តទុកក្នុងអភិនីហារនោះ ។ នេះជាបច្ច័យទី ២ នៃអភិនីហារ ។



៣.ព្រះមហាបុរស មិនបានឃើញនូវអានុភាពដ៏ធំ-ធេងនៃព្រះតថាគត ទាំងមិនបានស្តាប់មហានុភាពនោះអំពីអ្នកដទៃឡើយ តែកាលព្រះតថាគតទ្រង់សម្តែងព្រះធម៌ព្រះមហាបុរសរមែងស្តាប់ធម៌ ដែលព្រះធម៌ប្រព្រឹត្តទៅដោយពុទ្ធានុភាព មានន័យជាអាទិ៍ថា « ម្នាលភិក្ខុទាំងឡាយ តថាគតប្រកបដោយកម្លាំង ១០ » ។ ព្រះមហាបុរសនោះបង្អោនក្នុងសម្ពោធិញ្ញាណ ធ្វើធម្មធាតុនោះឱ្យជាបច្ច័យ អាស្រ័យពុទ្ធានុភាព រមែងតាំងចិត្តទុកក្នុងអភិនីហារនោះ ។ នេះជាបច្ច័យទី ៣ នៃអភិនីហារ ។

៤.ព្រះមហាបុរស មិនបានឃើញនូវអានុភាពដ៏ធំ-ធេងនៃតថាគត ទាំងមិនបានស្តាប់មហានុភាពនោះអំពីអ្នកដទៃ ហើយក៏មិនបានស្តាប់ព្រះធម៌របស់ព្រះតថាគតដែរ តែជាអ្នកមានអធ្យាស្រ័យទូលំទូលាយ មានការតាំងចិត្តដោយប្រពៃថា យើងនឹងរក្សាវង្សរបស់ព្រះពុទ្ធ បែបផែនរបស់ព្រះពុទ្ធ ប្រពៃណីរបស់ព្រះពុទ្ធ ភាវៈជាធម៌របស់ព្រះពុទ្ធ ហើយសក្ការៈ គោរពរាប់អាន បូជាធម៌តែ

ប៉ុណ្ណោះ ។ ព្រះមហាបុរសប្រព្រឹត្តធម៌បង្អោនទៅក្នុងសម្ពោធិញ្ញាណ ធ្វើធម្មធាតុនោះឱ្យជាបច្ច័យ អាស្រ័យធម៌រមែងតាំងចិត្តទុកក្នុងអភិនីហារនោះ ។ នេះជាបច្ច័យទី ៤ នៃអភិនីហារ ។

### ហេតុ ៤ នៃអភិនីហារ

១.ព្រះមហាបុរសក្នុងលោកនេះ តាមប្រក្រតីជាអ្នកសម្បូណ៌ដោយឧបនិស្ស័យ សាងសន្សំអធិការក្នុងព្រះពុទ្ធទាំងឡាយអំពីមុនៗ ។ នេះជាហេតុទី ១ នៃអភិនីហារ ។

២.ព្រះមហាបុរសតាមប្រក្រតី ជាអ្នកមាននូវអធ្យាស្រ័យករុណា បង្អោនទៅក្នុងករុណា បំណងនឹងនាំទុក្ខរបស់សត្វទាំងឡាយឱ្យចេញចេញឆ្ងាយអស់ទៅ ដោយព្រះមហាបុរសសុខចិត្តព្រមលះបង់កាយ និងជីវិតរបស់ខ្លួន ។ នេះជាហេតុទី ២ នៃអភិនីហារ ។

៣.ព្រះមហាបុរសប្រឹងប្រែងព្យាយាម ដោយមិនធុញទ្រាន់នឿយណាយពីការប្រព្រឹត្តកិច្ច ដែលធ្វើបាន



ដោយលំបាកក្នុងវដ្តទុក្ខអស់កាលជាអង្វែងក្រៃលែង ដើម្បីជាប្រយោជន៍ដល់សត្វ មិនតក់ស្លុតចំពោះទុក្ខលំបាកក្នុងសង្សារវដ្ត ព្រោះហេតុតែពេញចិត្តខ្លាំងចំពោះសព្វញ្ញុតញ្ញាណ រហូតដល់បានសម្រេចនូវប្រយោជន៍តាមដូចដែលប្រាថ្នា ។ នេះជាហេតុទី ៣ នៃអភិនីហារ ។

៤.ព្រះមហាបុរស ជាអ្នកអាស្រ័យនូវកល្យាណមិត្ត ដែលកល្យាណមិត្តនោះ ជាអ្នកហាមឃាត់អំពើមិនជាប្រយោជន៍ ដឹកនាំឱ្យតាំងនៅក្នុងអំពើជាប្រយោជន៍ ។ នេះជាហេតុទី ៤ នៃអភិនីហារ ។

គប្បីជ្រាបឧបនិស្សយសម្បទារបស់ព្រះមហាបុរស ដែលជាហេតុនៃអភិនីហារទី ១ ដូចតទៅ :

អធ្យាស្រ័យរបស់ព្រះមហាបុរសនោះ ទន់ទោរទៅបង្អោនទៅក្នុងសម្មាសម្ពោធិញ្ញាណ តែម្យ៉ាងប៉ុណ្ណោះយ៉ាងណា ការប្រព្រឹត្តធ្វើនូវប្រយោជន៍ឱ្យដល់សត្វទាំងឡាយ ក៏យ៉ាងនោះដែរ ។ ព្រះមហាបុរសនោះ បានធ្វើនូវការតាំងចិត្តមាំទាំពិតប្រាកដ ដើម្បីសម្មាសម្ពោធិញ្ញាណ

ក្នុងសំណាក់នៃព្រះសម្មាសម្ពុទ្ធក្នុងកាលមុនៗ ដោយចិត្ត និងវាចាថា សូម្បីអាត្មាអញ ក៏នឹងយ៉ាងនោះដែរ គឺនឹងជាព្រះសម្មាសម្ពុទ្ធ ញុំាងប្រយោជន៍សុខឱ្យសម្រេចដល់សត្វទាំងឡាយដោយប្រពៃហ្នឹងឯង ។ ព្រះមហាបុរសដល់ព្រមដោយឧបនិស្ស័យ មានឥន្រ្ទិយបរិសុទ្ធ មានញាណបរិសុទ្ធ ព្រះមហាបុរសជាអ្នកបដិបត្តិដើម្បីប្រយោជន៍អ្នកដទៃ មិនមែនដើម្បីប្រយោជន៍ខ្លួនឯងឡើយ (សូម្បីព្រះអង្គបានត្រាស់ដឹងជាព្រះសម្មាសម្ពុទ្ធ ដែលចាត់ថាជាប្រយោជន៍ចំពោះព្រះអង្គ តែនេះក៏ដើម្បីជាប្រយោជន៍ដល់អ្នកដទៃដែរ ក្នុងពុទ្ធកិច្ចទាំងឡាយ ) ។ ជាការពិតណាស់ អ្នកដទៃទៀតមិនបានបដិបត្តិដូចយ៉ាងព្រះមហាបុរសឡើយ គឺព្រះមហាបុរសបដិបត្តិដើម្បីប្រយោជន៍ដើម្បីសេចក្តីសុខដល់ទេវតា និងមនុស្សទាំងឡាយ ។ ព្រះមហាបុរសជាបុគ្គលឆ្លាតក្នុងប្រយោជន៍សុខ ដោយបដិភាណ ដែលកើតឡើងតាមឋានៈ ព្រមទាំងជាបុគ្គលឆ្លាតក្នុងឋានៈ និងអដ្ឋានៈដ៏យ៉ាងអស្ចារ្យ ។



អធ្យាស្រ័យនៃព្រះមហាបុរស ប្រព្រឹត្តទៅក្នុងទានបារមី មានសេចក្តីជាអាទិ៍ថា ប្រក្រតីនៃព្រះមហាបុរសមានអធ្យាស្រ័យក្នុងទាន ត្រេកអរក្នុងទាន កាលមានទេយ្យធម៌រមែងលះបង់ឱ្យទៅជាទានតែម្តង ។ មិននឿយណាយចាកភាពជាអ្នកមានប្រក្រតីចែកចាយរឿយៗជានិច្ច មានចិត្តអើពើនិងរីករាយក្នុងការឱ្យ គួរដល់ការសូម និងត្រេកអរក្នុងការចែករំលែក ។ កាលឱ្យទាន សូម្បីទេយ្យធម៌ច្រើនសន្ធឹកសន្ធាប់ហើយ តែក៏នៅមិនឆ្អែតក្នុងការឱ្យ ដូច្នេះមិនចាំបាច់និយាយក្នុងការឱ្យតិចឡើយ ។ កាលដែលញុំាងនូវឧស្សាហៈឱ្យកើតឡើងដល់អ្នកដទៃ រមែងពោលដល់គុណនៃការឱ្យ ពោលគឺ សម្តែងធម៌ពណ៌នាអំពីទានកថា ។ ឃើញអ្នកឱ្យទានរមែងពេញចិត្ត ។ ឱ្យអភ័យដល់អ្នកដទៃ ។

អធ្យាស្រ័យនៃព្រះមហាបុរស ប្រព្រឹត្តទៅក្នុងសីលបារមី មានសេចក្តីជាអាទិ៍ថា ព្រះមហាបុរសរមែងខ្មាសខ្ពើម និងខ្លាចនូវធម៌លាមកទាំងឡាយ មានការ

សម្លាប់សត្វជាដើម។ ជាអ្នកមិនបៀតបៀនសត្វទាំងឡាយ ត្រេកអរក្នុងកុសលធម៌ មានសីល មិនអួតអាង មិនមានមាយា ស្មោះត្រង់ ប្រដៅងាយ ប្រកបដោយធម៌ដែលធ្វើឱ្យជាអ្នកប្រដៅងាយ ទន់ភ្លន់ មិនរឹងត្អឹង មិនមើលងាយអ្នកដទៃ មិនកាន់យករបស់អ្នកដទៃ ដោយទីបំផុតសូម្បីតែស្មៅ ឬកាលបើអ្នកដទៃភ្លេចរបស់អ្វីនៅនឹងកន្លែងរបស់ខ្លួន ក៏ប្រាប់ឱ្យគេដឹងហើយប្រគល់ឱ្យគេវិញ ។ មិនជាអ្នកលោភលន់ សូម្បីគ្រាន់តែចិត្តលាមកក្នុងការកាន់យករបស់អ្នកដទៃ ក៏មិនឱ្យកើតឡើងដែរ ។ វៀរចាកការប្រព្រឹត្តខុសក្នុងស្ត្រីទាំងឡាយតាំងតែពីចម្ងាយ ។ និយាយពិត ទុកចិត្តបាន ផ្សះផ្សាមនុស្សដែលបែកគ្នា ផ្តល់នូវអ្វីដែលជាប្រយោជន៍ឱ្យ និយាយពីរោះ មុខមាត់ស្រស់បស់ និយាយប្រកបដោយអត្ថ ប្រកបដោយធម៌ មិនមានអភិជ្ឈា មិនមានព្យាបាទ មានសម្មាទិដ្ឋិដោយដឹងថា សត្វទាំង-ឡាយមានកម្មជារបស់ខ្លួន កំណត់ដឹងអរិយសច្ច មានកតញ្ញូកតវេទី មានការគោរពឱនលំទោនដល់បុគ្គលដែល



ចម្រើនដោយគុណ មានអាជីពបរិសុទ្ធ ប្រាថ្នាធម៌ បបួលអ្នកដទៃឱ្យតាំងនៅក្នុងធម៌ ហាមសត្វទាំងឡាយចាកអ្វីដែលមិនគួរធ្វើដោយប្រការទាំងពួង ហើយឱ្យតាំងនៅក្នុងអ្វីដែលគួរធ្វើវិញ ។

អធ្យាស្រ័យនៃព្រះមហាបុរស ប្រព្រឹត្តទៅក្នុងនេក្ខម្មបារមី មានសេចក្តីជាអាទិ៍ថា ព្រះមហាបុរស ជាបុគ្គលមានកិលេសស្រាលស្តើង មាននីវរណៈតិចតួច មានអធ្យាស្រ័យក្នុងសេចក្តីស្ងាត់ មិនរវើរវាយ វិតក្កដ៏លាមកមិនហូរចូលទៅកាន់ចិត្តនៃព្រះមហាបុរសឡើយ ។ ចិត្តរបស់ព្រះមហាបុរសនោះ ដល់នូវសេចក្តីស្ងាត់ តាំងមាំដោយមិនលំបាក ។ ភាពជាបុគ្គលមានមេត្តា ប្រព្រឹត្តទៅបានយ៉ាងឆាប់ រកបុគ្គលសូម្បីជាសត្រូវ មិនចាំបាច់និយាយដល់បុគ្គលដទៃទៀតឡើយ ។ ជាអ្នកមានសតិរលឹកដល់អ្វីៗ ដែលបានធ្វើ និងសូម្បីពាក្យសម្តីដែលនិយាយយូរហើយ ។ ជាអ្នកមានបញ្ញា និងជាអ្នកឆ្លាតក្នុងកិច្ចដែលគួរធ្វើនោះៗ ។ ជាអ្នកប្រារព្ធនូវសេចក្តីព្យាយាម

ក្នុងការធ្វើប្រយោជន៍ឱ្យដល់សត្វទាំងឡាយ ។ ជាអ្នកប្រកបដោយកម្លាំងខន្តិ អត់ធន់បានទាំងអស់ ។ ជាអ្នកមានការតាំងចិត្តមិនញាប់ញ័រ សមាទានមាំទាំ ។ ជាអ្នកមានមេត្តា និងជាអ្នកព្រងើយក្នុងធម៌ទាំងឡាយ ដែលជាទីតាំងនៃឧបេក្ខា ។

កាលដែលព្រះមហាបុរសប្រកបដោយលក្ខណៈនៃពោធិសម្ភារទាំងនេះដោយប្រការដូច្នេះ លោកទើបពោលថា ការអាស្រ័យនូវកល្យាណមិត្តជាហេតុនៃអភិនីហារ ។ កល្យាណមិត្តក្នុងលោកនេះ ជាអ្នកដល់ព្រមដោយសទ្ធា សីល សុតៈ ចាគៈ វីរិយៈ សតិ សមាធិ និងបញ្ញា ។

ជឿការត្រាស់ដឹងរបស់ព្រះតថាគត និងផលរបស់កម្ម ដោយសទ្ធាសម្បត្តិ ។

មិនលះបង់នូវការស្វែងរកប្រយោជន៍ ឱ្យដល់សត្វទាំងឡាយ ដែលជាហេតុនៃសម្មាសម្ពោធិញ្ញាណ ជាទីស្រឡាញ់ពេញចិត្ត និងជាទីគោរពលើកតម្កើងរបស់សត្វទាំងឡាយ ជាអ្នករំលឹកដាស់តឿន តិះដៀលអំពើអាក្រក់



និងអត់ធន់ចំពោះពាក្យសម្តី ដោយសីលសម្បត្តិ ។

ជាអ្នកពោលធម៌ជ្រៅជ្រះ ល្អិតល្អន់ នាំមកនូវប្រយោជន៍សុខដល់សត្វទាំងឡាយ ដោយសុតសម្បត្តិ ។

ជាអ្នកប្រាថ្នាតិច សន្តោស ស្ងប់ស្ងាត់ និងមិនច្របូកច្របល់ដោយពួកគណៈ ដោយចាគសម្បត្តិ ។

ជាអ្នកប្រារព្ធសេចក្តីព្យាយាមក្នុងការបដិបត្តិ ដើម្បីប្រយោជន៍ដល់សត្វទាំងឡាយ ដោយវីរិយសម្បត្តិ ។

ជាអ្នកមានសតិមាំទាំ ក្នុងធម៌ដែលមិនមានទោស ដោយសតិសម្បត្តិ ។

ជាអ្នកមិនរវើរវាយ មានចិត្តមាំទាំ ដោយសមាធិសម្បត្តិ ។

ជាអ្នកដឹងសេចក្តីច្បាស់មិនវិបរិត ដោយបញ្ញាសម្បត្តិ ។

ព្រះមហាបុរសនោះ ស្វែងរកគតិនៃកុសលធម៌ និងអកុសលធម៌ដោយសតិ ។ ដឹងអ្វីជាប្រយោជន៍ និងអ្វីដែលមិនមែនជាប្រយោជន៍ របស់សត្វទាំងឡាយ តាម

សេចក្ដីពិត ដោយបញ្ញា ។ មានចិត្តនឹងធឹងក្នុងធម៌នោះ ដោយសមាធិ ។ ហាមសត្វទាំងឡាយចាកសភាវៈដែលមិនជាប្រយោជន៍ ហើយឱ្យប្រកបក្នុងសភាវៈជាប្រយោជន៍ ដោយវីរិយៈ ។ ដូចព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា :

**មហាបុរស ជាបុគ្គលគួរស្រឡាញ់ គួរគោរព គួរលើកតម្កើង អត់ធន់ចំពោះពាក្យសម្ដី ព្យាយាមពន្យល់ប្រាប់រំលឹកដាស់តឿនអ្នកដទៃ ពោលពាក្យមានជម្រៅ មិនដឹកនាំក្នុងផ្លូវខុស ។**

ព្រះមហាបុរស អាស្រ័យកល្យាណមិត្ត ប្រកបដោយគុណយ៉ាងនេះហើយ រមែងញុំាងឧបនិស្ស័យសម្បត្តិរបស់ខ្លួនឱ្យផូរផង់ដោយប្រពៃនោះឯង និងជាអ្នកប្រកបដោយអធ្យាស្រ័យបរិសុទ្ធដោយល្អ ប្រកបដោយពលៈ ៤ ញុំាងអង្គ ៨ ឱ្យប្រជុំគ្នាធ្វើមហាភិនីហារ មានសភាពមិនវិលត្រឡប់វិញជាធម្មតា ជាបុគ្គលទៀងទាត់តែនឹងបានសម្រេចនូវ អនុត្តរសម្មាសម្ពោធិញ្ញាណ ក្នុងកាលខាងមុខ គឺព្រះមហាបុរសជានិយតពោធិសត្វ ។



ពលៈ ៤ របស់អភិនីហារ

១-អជ្ឈត្តិកពលៈ គឺកម្លាំងខាងក្នុង បានដល់ការពេញចិត្តគោរពធម៌ក្នុងខ្លួន ប្រព្រឹត្តទៅដើម្បីសម្មាសម្ពោ-ធិញ្ញាណ ជាអ្នកមានអធ្យាស្រ័យបង្អោនទៅតែម្យ៉ាងប៉ុណ្ណោះ ។

ព្រះមហាបុរស មានខ្លួនឯងជាធំ មានការខ្មាសខ្មើមបាបជាទីពឹងអាស្រ័យ និងដល់ព្រមដោយអភិនីហារបំពេញបារមីហើយបានសម្រេចនូវសម្មាសម្ពោធិញ្ញាណ ។

២-ពាហិរពលៈ គឺកម្លាំងខាងក្រៅ បានដល់ ការពេញចិត្តអាស្រ័យអ្នកដទៃ ប្រព្រឹត្តទៅដើម្បីសម្មាសម្ពោ-ធិញ្ញាណ ជាអ្នកមានអធ្យាស្រ័យបង្អោនទៅតែម្យ៉ាងប៉ុណ្ណោះ ។

ព្រះមហាបុរសមានលោកជាធំ មានការរាប់អានជាទីពឹងអាស្រ័យ និងដល់ព្រមដោយអភិនីហារ បំពេញបារមីហើយបានសម្រេចនូវសម្មាសម្ពោធិញ្ញាណ ។

៣-ឧបនិស្សយពលៈ គឺកម្លាំងឧបនិស្ស័យ បានដល់

ការពេញចិត្ត ដោយឧបនិស្ស័យសម្បត្តិប្រព្រឹត្តទៅដើម្បីសម្មាសម្ពោធិញ្ញាណ ជាអ្នកមានអធ្យាស្រ័យបង្អោនទៅតែម្យ៉ាងប៉ុណ្ណោះ ។

ព្រះមហាបុរស មានឥន្ទ្រិយចាស់ក្លា មានការឆ្លាតឈ្លាស អាស្រ័យសតិ និងដល់ព្រមដោយអភិនីហារ បំពេញបារមីហើយបានសម្រេចនូវសម្មាសម្ពោធិញ្ញាណ ។

៤.បយោគពលៈ គឺកម្លាំងព្យាយាម បានដល់ ការដល់ព្រមដោយសេចក្តីព្យាយាម ភាពជាអ្នកធ្វើដោយសេចក្តីគោរព ធ្វើតជាប់គ្នា ប្រព្រឹត្តិទៅដើម្បីសម្មាសម្ពោធិញ្ញាណ ជាអ្នកមានអធ្យាស្រ័យបង្អោនទៅតែម្យ៉ាងប៉ុណ្ណោះ ។

ព្រះមហាបុរស មានព្យាយាមបរិសុទ្ធ ធ្វើដោយលំដាប់ និងដល់ព្រមដោយអភិនីហារ បំពេញបារមីហើយបានសម្រេចនូវសម្មាសម្ពោធិញ្ញាណ ។

អភិនីហារនេះ ដែលដល់ព្រមដោយសមោធានធម៌ មានអង្គ ៨ មានការផ្តើមដោយភាពសម្បូណ៌ទៅ



ដោយបច្ច័យ ៤ ហេតុ ៤ ពលៈ ៤ យ៉ាងនេះ ជាបច្ច័យនៃបារមីទាំងឡាយ ព្រោះភាពជាមូលហេតុ ។

ម្យ៉ាងទៀត ធម៌ទាំងឡាយគួរអស្ចារ្យមិនធ្លាប់មាន ៤ ប្រការ រមែងតាំងនៅក្នុងព្រះមហាបុរស។ ៤ ប្រការគឺ

១.ព្រះមហាបុរសមានចិត្តប្រព្រឹត្តទៅក្នុងសព្វសត្វដោយការស្រឡាញ់ ដូចបុត្រកើតពីដើមទ្រូងរបស់ខ្លួន ។

២.ព្រះមហាបុរស មានចិត្តមិនសៅហ្មង ដោយអំណាចនៃសេចក្តីសៅហ្មងផ្សេងៗចំពោះបុត្រឡើយ ។

៣.អធ្យាស្រ័យ និងសេចក្តីព្យាយាមរបស់ព្រះមហាបុរសនោះ រមែងនាំមកនូវប្រយោជន៍សុខដល់សត្វទាំងឡាយ ។

៤.ធម៌ដែលធ្វើឱ្យបានសម្រេចជាព្រះសម្មាសម្ពុទ្ធ រមែងចម្រើន រមែងមានផលក្រៃលែងឡើងៗ ។

ព្រះមហាបុរស ប្រកបដោយការបង្គួរមកនៃបុណ្យកុសលដ៏យ៉ាងក្រៃលែងបំផុត ជាបច្ច័យនៃសេចក្តីចម្រើនទៅមុខ ជាអាហារនៃសេចក្តីសុខ ជាបុគ្គលគួរទទួលនូវ

ទក្ខិណាទាន ជាបុគ្គលគួរដល់នូវសេចក្តីគោរពដ៏យ៉ាងខ្ពង់ខ្ពស់ និងជាបុញ្ញក្ខេត្តរកបុគ្គលណាមួយដូចគ្មាន ។

មហាអភិនីហារ មានគុណសន្ធឹកសន្ធាប់ មានអានិសង្សដ៏យ៉ាងក្រៃលែងយ៉ាងនេះឯង គប្បីជ្រាបថា ជាបច្ច័យនៃបារមីទាំងឡាយ ។

## ២-បញ្ញានិងករុណា

គប្បីជ្រាបអំពីបញ្ញា និងករុណា នៃព្រះមហាបុរសដូចតទៅ :

-ខ្លួនឯងឆ្លងដោយបញ្ញា ញុំាងអ្នកដទៃឱ្យឆ្លងដោយករុណា ។

-កំណត់ដឹងទុក្ខរបស់អ្នកដទៃដោយបញ្ញា ប្រារព្ធជួយដោះទុក្ខអ្នកដទៃដោយករុណា ។

-ធុញទ្រាន់ នឿយណាយ ចំពោះទុក្ខដោយបញ្ញា ទទួលទុក្ខដោយករុណា ។

-ឆ្ពោះមុខទៅព្រះនិព្វានដោយបញ្ញា ដល់នូវវដ្តៈដោយករុណា ។



-មិនត្រេកអរក្នុងសង្សារវដ្តដោយបញ្ញា ឆ្ពោះមុខរកសង្សារវដ្តដោយករុណា ។

-នឿយណាយក្នុងទីទាំងពួងដោយបញ្ញា តែព្រោះប្រព្រឹត្តទៅដោយករុណា ទើបត្រូវអនុគ្រោះសត្វទាំងពួង។

-អាណិតសត្វទាំងពួងដោយករុណា តែព្រោះប្រព្រឹត្តទៅដោយបញ្ញា ទើបមានចិត្តនឿយណាយក្នុងទីទាំងពួង ។

-ភាពជាបុគ្គលមិនមានអហង្ការមមង្ការដោយបញ្ញា មិនមានការខ្ជិលច្រអូសដោយករុណា ។

-បានជាទីពឹងនៃខ្លួនឯង និងអ្នកដទៃ ដោយបញ្ញាខ្លាំងក្លាតាមលំដាប់ដោយបញ្ញានិងករុណា ។

ជាអ្នកមិនធ្វើខ្លួនឯងឱ្យក្តៅក្រហាយ ហើយក៏មិនធ្វើអ្នកដទៃឱ្យក្តៅក្រហាយផងដែរ ។ ការសម្រេចប្រយោជន៍ខ្លួនឯង និងប្រយោជន៍អ្នកដទៃ ។ ភាពជាអ្នកមិនមានការភ័យខ្លាចតក់ស្លុត ។ ភាពជាអ្នកមានធម៌ជាធំ និងមានលោកជាធំ ។ ភាពជាអ្នកដឹងគុណនិងជាបុព្វការី។

ការប្រាសចាកមោហៈ និងតណ្ហា ។ ការសម្រេចវិជ្ជានិងចរណៈ ។ ការសម្រេចពលៈ និងវេសារជ្ជៈគឺធម៌ធ្វើឱ្យក្លាហាន ។ ទាំងអស់នេះ គឺព្រោះអាស្រ័យបញ្ញា និងករុណា ដែលបញ្ញា និងករុណានេះ ក៏ជាបច្ច័យនៃបារមីទាំងឡាយដូចអភិនីហារនោះឯង ។

### ៣-ឧស្សាហៈ ជាដើម

ការឧស្សាហ៍ ១ បញ្ញា ១ ភាពមាំមួន ១ និងការប្រព្រឹត្តជាប្រយោជន៍ ១ គប្បីជ្រាបថា ទាំង ៤ នេះជាបច្ច័យនៃបារមីទាំងឡាយ ។

១-ឧស្សាហៈ ឧស្សាហ៍ព្យាយាម ដោយសេចក្តីអត់ធន់យ៉ាងក្រៃលែង ក្នុងការបំពេញនូវពោធិសម្ភារទាំងឡាយ ប្រព្រឹត្តទៅក្នុងបារមី ដែលបារមីនោះលោកពោលថាជាពុទ្ធភូមិ ព្រោះជាហេតុនៃការកើតបានជាព្រះសម្មាសម្ពុទ្ធ ។

២-បញ្ញា ការឆ្លាតក្នុងឧបាយនៃការបំពេញនូវពោធិសម្ភារទាំងឡាយ ។



៣-អវត្ថាន ការតាំងចិត្តមាំ ព្រោះតាំងចិត្តមិនញាប់ញ័រ ។

៤-ហិតចរិយា ការប្រព្រឹត្តជាប្រយោជន៍ ដោយមេត្តាភាវនា និងករុណាភាវនា ។

### ៤-អធ្យាស្រ័យ ៦ យ៉ាង

អធ្យាស្រ័យ ៦ យ៉ាង ដែលមានប្រភេទជានេក្ខម្មៈ បវិវេកៈ អលោភៈ អទោសៈ អមោហៈ និងនិស្សរណៈ ។ អធ្យាស្រ័យ ៦ យ៉ាងនេះ របស់ព្រះបរមពោធិសត្វទាំង-ឡាយ គប្បីជ្រាបថាជាបច្ច័យនៃបារមីទាំងឡាយ ។

១-នេក្ខម្មៈ ព្រះបរមពោធិសត្វទាំងឡាយ ជាអ្នកឃើញទោសក្នុងកាម និងក្នុងការគ្រប់គ្រងផ្ទះ ឈ្មោះថាមានអធ្យាស្រ័យក្នុងនេក្ខម្មៈ ។

២-បវិវេកៈ ព្រះបរមពោធិសត្វទាំងឡាយ ជាអ្នកឃើញទោសក្នុងការច្របូកច្របល់ ឈ្មោះថា មានអធ្យា-ស្រ័យដោយសេចក្តីស្ងប់ស្ងាត់ ។

៣-អលោភៈ ឃើញទោសក្នុងលោភៈ ឈ្មោះថា

មានអធ្យាស្រ័យមិនលោភ ។

៤-អទោសៈ ឃើញទោសក្នុងទោសៈ ឈ្មោះថាមានអធ្យាស្រ័យមិនក្រោធ ។

៥-អមោហៈ ឃើញទោសក្នុងមោហៈ ឈ្មោះថាមានអធ្យាស្រ័យមិនវង្វេង ។

៦-និស្សរណៈ ឃើញទោសក្នុងគ្រប់ភាវៈទាំងអស់ ឈ្មោះថាមានអធ្យាស្រ័យចេញចាកទុក្ខ ។

## ៥-អធ្យាស្រ័យក្នុងបារមី

ភាពជាអ្នកមានអធ្យាស្រ័យក្នុងទានជាដើម ក៏ជាបច្ច័យ នៃបារមី មានទានបារមីជាដើមផងដែរ របស់ព្រះបរមពោធិសត្វទាំងឡាយ អ្នកប្រព្រឹត្តដើម្បីពោធិញ្ញាណ។

ពិតណាស់ ព្រោះភាពជាអ្នកមានអធ្យាស្រ័យក្នុងទាន ព្រះបរមពោធិសត្វទាំងឡាយ ទើបជាអ្នកឃើញទោសក្នុងសេចក្តីកំណាញ់ ដែលជាបដិបក្ខចំពោះទាននោះឯង ហើយរមែងបំពេញនូវទានបារមីឱ្យបរិបូណ៌ដោយប្រពៃ ។



ព្រោះជាអ្នកមានអធ្យាស្រ័យក្នុងសីល ទើបជាអ្នកឃើញទោសក្នុងការទ្រុស្តសីល ហើយរមែងបំពេញនូវសីលបារមីឱ្យបរិបូណ៌ដោយប្រពៃ ។

ព្រោះជាអ្នកមានអធ្យាស្រ័យក្នុងនេក្ខម្ម ទើបជាអ្នកឃើញទោសក្នុងកាម និងការគ្រប់គ្រងផ្ទះ ហើយរមែងបំពេញនូវនេក្ខម្មបារមីឱ្យបរិបូណ៌ដោយប្រពៃ ។

ព្រោះជាអ្នកមានអធ្យាស្រ័យក្នុងការដឹងតាមសេចក្តីពិត ទើបជាអ្នកឃើញទោសក្នុងការមិនដឹង និងការសង្ស័យ ហើយរមែងបំពេញនូវ បញ្ញាបារមីឱ្យបរិបូណ៌ដោយប្រពៃ ។

ព្រោះជាអ្នកមានអធ្យាស្រ័យក្នុងសេចក្តីព្យាយាម ទើបជាអ្នកឃើញទោសក្នុងសេចក្តីខ្ជិល ហើយរមែងបំពេញនូវវីរិយបារមីឱ្យបរិបូណ៌ដោយប្រពៃ ។

ព្រោះជាអ្នកមានអធ្យាស្រ័យក្នុងសេចក្តីអត់ធន់ ទើបជាអ្នកឃើញទោសក្នុងការមិនអត់ធន់ ហើយរមែងបំពេញនូវខន្តិបារមីឱ្យបរិបូណ៌ដោយប្រពៃ ។

ព្រោះជាអ្នកមានអធ្យាស្រ័យក្នុងសច្ចៈ ទើបជាអ្នកឃើញទោសក្នុងការនិយាយមិនពិត ហើយរមែងបំពេញនូវសច្ចបារមីឱ្យបរិបូណ៌ដោយប្រពៃ ។

ព្រោះជាអ្នកមានអធ្យាស្រ័យក្នុងការតាំងចិត្តមាំ ទើបជាអ្នកឃើញទោសក្នុងការមិនតាំងចិត្តមាំ ហើយរមែងបំពេញនូវអធិដ្ឋានបារមីឱ្យបរិបូណ៌ដោយប្រពៃ ។

ព្រោះជាអ្នកមានអធ្យាស្រ័យក្នុងមេត្តា ទើបជាអ្នកឃើញទោសក្នុងព្យាបាទ ហើយរមែងបំពេញនូវមេត្តាបារមីឱ្យបរិបូណ៌ដោយប្រពៃ ។

ព្រោះជាអ្នក មានអធ្យាស្រ័យក្នុងការព្រងើយ-កន្តើយ ទើបជាអ្នកឃើញទោសក្នុងលោកធម៌ ហើយរមែងបំពេញនូវឧបេក្ខាបារមីឱ្យបរិបូណ៌ដោយប្រពៃ ។

ភាពជាអ្នកមានអធ្យាស្រ័យក្នុងទានជាដើម ជាបច្ច័យនៃបារមី មានទានបារមីជាដើម ព្រោះជាហេតុឱ្យសម្រេច ។



## ៦-ពិចារណាទោសនិងអានិសង្ស

ការពិចារណាឃើញទោសនិងអានិសង្ស តាមលំដាប់នៃការមិនបរិច្ចាគ និងការបរិច្ចាគជាដើម ជាបច្ច័យនៃបារមីទាំងឡាយ មានទានបារមីជាដើម ។ គប្បីជ្រាបវិធីពិចារណាដូចតទៅ :

ពិចារណាទានបារមី ទ្រព្យ នាំមកនូវសេចក្តីវិនាសច្រើនសន្ធឹកសន្ធាប់ យ៉ាងនេះគឺ

-ភាពជាអ្នកប្រាថ្នាច្រើនដោយវត្ថុកាម មានដីធ្លី ស្រែចំការ មាសប្រាក់ជាដើម នៃបុគ្គលទាំងឡាយដែលមានចិត្តហួងហែង ជាប់ជំពាក់នៅក្នុងវត្ថុកាមនោះៗ ។

-សាធារណភ័យ មានចោរភ័យ រាជភ័យ និងអគ្គិភ័យជាដើម ។

-ការតាំងចិត្តឈ្លោះប្រកែកគ្នា ជាសត្រូវនឹងគ្នា បៀតបៀនគ្នាជាដើម ។

-របស់ដែលមិនមានខ្លឹមសារ ។

-ប្រព្រឹត្តទុច្ចរិតក្នុងការស្វែងរកទ្រព្យ ។

-មានដំណើរទៅកាន់អបាយភូមិ នៃបុគ្គលដែលមានចិត្តសៅហ្មង ជាប់ជំពាក់ក្នុងទ្រព្យ ។

គួរធ្វើសេចក្តីមិនប្រមាទក្នុងការបរិច្ចាគថា ការបរិច្ចាគវត្ថុទាំងនោះជាមង្គលដ៏ឧត្តម ។

ម្យ៉ាងទៀតគប្បីពិចារណាថា -

-ស្មូមជាបុគ្គលស្និទ្ធស្នាលរបស់យើង ព្រោះប្រាប់អាថ៌កំបាំងរបស់ខ្លួនគាត់ឱ្យយើងដឹង ។

-ស្មូមជាអ្នកណែនាំដល់យើងថា អ្នកចូរលះទ្រព្យដែលមិនមានខ្លឹមសារ ហើយកាន់យកនូវទ្រព្យដែលមានខ្លឹមសារ ជារបស់ខ្លួនពិតទៅកាន់បរលោក ។

-ស្មូមគឺជាសម្លាញ់ជួយរែកជញ្ជូនទ្រព្យរបស់យើងអំពីលោកនេះ នៅពេលដែលខន្ធលោកនេះត្រូវភ្លើង គឺមរណៈឆាបឆេះ ដូចផ្ទះដែលត្រូវភ្លើងឆេះដូច្នោះឯង ។

-ស្មូមជាកល្យាណមិត្តដ៏ក្រៃលែង ព្រោះជាសម្លាញ់ក្នុងការឱ្យទាន និងព្រោះជាអ្នកជ្រោមជ្រែងជួយឱ្យបានដល់ពុទ្ធភូមិ ដែលបានដោយលំបាកដ៏ក្រៃលែងជាងសម្បត្តិ



ទាំងពួង ។

-ស្មូម ជាអ្នកលើកតម្កើងយើងក្នុងកម្មដ៏ក្រៃលែង ព្រោះដូច្នោះ គួរធ្វើនូវការលើកតម្កើងនោះ ឱ្យបានសម្រេចជាការពិត ។

-ស្មូម្បីគេមិនស្មូម ក៏យើងដែរឱ្យ ព្រោះជីវិតរបស់គេប្រាកដច្បាស់ស្រេចហើយ មិនចាំបាច់និយាយដល់ការស្មូមនោះឡើយ ។

-ស្មូមមកហើយដោយខ្លួនឯង ត្រូវតាមអធ្យាស្រ័យដ៏ក្រៃលែង មិនចាំបាច់ស្វែងរក គួរឱ្យដោយបុណ្យរបស់យើង ។

-ការអនុគ្រោះរបស់យើងនេះ ដោយសំដៅដល់ការឱ្យទានដល់ស្មូមយាចក យើងគួរអនុគ្រោះសត្វលោកដូចអនុគ្រោះខ្លួនយើង ។

-កាលបើស្មូមយាចកមិនមានទេ ទានបារមីរបស់យើងនឹងគប្បីពេញបានយ៉ាងដូចម្តេច ។

-យើងគប្បីជាទីស្រឡាញ់ និងជាទីពេញចិត្តរបស់

ស្នូមទាំងឡាយបានយ៉ាងណា ។

-ស្នូមយាចកទាំងនោះ គប្បីជាទីស្រឡាញ់ ជាទីពេញចិត្តរបស់យើងបានយ៉ាងដូចម្ដេចដែរ ។

-នៅពេលឱ្យ យើងក៏ពេញចិត្ត លុះឱ្យរួចហើយក៏រីករាយ កើតបីតិសោមនស្សបាននោះ តើយ៉ាងណាទៅ ។

-កាលបើទ្រព្យមាន ស្នូមយាចកក៏មាន តែមិនបរិច្ចាគ គឺវាជាការបោកបញ្ឆោតខ្លួនឯងដ៏ក្រៃលែង ។

<u>ពិចារណាសីលបារមី</u>

-សីលជាទឹកលាងនូវមន្ទិលគឺទោសៈ ដែលមិនអាចជម្រះបាន ដោយទឹកទន្លេគង្គាជាដើម ។

-សីលកម្ចាត់នូវអន្តរាយមានរាគៈជាដើម ដែលមិនអាចកម្ចាត់បានដោយចន្ទន៍លឿងជាដើម ។

-សីល ជាគ្រឿងប្រដាប់យ៉ាងវិសេសរបស់មនុស្សល្អទាំងឡាយ ។

-សីល មានក្លិនក្រអូបផ្សាយទៅគ្រប់ទិស និងសមគួរគ្រប់កាល ។

-៤៩-

-សីលមានអំណាចដ៏ក្រៃលែង ព្រោះនាំមកនូវគុណ ដែលក្សត្រមហាសាលជាដើម និងទេវតាទាំងឡាយគួរក្រាបសំពះ ។

-សីល ជាជណ្ដើរឡើងទៅកាន់ទេវលោក មានឋានសួគ៌ជាន់ចាតុម្មហារាជិកាជាដើម ។

-សីល ជាឧបាយនាំឱ្យបានសម្រេចនូវឈាន និងអភិញ្ញា ។

-សីល ជាផ្លូវឱ្យទៅដល់មហានគរគឺព្រះនិព្វាន ។

-សីល ជាភូមិប្រតិស្ឋាននូវសាវកពោធិ បច្ចេកពោធិ និងសម្មាសម្ពោធិញ្ញាណ ។

-សីល ដូចជាកែវទិព្វ ឬដើមកប្បព្រឹក្ស ព្រោះជាឧបាយឱ្យសម្រេចនូវអ្វីៗតាមដែលប្រាថ្នា ។

-សីល ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា :

ម្នាលភិក្ខុទាំងឡាយ ប្រសិនបើភិក្ខុមានសេចក្ដីប្រាថ្នាថា អាត្មាអញគប្បីជាទីស្រឡាញ់ ជាទីពេញចិត្ត ជាទីគោរព ជាទីលើកតម្កើង របស់សព្រហ្មចារីទាំងឡាយ

-៥០-

ភិក្ខុគប្បីជាអ្នកធ្វើឱ្យបរិបូណ៌ក្នុងសីលទាំងឡាយចុះ ។

ម្នាលអានន្ទ កុសលសីល មានការមិនក្តៅក្រហាយជាប្រយោជន៍ ។

ម្នាលគហបតីទាំងឡាយ នេះជាអានិសង្ស ៥ យ៉ាង របស់អ្នកមានសីល ។ ៥ យ៉ាងគឺ ១.ដល់ព្រមដោយភោគសម្បត្តិ ; ២.មានកិត្តិគុណ កិត្តិសព្ទល្បីខ្ចរខ្ចាយទៅ ; ៣.មានសេចក្តីក្លៀវក្លាក្នុងកណ្តាលបរិស័ទ ; ៤.នឹងមិនវង្វេងនៅពេលជិតស្លាប់ ; ៥.ស្លាប់ហើយនឹងទៅកើតនៅសុគតិសួគ៌ទេវលោក ។

-សីលជានិមិត្តនៃបីតិ និងសោមនស្ស ដោយការមិនតិះដៀលខ្លួនឯងផង អ្នកដទៃមិនតិះដៀលផង វិញ្ញូជនសរសើរផង មិនមានអាជ្ញាភ័យផង និងមិនមានទុគ្គតិភ័យផង ។

-សីលជាទីតាំងនៃសិរីសួស្តី ព្រោះតាំងចិត្តទុកក្នុងសេចក្តីមិនប្រមាទ និងព្រោះញ៉ាំងប្រយោជន៍ធំឱ្យសម្រេចដោយមានការគ្រប់គ្រងរក្សាអំពីសីល ដែលសីលនេះជា



មង្គលដ៏ឧត្តម ។

-សីលជាកុលសម្បត្តិ ព្រោះថាសូម្បីបុគ្គលមានជាតិត្រកូលទាបក៏ដោយ លុះដល់បានបួសជាភិក្ខុអ្នកមានសីល ក៏ជាបូជនីយបុគ្គលរបស់ក្សត្រមហាសាលជាដើមដោយពិត ។

-សីលជាសម្បត្តិដ៏ប្រសើរ ក្រៃលែងជាងសម្បត្តិខាងក្រៅ ព្រោះមិនទូទៅដល់ចោរ ដល់ទឹកភ្លើងជាដើម ព្រោះអនុគ្រោះដល់លោកខាងមុខ ព្រោះមានផលច្រើន និងព្រោះជាអធិដ្ឋានគុណ គឺជាទីតាំងនៃសមថៈ និងវិបស្សនាជាដើម ។

-សីលជាធំ មានភាពជាឥស្សរៈដ៏ក្រៃលែង ជាងព្រះមហាក្សត្រទៅទៀត ព្រោះជាឥស្សរៈមាំមួនផ្លូវចិត្ត មិនជាទាសៈក្នុងការប្រព្រឹត្តបញ្ចវេរាជាដើម ។

-សីលប្រសើរជាងជីវិត និងធ្វើឱ្យជីវិតរស់នៅសូម្បីតែមួយថ្ងៃ ប្រសើរជាងជីវិតអត់សីលហើយរស់នៅអស់រយនៃឆ្នាំ ។

-សីលប្រសើរជាងរូបសម្បត្តិ ព្រោះសីលនាំមកនូវការពេញចិត្ត សូម្បីតែគេនោះជាសត្រូវ ឬចោរ និងព្រោះជរា រោគព្រមទាំងវិបត្តិផ្សេងៗគ្របសង្កត់មិនបាន ។ រូបកាយ ចាស់ជរា ឈឺ និងលំបាកថែរក្សារាល់ថ្ងៃ ហើយត្រូវបញ្ចប់ត្រឹមស្លាប់ទៅត្រូវដុត ឬកប់ប៉ុណ្ណោះឯង ។

-សីលវិសេសលើសលំនៅឋាន មានវិមានប្រាសាទជាដើមទៅទៀត ព្រោះជាការតាំងចិត្តដ៏វិសេស ជាសុខ-ភាពរបស់ចិត្ត សុខត្រជាក់ ដោយចិត្តមានសីលហ្នឹងឯង ។

-សីលជាញាតិដ៏ក្រៃលែង ព្រោះថាសូម្បីមាតាបិតាក៏មិនអាចធ្វើឱ្យសម្រេចបានដែរ នូវអ្វីដែលជាប្រយោជន៍របស់សីល តែសីលអាចឱ្យសម្រេចបាននូវសម្បត្តិទាំងពួងនោះៗ ទាំងអនុគ្រោះដល់បរលោក ទាំងសម្បត្តិនិព្វាន ។

-សីលប្រសើរជាងចតុរង្គសេនា របស់ព្រះរាជា ព្រោះសីលច្បាំងឈ្នះកិលេសខ្លួនឯង ។

-សីលប្រសើរជាងមន្ត និងថ្នាំទិព្វ ព្រោះសីលជាគ្រឿងរក្សាខ្លួន ដែលគេរក្សាបានដោយកម្រ ។



-សីលនាំឱ្យមានខ្លួនឯងជាទីពឹង និងនាំឱ្យអ្នកមានសីល មានអធ្យាស្រ័យប្រណីតឡើងៗ ។

ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា « **ធម្មោ ហវេ រក្ខតិ ធម្មចារឹ** ធម៌រមែងរក្សានូវអ្នកប្រព្រឹត្តធម៌ » ។

កាលព្រះមហាបុរស ពិចារណាឃើញថា សីលប្រកបដោយគុណដ៏ច្រើនក្រៃលែងយ៉ាងនេះហើយ សីល-សម្បទាដែលនៅមិនទាន់បរិបូណ៌ ក៏ដល់នូវភាពបរិបូណ៌ដែលមិនទាន់បរិសុទ្ធ ក៏ដល់នូវភាពបរិសុទ្ធ ដោយប្រការដូច្នេះឯង ។

ប្រសិនបើធម៌ទាំងឡាយមានទោសៈជាដើម ជាបដិបក្ខដល់សីល គប្បីកើតឡើងដល់មហាបុរសនោះ ក្នុងរវាងៗដោយសន្សំសន្តានមកយូរហើយ បុគ្គលដែលជាព្រះពោធិសត្វនោះ រមែងពិចារណាយ៉ាងនេះថា « អ្នកតាំងចិត្តពិតប្រាកដ ដើម្បីត្រាស់ដឹង ប៉ុន្តែសូម្បីសម្បត្តិជាលោកិយ អ្នកក៏នៅមិនអាចឱ្យដល់ទៅបានផង ដោយភាពមិនប្រក្រតីនៃសីល ព្រោះទោសៈនេះឯង ដូច្នេះមិន

ចាំបាច់និយាយដល់សម្បត្តិជាលោកុត្តរឡើយ ។ សីលជាអធិដ្ឋានដើម្បីសម្មាសម្ពោធិញ្ញាណ ដ៏លើសលប់ជាងសម្បត្តិទាំងពួង គួរឱ្យបានដល់ដោយឧក្រិដ្ឋក្រៃលែង ។ ម្យ៉ាងទៀត ភាពជាអ្នកធ្វើនូវឧបការៈដល់សត្វទាំងឡាយ និងការបំពេញបារមី មានបញ្ញាបារមីជាដើមរបស់យើង ព្រមទាំងការប្រកបនូវគុណវិសេសមានឈានជាដើមនោះ វៀរចាកសេចក្តីបរិសុទ្ធនៃសីលហើយ រមែងសម្រេចមិនបានឡើយ ព្រោះហេតុនោះ អ្នកទើបគួរញ៉ាំងសីលឱ្យបរិសុទ្ធដោយប្រពៃ » ។ នេះជាសេចក្តីដែលព្រះបរម-ពោធិសត្វពិចារណានូវគុណរបស់សីល ដើម្បីគ្របសង្កត់នូវធម៌បដិបក្ខរបស់សីល ។

<u>ពិចារណានេក្ខម្មបារមី</u>

គប្បីជ្រាបការពិចារណាក្នុងការគ្រប់គ្រងផ្ទះដោយន័យមានជាអាទិ៍ថា ការគ្រប់គ្រងផ្ទះចង្អៀតចង្អល់ជាផ្លូវនៃធូលី គឺកិលេស ។ កាមទាំងឡាយឧបមាដូចជាគ្រោងឆ្អឹងជាដើម សូម្បីបុត្រក៏ឈ្លោះនឹងមាតា ។ល។ ដូចបុរស



បុលបំណុលគេទៅប្រកបការងារ។ល។ គប្បីជ្រាបសេចក្តីពិស្តារក្នុងទុក្ខក្ខន្ធសូត្រ និងអាសីវិសូបមសូត្រជាដើម ។

ក្នុងនេក្ខម្មបារមី គប្បីជ្រាបដោយការពិចារណានូវអានិសង្សក្នុងបព្វជ្ជាជាដើម ដោយន័យមានជាអាទិ៍ថា បព្វជ្ជាជាអព្ភោកាស គឺឱកាសស្រឡះល្អដ៏ក្រៃលែង ។ល។

<u>ពិចារណាបញ្ញាបារមី</u>

គប្បីមនសិការដល់បញ្ញាគុណថា ធម៌ទាំងឡាយមានទានជាដើម បើវៀរចាកបញ្ញាហើយ រមែងមិនអាចបរិសុទ្ធបានឡើយ ។ រមែងមិនមានសមត្ថភាពក្នុងការងារជារបស់ខ្លួន ។ ដូចសរីរយន្ត បើប្រាសចាកជីវិតហើយ ក៏រមែងមិនល្អមិនស្អាត ។ ឥន្ទ្រិយទាំងឡាយមានចក្ខុន្ទ្រិយជាដើម បើវៀរចាកនូវវិញ្ញាណហើយ ក៏មិនល្មមនឹងធ្វើកិច្ច ក្នុងវិស័យរបស់ខ្លួនបាន យ៉ាងណា ឥន្ទ្រិយទាំងឡាយមានសទ្ធិន្ទ្រិយជាដើម ក៏យ៉ាងនោះដែរ បើវៀរចាកបញ្ញាហើយ ក៏មិនអាចបដិបត្តិកិច្ចរបស់ខ្លួនបាន ។

ព្រោះហេតុនោះ បញ្ញាទើបជាធំក្នុងការបដិបត្តិ

មានការបរិច្ចាគជាដើម ។ ពិតណាស់ ព្រះមហាពោធិសត្វទាំងឡាយ ជាអ្នកមានបញ្ញាចក្ខុបើកហើយ ឱ្យទានសូម្បីតែអវយវៈតូចធំរបស់ខ្លួន ព្រមលះបង់នូវជីវិតក្នុងកិច្ចដែលត្រូវលះ និងមិនលើកខ្លួនប្រៀបផ្ទឹមនឹងអ្នកដទៃ កើតសោមនស្សក្នុងកាលទាំង ៣ ដែលមិនអាចកំណត់បានប្រៀបដូចដើមឈើដែលជាថ្នាំ ។ ការបរិច្ចាគប្រកបដោយបញ្ញាឆ្លាតក្នុងឧបាយ រមែងចូលដល់នូវភាពជាទានបារមី ព្រោះប្រព្រឹត្តទៅដើម្បីជាប្រយោជន៍ដល់អ្នកដទៃ ព្រោះថា ទានគឺដូចជាកម្រៃដែលជាប្រយោជន៍របស់ខ្លួន ។

ម្យ៉ាងទៀត សេចក្តីបរិសុទ្ធនៃសីល ដោយប្រាស-ចាកសេចក្តីសៅហ្មងមានតណ្ហាជាដើម រមែងសម្រេចមិនបានឡើយ បើមិនមានបញ្ញាទេនោះ ដូច្នេះអធិដ្ឋានគុណដើម្បីភាពជាព្រះសព្វញ្ញូនឹងសម្រេចបានមកពីណា ។

មានតែបុគ្គលមានបញ្ញាប៉ុណ្ណោះ ដែលពិចារណាឃើញទោសក្នុងការគ្រប់គ្រងផ្ទះ ក្នុងកាមគុណទាំងឡាយ និងក្នុងវដ្តសង្សារ ហើយពិចារណាឃើញអានិសង្សក្នុង



ការបព្វជ្ជា ក្នុងឈានសមាបត្តិ និងក្នុងព្រះនិព្វានដោយល្អ និងព្រោះតែបញ្ញា ទើបញ៉ាំងការបួសឱ្យបានសម្រេចនូវប្រយោជន៍ ញ៉ាំងឈានសមាបត្តិឱ្យកើត ឆ្ពោះមុខទៅព្រះនិព្វាន ព្រមទាំងញ៉ាំងមនុស្សដទៃឱ្យតាំងនៅក្នុងឈានសមាបត្តិនោះៗទៀតផង ។

បញ្ញា មិនបានញ៉ាំងនូវសេចក្តីព្យាយាមឱ្យប្រាស-ចាកបញ្ញាប្រព្រឹត្តទៅនោះឡើយ ហើយក៏មិនមែនដោយគ្រាន់តែតាំងសេចក្តីប្រាថ្នាទុក ឱ្យសម្រេចទៅបានដោយចាប់ផ្តើមព្យាយាមមិនល្អទៅនោះដែរ ព្រោះថា ការមិនចាប់ផ្តើម វាប្រសើរជាងការចាប់ផ្តើមមិនល្អ ។

បញ្ញារមែងញ៉ាំងសេចក្តីព្យាយាមឱ្យប្រព្រឹត្តទៅដោយឧបាយដ៏ប្រសើរ ចាប់ផ្តើមក្នុងការងារជាប្រយោជន៍ប្រាសចាកទោស និងអនុគ្រោះដល់អ្នកដទៃ ។

បុគ្គលមានបញ្ញា ជាអ្នកមានសេចក្តីអត់ធន់ចំពោះវិបត្តិផ្សេងៗ ក្នុងជីវិត មិនក្តៅក្រហាយចិត្ត ។ ក្នុងសេចក្តីនេះ បុគ្គលល្ងង់ខ្លៅមិនជាអ្នកអត់ធន់ឡើយ សេចក្តីវិនាស

ដែលអ្នកដទៃនាំមកឱ្យដល់បុគ្គលល្ងង់ខ្លៅ រមែងចម្រើនកព្វូននូវធម៌ជាបដិបក្ខដល់ខន្តីសេចក្តីអត់ធន់ ប៉ុន្តែសេចក្តីវិនាសទាំងនោះ ដែលបានមកដល់អ្នកមានបញ្ញា រមែងប្រព្រឹត្តទៅ ដើម្បីភាពមាំទាំនៃខន្តីនោះ ធ្វើឱ្យមានការកព្វូនច្រើនឡើងនូវសេចក្តីអត់ធន់ ។

មានតែអ្នកមានបញ្ញាប៉ុណ្ណោះ ដែលដឹងនូវសច្ចៈ៣យ៉ាង (វចីសច្ចៈ ញាណសច្ចៈ និងវិរតិសច្ចៈ) ដឹងហេតុនៃសច្ចៈទាំងនោះ និងដឹងធម៌បដិបក្ខតាមសេចក្តីពិត ហើយគឺជាអ្នកមិននិយាយខុសចំពោះអ្នកដទៃ ។

បុគ្គលអ្នកឧបត្ថម្ភខ្លួនដោយកម្លាំងនៃបញ្ញា រមែងជាអ្នក តាំងចិត្តសមាទានមិនញាប់ញ័រ មានអធិដ្ឋានធម៌ក្នុងបារមីទាំងពួង ដោយការដល់ព្រមដោយបញ្ញា ។

មានតែអ្នកមានបញ្ញាប៉ុណ្ណោះ ដែលមិនធ្វើការបែងចែកមនុស្សជាទីស្រឡាញ់ មនុស្សកណ្តាលនិងមនុស្សដែលជាសត្រូវ ។ ជាអ្នកឆ្លាតក្នុងមេត្តា មានការនាំទៅនូវប្រយោជន៍ឱ្យដល់សត្វទាំងពួង ។



ជាអ្នកមានភាពជាកណ្តាល គឺឧបេក្ខា មិនមានការខុសប្រក្រតី នៅពេលជួបប្រសព្វនូវលោកធម៌មានលាភអត់លាភជាដើម ដោយអំណាចនៃបញ្ញា ។

បញ្ញាតែប៉ុណ្ណោះ ជាហេតុនៃសេចក្តីបរិសុទ្ធរបស់បារមីទាំងពួងដោយប្រការដូច្នេះ ព្រោះហេតុនោះ បុគ្គលគួរពិចារណាគុណរបស់បញ្ញា ។

ម្យ៉ាងទៀត បើវៀរបញ្ញាហើយ ទិដ្ឋិសម្បទារមែងមានមិនបានឡើយ ។ បើវៀរទិដ្ឋិសម្បទាដោយរវាងចន្លោះហើយ សីលសម្បទាក៏មិនអាចមានបានដែរ ។ បុគ្គលប្រាសចាកនូវសីលសម្បទា និងទិដ្ឋិសម្បទា គឺមិនអាចធ្វើឱ្យសមាធិសម្បទាសម្រេចទៅបាន ។ បើបុគ្គលមានចិត្តមិនតាំងមាំហើយ រមែងមិនអាចញុំាងសូម្បីតែប្រយោជន៍ខ្លួនឱ្យសម្រេចបាន មិនចាំបាច់និយាយទៅថ្វីដល់ប្រយោជន៍អ្នកដទៃក្នុងថ្នាក់ឧក្រិដ្ឋនោះ ព្រោះហេតុនោះ ព្រះបរមពោធិសត្វ ជាអ្នកបដិបត្តិដើម្បីប្រយោជន៍អ្នកដទៃ ទើបប្រដៅខ្លួនថា « អ្នកគួរធ្វើនូវសេចក្តី

ព្យាយាមក្នុងសេចក្ដីចម្រើននៃបញ្ញាដោយគោរព មិនមែនទេឬ ? »។ ពិតណាស់ ព្រះមហាពោធិសត្វតាំងមាំក្នុងអធិដ្ឋានធម៌ ៤ ដោយបុញ្ញានុភាព អនុគ្រោះសត្វលោកដោយសង្គហៈ ៤ រមែងញ៉ាំងសត្វទាំងឡាយឱ្យធ្លាក់ចុះកាន់មគ្គ ដែលជាការចេញចាកទៅ និងញ៉ាំងឥន្ទ្រិយរបស់សត្វទាំងនោះ ឱ្យចម្រើនជាភិយ្យោភាព ។

គប្បីកំណត់គុណរបស់បញ្ញាដ៏ខ្លាំងក្លា មានន័យជាអាទិ៍ថា បុគ្គលច្រើនដោយការស្រាវជ្រាវក្នុងខន្ធធាតុអាយតនៈជាដើម ដោយកម្លាំងបញ្ញាកំណត់ដឹងនូវការប្រព្រឹត្តទៅ និងការវិលត្រឡប់ (គឺចេញចាកកិលេស ) តាមសេចក្ដីពិត ។ ណែនាំគុណមានទានជាដើម ដែលជាចំណែកនៃចំណេះដឹងយ៉ាងវិសេស ។ រមែងជាអ្នកធ្វើឱ្យបរិបូណ៌ក្នុងការសិក្សា ហើយគប្បីកពូននូវបញ្ញាបារមី ។

<u>ពិចារណាវីរិយបារមី</u>

កម្មដែលជាលោកិយ សូម្បីប្រាកដ ក៏មិនអាចសម្រេចបានដោយសេចក្ដីព្យាយាមថោកថយ ។ បុគ្គល



ដែលប្រារព្ធនូវសេចក្ដីព្យាយាម មិនគិតដល់សេចក្ដីលំបាក រមែងនឹងបានសម្រេចដោយពិត ។ ពិតណាស់ អ្នកដែលមានសេចក្ដីព្យាយាមថោកថយ មិនអាចប្រារព្ធបានថា យើងនឹងញ៉ាំងសព្វសត្វឱ្យឆ្លងផុតចាកសមុទ្រសង្សារឡើយ ចំណែកអ្នកដែលមានសេចក្ដីព្យាយាមឧក្រិដ្ឋ សម្លឹងដល់សេចក្ដីទុក្ខរបស់សត្វក្នុងវដ្ដសង្សារ រមែងសម្រេចនូវបារមីដែលជាសេចក្ដីព្យាយាម ។

ព្រោះហេតុនោះ គប្បីពិចារណាដល់គុណនៃវីរិយ-សម្បត្តិ ដោយន័យមានជាអាទិ៍យ៉ាងនេះថា ការប្រារព្ធដើម្បីរើខ្លួនចាកអន្លង់ភក់គឺសង្សារវដ្ដរបស់បុគ្គលណា ការបានដល់ទីបំផុតនៃសេចក្ដីប្រាថ្នា ក្នុងភាពជាអ្នកមានសេចក្ដីព្យាយាមអន់ថយ សូម្បីតែខ្លួនឯងនៃបុគ្គលនោះក៏មិនអាចឱ្យសម្រេចទៅបាន មិនចាំបាច់និយាយដល់ការសាងនូវអភិនីហារ ដើម្បីជួយសង្គ្រោះដល់មនុស្សលោក និងទេវលោកឡើយ ។ ព្រោះពួកកិលេសជាគ្រឿងប្រទូសរ៉ាយ មានរាគៈជាដើម គឺហាមឃាត់បានដោយ

លំបាក ដូចដំរីចុះប្រេង ។ ព្រោះ ការសមាទានកម្មដែលមានកិលេសជាគ្រឿងប្រទូសរ៉ាយនោះជាហេតុ ដូចជាពេជ្ឈឃាតងាដាវ ដោយទុគ្គតិដែលជានិមិត្តនៃកម្មនោះបើកទ្វារជានិច្ចគ្រប់ពេល ។ ព្រោះបាបមិត្តបបួលក្នុងកម្មនោះ បានត្រៀមចាំហើយគ្រប់កាល និងព្រោះធ្វើតាមពាក្យណែនាំរបស់បាបមិត្តនោះឯង ។ ដូច្នេះទើបពោលថា បុគ្គលដែលមានព្យាយាមអន់ថយ មិនទាំងអាចជួយខ្លួនឯងរួចផង ។

ក្នុងការមានសតិរបស់បុថុជ្ជន ទើបគួរចេញចាកសង្សារទុក្ខដោយខ្លួនឯងបាន ព្រោះហេតុនោះ មិច្ឆាវិតក្ករមែងនៅឆ្ងាយដោយអានុភាពនៃសេចក្ដីព្យាយាម ។ បើថាអាចសម្រេចនូវសម្មាសម្ពោធិញ្ញាណបាន ដោយសេចក្ដីព្យាយាមរបស់ខ្លួនទៅហើយនោះ តើមានអ្វីទៀតទៅដែលធ្វើបានដោយលំបាកក្នុងសេចក្ដីនេះ ។

<u>ពិចារណាខន្តិបារមី</u>

ខន្តីជាអាវុធកម្ចាត់សេចក្ដីក្រោធជាគ្រឿងអលង្ការ



របស់អ្នកប្រាជ្ញ ជាកម្លាំងរបស់សមណព្រាហ្មណ៍ ។

ខន្តីជាទឹកពន្លត់ភ្លើង គឺសេចក្ដីក្រោធ ជាមន្តនិងជាថ្នាំដ៏វិសេស សម្រាប់រម្ងាប់ពិស គឺពាក្យអាក្រក់របស់មនុស្ស ជាគ្រឿងចង្អុលប្រាប់ដល់ទីកើតនៃកិត្តិសព្ទដ៏ប្រសើរ ជាប្រក្រតីរបស់អ្នកមានបញ្ញាតាំងនៅក្នុងការសង្រួម ។

ខន្តីជាសាគរ ព្រោះអាស្រ័យភាពដ៏មានជម្រៅ ជាត្រើយនៃមហាសាគរគឺទោសៈ ជាសន្លឹកទ្វារ បិទទ្វារអបាយភូមិ ជាជណ្ដើរឡើងទៅកាន់ទេវលោក និងព្រហ្ម-លោក ជាភូមិនិងជាទីស្ថិតនៅនៃគុណទាំងពួង ជាសេចក្ដីបរិសុទ្ធនៃកាយ វាចា និងចិត្ត ដ៏យ៉ាងខ្ពង់ខ្ពស់ ។ គប្បីមានមនសិការដោយប្រការដូច្នេះ ។

សត្វទាំងឡាយក្នុងលោកនេះ មានសេចក្ដីក្ដៅក្រហាយ ព្រោះមិនមាននូវខន្តិសម្បត្តិ ។ អត្តភាពដែលជាដែនរបស់ទុក្ខ និងកម្មដែលជាពូជនៃទុក្ខនោះ គឺយើងបានតាក់តែងហើយ នេះឯងជាហេតុនៃការជំពាក់បំណុលទុក្ខ

គប្បីពិចារណាយ៉ាងនេះឯង នៅពេលណាដែលមានអ្នកដទៃធ្វើនូវសេចក្ដីវិនាសឱ្យ ។ កាលបើមិនមានអ្នកធ្វើនូវសេចក្ដីវិនាសឱ្យទេ ខន្តិសម្បទារបស់យើងនិងកើតបានយ៉ាងណាទៅ ។

គេធ្វើសេចក្ដីវិនាសដល់យើងដោយធម៌ណា និងធ្វើក្នុងទីណា ធម៌នោះទាំងអស់ក៏រលត់ទៅក្នុងខណៈនោះឯង ។ ឥឡូវនេះតើអ្នកណាធ្វើនូវសេចក្ដីក្រោធឱ្យដល់អ្នកណា និងអ្នកណាខុសចំពោះអ្នកណា ព្រោះធម៌ទាំងពួងជាអនត្តា ។ ពិចារណាយ៉ាងនេះហើយ គួរកពូននូវខន្តិសម្បទា ដោយប្រការដូច្នេះ ។

សត្វលោកទាំងអស់នេះ ព្រះសម្មាសម្ពុទ្ធជាម្ចាស់គ្រប់គ្រងដូចបុត្រកើតអំពីព្រះអង្គ ព្រោះហេតុដូច្នោះយើងមិនគួរញ៉ាំងចិត្តក្រោធឱ្យកើតឡើងក្នុងសត្វទាំងអស់នេះទេ ។

កាលបើអ្នកធ្វើខុសនោះមានគុណ យើងមិនគួរធ្វើសេចក្ដីក្រោធទៅក្នុងអ្នកមានគុណនោះឡើយ តែបើមិន



មាននូវគុណទេ យើងគួរសម្ដែងនូវការអាណិតឱ្យជាពិសេស ។

យសសិរី និងគុណរបស់យើង រមែងសាបសូន្យព្រោះសេចក្ដីក្រោធ ។ របស់ដែលជាសត្រូវទាំងឡាយមានពណ៌សម្បុរសៅហ្មង និងការរស់នៅជាទុក្ខជាដើមរមែងមកដល់យើង ដោយសេចក្ដីក្រោធរបស់យើង ។

ឈ្មោះថាសេចក្ដីក្រោធនេះ រមែងធ្វើនូវអ្វីដែលមិនជាប្រយោជន៍បានគ្រប់យ៉ាង ហើយថែមទាំងញ៉ាំងប្រយោជន៍ទាំងពួងឱ្យវិនាសទៀតផង វាជាសត្រូវដ៏មានកម្លាំងខ្លាំងក្លា ។

កាលមានខន្តី សត្រូវអ្វីៗក៏មិនមាន យើងក៏មិនមានទុក្ខ ។ កាលបើយើងគ្របសង្កត់បាននូវសេចក្ដីក្រោធដោយខន្តី អំពើដែលជាទាសភាពនៃសេចក្ដីក្រោធនោះ ក៏នឹងត្រូវគ្របសង្កត់បានដែរដោយប្រពៃ ។

កាលបើមានសេចក្ដីក្រោធ ដែលជាសត្រូវទម្លាយនូវគុណធម៌ គុណទាំងឡាយមានសីលជាដើមនឹងបរិបូណ៌

ដល់យើងបានយ៉ាងណា ។ កាលបើមិនមាននូវគុណធម៌មានសីលជាដើមនោះ យើងជាអ្នកច្រើនដោយឧបការៈដល់សត្វទាំងឡាយ នឹងដល់នូវសម្បត្តិដ៏ខ្ពង់ខ្ពស់សមគួរដល់ការប្តេជ្ញាបានយ៉ាងណា ។

ម្យ៉ាងទៀត បុគ្គលតាំងនៅក្នុងខន្តី រមែងសមគួរដល់ការសម្លឹងមើលធម៌ ព្រោះជាអ្នកមិនតាំងនៅក្នុងអហង្ការ មមង្ការ ។ កាលណាបើប្រាសចាកការប្រកាន់ខ្លួនហើយ ធម្មជាតិជាធម្មតា រមែងប្រាកដនូវការកើត ការវិនាស តាមបច្ច័យទាំងឡាយរបស់ខ្លួន រមែងមិនមកអំពីទីណាៗ រមែងមិនទៅក្នុងទីណាៗ ទាំងមិនតាំងនៅក្នុងទីណាៗ និងមិនមានការខ្វល់ខ្វាយអ្វីៗឡើយ ។ ព្រះនិយតពោធិសត្វ ជាបុគ្គលទៀងចំពោះពោធិញ្ញាណ ជាអ្នកមិនត្រឡប់វិញជាធម្មតា ដោយប្រការដូច្នេះ ។

<u>ពិចារណាសច្ចបារមី</u>

គប្បីពិចារណាការដល់ព្រមដោយសច្ចបារមី ដោយន័យមានជាអាទិ៍ថា ព្រោះវៀរចាកសច្ចៈហើយ សីលជា-



ដើមក៏មិនអាចមានទៅបាន ដោយមិនមានការបដិបត្តិឱ្យសមគួរតាមការប្តេជ្ញា ។

បុគ្គលមិនមាននូវសច្ចៈ ជាបុគ្គលដែលមិនអាចឱ្យជឿទុកចិត្តបាន ព្រោះពោលពាក្យដែលមិនពិត ព្រោះរួមធម៌ដ៏លាមកទាំងពួង និងព្រោះកន្លងនូវសច្ចៈ ។

បុគ្គលដែលសម្បូណ៌ដោយសច្ចៈ ជាអ្នកតាំងមាំក្នុងគុណធម៌ទាំងពួង ជាអ្នកអាចបំពេញនូវពោធិសម្ភារទាំងពួងឱ្យបរិសុទ្ធបាន ធ្វើកិច្ចក្នុងពោធិសម្ភារទាំងពួងដោយមិនខុសចំពោះសភាវធម៌ និងបានសម្រេចក្នុងការបដិបត្តិរបស់ព្រះបរមពោធិសត្វ ។

<u>ពិចារណាអធិដ្ឋានបារមី</u>

គប្បីពិចារណាគុណនៃអធិដ្ឋានបារមី ដោយន័យមានជាអាទិ៍ថា ការសមាទានដោយមាំទាំក្នុងទានជាដើម និងការអធិដ្ឋានមិនញាប់ញ័រនៃគុណទាំងនោះ ទប់ទល់ចំពោះធម៌ដែលជាបដិបក្ខទាំងឡាយ ។

ការសន្សំបារមីមានទានបារមីជាដើម ដែលមាន

សម្ពោធិញ្ញាណជានិមិត្ត បើវៀរចាកនូវបញ្ញា និងភាពខ្លាំងក្លានៃអធិដ្ឋាននេះហើយ គឺមិនអាចប្រព្រឹត្តទៅបានឡើយ ។

ពិចារណាមេត្តាបារមី

គប្បីពិចារណាគុណរបស់មេត្តា ដោយន័យមានជាអាទិ៍យ៉ាងនេះថា បុគ្គលដែលមិនមានការតាំងចិត្តសំដៅទៅរកប្រយោជន៍ឱ្យបានសម្រេចដល់សព្វសត្វ គឺមិនអាចញុំាងសត្វលោកឱ្យបាននូវសម្បត្តិក្នុងលោកនេះ និងលោកខាងមុខឡើយ ចាំបាច់និយាយថ្វីដល់ការដែលថា អាចញុំាងសត្វលោកឱ្យបាននូវនិព្វានសម្បត្តិនោះ គឺពិតជាមិនអាចទេ ។

ព្រោះដូច្នេះ គប្បីជាអ្នកមាននូវអធ្យាស្រ័យបំពេញប្រយោជន៍ដល់សព្វសត្វ ព្រមជាមួយនឹងការយល់ដឹងដ៏ពិសេសថា សត្វទាំងនេះ ជាបុញ្ញក្ខេត្តយ៉ាងក្រៃលែង ជាអណ្តូងកើតនៃកុសលដ៏យ៉ាងសំខាន់ ជាទីតាំងនៃសេចក្តីគោរពដ៏ខ្ពង់ខ្ពស់របស់យើង ព្រោះជាហេតុឱ្យសម្រេចនូវ



សេចក្តីចម្រើនក្នុងពុទ្ធគុណទាំងពួង ។

គប្បីកពូនមេត្តាទៅរកសព្វសត្វ ព្រមដោយការអធិដ្ឋាននូវករុណាយ៉ាងពិតប្រាកដ ក្នុងបំណងកម្ចាត់នូវអ្វីដែលមិនមានប្រយោជន៍ និងទុក្ខរបស់សត្វទាំងនោះ ។

ឫសគល់ដ៏មានកម្លាំងមាំទាំ រមែងកើតឡើងដល់បុគ្គល ដែលត្រេកអរក្នុងការនាំនូវប្រយោជន៍សុខចូលទៅឱ្យដល់សត្វទាំងឡាយ ដោយមេត្តាចិត្ត ដែលមិនមានព្រំដែន ។

ករុណា ជាខាងដើម ជាចរណៈ ជាគោល ជាឫសគល់ ជាប្រមុខនៃពុទ្ធការកធម៌ទាំងឡាយ ទាំងពួង ។

ពិចារណាឧបេក្ខាបារមី

គប្បីពិចារណាឧបេក្ខាបារមី ដោយន័យមានជាអាទិ៍ថា សេចក្តីវិនាសដែលសត្វទាំងឡាយធ្វើ ព្រោះមិនមានឧបេក្ខា ទើបឱ្យកើតនូវភាពពិការផ្លូវចិត្ត កាលដែលចិត្តពិការ ក៏មិនមានការសន្សំនូវបារមី មានទានបារមីជាដើម ។

កាលចិត្តនៅជាប់ជំពាក់ដោយមេត្តា បើវៀរនូវឧបេក្ខាហើយ ការសន្សំបារមីរមែងមិនមាន ។

បុគ្គលមិនមាននូវឧបេក្ខា មិនអាចនឹងបង្អោននូវបុញ្ញសម្ភារ និងប្រយោជន៍ក្នុងការទំនុកបម្រុងដែលជាផលនៃបុញ្ញសម្ភារនោះ ឱ្យប្រព្រឹត្តទៅក្នុងការសន្សំបានឡើយ ។

ព្រោះមិនមានឧបេក្ខា ទើបគេមិនអាចធ្វើការចែកទេយ្យធម៌ និងបដិគ្គាហកបាន ហើយក៏មិនអាចបរិច្ចាគបាន ។

ព្រោះប្រាសចាកឧបេក្ខា ទើបមិនមានមនសិការដល់អន្តរាយនៃបច្ច័យដែលជាគ្រឿងនាំមកនូវជីវិត និងមិនមានមនសិការដល់អន្តរាយនៃជីវិត ហើយក៏មិនអាចធ្វើសីលឱ្យបរិសុទ្ធបាន ។

សេចក្តីសម្រេចនៃការតាំងចិត្តសមាទាននូវពោធិសម្ភារទាំងពួងឱ្យបរិបូណ៌ រមែងសម្រេចដោយអានុភាពនៃឧបេក្ខាទាំងអស់ ។



⋆ ការពិចារណានូវទោស និងអានិសង្ស តាមលំដាប់នៃការមិនបរិច្ចាគ និងបរិច្ចាគជាដើម យ៉ាងនេះ គប្បីឃើញថា ជាបច្ច័យនៃបារមីទាំងឡាយមានទានបារមីជាដើម ។

## ៧-ចរណធម៌ ១៥

គប្បីជ្រាប ចរណធម៌ ១៥ និងអភិញ្ញា ៥ ព្រមដោយធម៌ជាបរិវារ ដូចតទៅនេះគឺ —

ផ្នែកសីលមាន ៤ :

១-សីលសំវរ ការសង្រួមក្នុងសីល កាយវាចារៀបរយ ។

២-ឥន្ទ្រិយសំវរ ការសង្រួមឥន្ទ្រិយ៦ មានចក្ខុន្ទ្រិយជាដើម ។

៣-ភោជនេ មត្តញ្ញុតា ការស្គាល់ប្រមាណក្នុងភោជន ។

៤-ជាគរិយានុយោគ ការភ្ញាក់ឡើង ប្រឹងប្រែងព្យាយាមមិនគិតតែពីដេកលក់នោះឡើយ ។

ក្នុងចរណៈផ្នែកសីលទាំង ៤ នេះ មានធុតង្គ ១៣ និងការប្រាថ្នាតិចជាដើមជាបរិវារ ។

ផ្នែកព្រះសទ្ធម្ម ៧ :

១.សទ្ធា ជំនឿត្រឹមត្រូវ មាន ពុទ្ធានុស្សតិ សង្ឃានុស្សតិ សីលានុស្សតិ ចាគានុស្សតិ ទេវតានុស្សតិ ការវៀរចាកបុគ្គលដែលសៅហ្មង ការសេពគប់បុគ្គលដែលបរិសុទ្ធ ហ្មត់ចត់ល្អ និងការពិចារណាធម៌ដែលនាំមកនូវសេចក្តីជ្រះថ្លា ជាបរិវារ ។

២.ហិរិ ការខ្មាសខ្ពើមបាប ។

៣.ឱត្តប្បៈ ការខ្លាចបាប ហិរិ និងឱត្តប្បៈមាន ភាពនៃចិត្តដែលបង្អោនទៅក្នុងការពិចារណាទោសនៃអកុសល ទោសទុក្ខក្នុងអបាយភូមិ ហើយពិចារណានូវគុណនៃកុសលធម៌ មានការវៀរចាកនូវបុគ្គលដែលប្រាសចាកហិរិ ឱត្តប្បៈ ជាបរិវារ ។

៤.ពាហុសច្ចៈ ការចេះដឹងច្រើន មាន ការចាស់ក្លានៃឥន្ទ្រិយ ដោយការសន្សំសទ្ធិន្ទ្រិយជាដើម ការសាកសួរ

-៧៣-

ការប្រកបព្យាយាមពីខាងដើម ការតាំងនៅក្នុងព្រះសទ្ធម្ម ការតាំងនៅក្នុងវិជ្ជាដែលប្រាសចាកទោស និងចិត្តឆ្ងាយពីកិលេស បង្អោនទៅក្នុងការស្តាប់ច្រើន ជាបរិវារ ។

៥.វីរិយៈ ឧស្សាហ៍ព្យាយាម មាន ភាពនៃចិត្តដែលបង្អោនទៅក្នុងការពិចារណា ឃើញភ័យក្នុងអបាយភូមិ ពិចារណា ឃើញផ្លូវដើររបស់ព្រះអរិយបុគ្គលទាំងឡាយ ពិចារណា ដល់ការបូជាធម៌ ពិចារណាដល់ការកម្ចាត់បង់នូវថីនមិទ្ធៈ ការវៀរចាកបុគ្គលខ្ជិលច្រអូស និងការសេពគប់បុគ្គលមានព្យាយាមត្រូវ ជាបរិវារ ។

៦.សតិ ស្មារតីភ្ញាក់រលឹក មាន ភាពនៃចិត្តដែលបង្អោនទៅក្នុងការវៀរចាកបុគ្គលខ្វះសតិសម្បជញ្ញៈ និងសេពគប់រកបុគ្គលដែលមានចិត្តតាំងមាំ ជាបរិវារ ។

៧.បញ្ញា ការចូលដល់សេចក្តីពិត មាន ការចម្រើនសតិឱ្យដល់នូវភាពបរិបូណ៌នៃឥន្ទ្រិយមានសទ្ធិន្ទ្រិយជាដើម ឆ្លាតឈ្លាសក្នុងការសាកសួរ ការវៀរចាកបុគ្គលល្ងង់ខ្លៅ ការគប់រកបុគ្គលដែលមានបញ្ញា និងការពិចារណាដល់

-៧៤-

ការប្រព្រឹត្តទៅនៃបញ្ញាដ៏ជ្រៅជ្រះ ជាបរិវារ ។

ផ្នែកឈាន ៤ :

១.បឋមជ្ឈាន គ្របសង្កត់នូវអកុសលនីវរណៈ

២.ទុតិយជ្ឈាន លះបង់នូវវិតក្កៈ និងវិចារៈ

៣.តតិយជ្ឈាន លះបង់នូវបីតិ

៤.ចតុត្ថជ្ឈាន លះបង់នូវសោមនស្ស ។

ឈានទាំង ៤ នេះ មានផ្នែកសីលទាំង ៤ ផង មានបុព្វភាគនៃភាវនាផង មានការហាត់នូវវសីឱ្យមាន ជំនាញក្នុងឈានផង ជាបរិវារ ។

⋆ចរណធម៌ទាំង ១៥ ក្តី អភិញ្ញា ៥ ក្តី ជាបច្ច័យនៃការសន្សំបារមីទាំងឡាយ មានទានបារមីជាដើម ។

**ចប់បារមីភាគទី ១**



# ខ្លឹមសារខ្លីៗ

១.គ្រប់សត្វមានជីវិត សុទ្ធតែមានចិត្តជាប្រធាន មានចិត្តជាធំ ។ មនុស្សមានវិធីអប់រំចិត្ត តែសត្វតិរច្ឆាន មិនមានឡើយ ដូច្នេះជីវិតមនុស្ស និងជីវិតសត្វតិរច្ឆាន ទើបផ្សេងគ្នា ពោលគឺមនុស្សបានប្រសើរត្រង់មានការ ចម្រើនផ្លូវចិត្ត ចម្រើនគុណធម៌ អប់រំរឿយៗ ។

២.បើមិនអាចធ្វើការងារធំឱ្យមកជាតូចក្នុងឆន្ទៈទេ គឺមិនអាចធ្វើការងារធំបានឡើយ ។

៣.គុណធម៌ ទាល់តែសាងទើបកើត ។ មនុស្ស សាងគុណធម៌ឱ្យកើតឡើងជាមុន ទើបគុណធម៌សាង មនុស្សនោះវិញតាមក្រោយ ។

៤.ទាល់តែកុំទាញទើបមិនតឹង លែងឱ្យវាទៅតាមធម្មជាតិ ។ រស់នៅជាមួយនឹងការមិនប្រកាន់ ទុក្ខក្នុងចិត្តរមែងមិនមាន ។

៥.ការងារដែលជាតួនាទីរបស់មនុស្ស មិនមែនគាំទ្របាបទេ គឺកម្ចាត់បាប ។ បាបកើតពីមនុស្សណា វារមែងទម្លាយនូវមនុស្សនោះ ដូចច្រែះកើតពីដែកណា ក៏រមែងទម្លាយនូវដែកនោះ ដូច្នោះដែរ ។

៦.យើងទៅណាមួយយប់ពីរយប់ ក៏គង់រៀបឥវ៉ាន់ដាក់ទៅដែរ ចាំបាច់និយាយថ្វី ក្នុងដំណើរចេញពីភពមួយទៅកាន់ភពមួយទៀត ដោយអត់ត្រឡប់វិញ ថាមិនចាំបាច់រៀបឥវ៉ាន់គឺបុណ្យកុសលឱ្យដល់ព្រមនោះ ។

៧.បើមិនចង់ស្លាប់ កុំផឹកថ្នាំពិស បើមិនចង់ទុក្ខកុំសន្សំបាប ។ ព្រះបរមពោធិសត្វសន្សំបារមី ញាតិញោម



ប្រុសស្រី អបអរសាទរសន្សំបុណ្យ ។

៨.វិញ្ញូជនចែកបានថា អ្វីណាដែលជាសារៈ និងអ្វីណាដែលមិនជាសារៈ ហើយជ្រើសរើសធ្វើតែក្នុងរបស់ដែលមានសារៈ ទើបបានជួបតែរបស់ដែលមានសារៈខ្លឹមសារហ្នឹងឯង ។

៩.មនុស្សដែលកើតមកក្នុងលោកនេះ កាលនិយាយដល់របស់ដែលគួរស្វែងរក របស់នោះក៏គឺសារៈនៃជីវិត ដែលជាផ្លូវនៃសេចក្ដីសុខ និងសេចក្ដីចម្រើន ។

-សារៈនៃទ្រព្យ គឺការឱ្យទាន

-សារៈនៃចំណេះដឹង គឺសង្គ្រោះអ្នកដទៃ

-សារៈនៃការសង្គ្រោះនោះ គឺប្រាប់ផ្លូវត្រូវ

-សារៈនៃរូបកាយ គឺប្រើរូបកាយសាងប្រយោជន៍

-សារៈនៃជីវិត គឺការប្រព្រឹត្តធម៌ដែលជាខ្លឹមសារសំខាន់បំផុតក្នុងជីវិត ។

១០_កាលមនុស្សយើងកើតមក ភាគច្រើន គឺច្រើនតែស្វែងរកសុខប៉ុណ្ណោះ មិនស្វែងរកសេចក្តីចម្រើនឡើយ ។ ចំពោះសុខណាដែលបានមកពីវត្ថុខាងក្រៅខ្លួន រមែងប្រឹងប្រែងអន្ទះអន្ទែង ស្វែងរកយកមក ដោយប្តូរស្លាប់ប្តូររស់ បុន្តែផ្នែកខាងការចម្រើនផ្លូវចិត្តវិញ ដែលជាសារៈសំខាន់នៃកំណើតមនុស្ស បែរជាមិនសូវចូលចិត្តឡើយ ។

១១_កើតមកជាមនុស្ស គួរអត់ធន់ហើយអត់ទ្រាំទៀត ចំពោះពាក្យសម្តីហួសប្រមាណរបស់អ្នកដទៃ ឱ្យដូចជាដំរីដែលអត់ធន់ចំពោះកូនព្រួញ ដែលគេបាញ់មករកក្នុងសមរភូមិ ។ សេចក្តីអត់ធន់ធ្វើក្រដាសត្រចៀកឱ្យស្វិតដូចស្បែកដំរី ។

១២_និយាយល្អ តែគេអ្នកស្តាប់មិនបានធ្វើល្អតាមនិយាយ ពាក្យនិយាយនោះ គឺជាសម្តីឥតផល ដូចផ្កាឈើ



ស្អាតតែអត់ក្លិនក្រអូប ។

១៣_មនុស្សដែលប្រកបដោយគុណធម៌ រមែងសាងខ្លួនឯងឱ្យមានតម្លៃឡើងជានិច្ច មិនថានៅក្នុងតំណែងណាឡើយ ។

១៤_មនុស្សយើងត្រូវរក្សាទ្រព្យសម្បត្តិ ប៉ុន្តែការចេះដឹងរក្សាមនុស្សយើង ដូច្នេះការចេះដឹងទើបប្រសើរជាងទ្រព្យសម្បត្តិ ។ ការចេះដឹងធ្វើឱ្យមនុស្សមានទឹកចិត្តធ្វើឱ្យចិត្តភ្លឺស្វាង និងជាប្រភពនៃសម្បត្តិទាំងពួងព្រមទាំងសេចក្តីសុខចម្រើន ។

១៥_មនុស្សមានបញ្ញា មិនត្រូវការសម្លាប់សត្រូវឡើយ រមែងសម្លាប់ចំពោះតែភាពជាសត្រូវរបស់គេតែប៉ុណ្ណោះ ហើយធ្វើសត្រូវឱ្យត្រឡប់មកជាមិត្ត ។ ព្រះបរមពោធិសត្វ ឃើញបច្ចាមិត្តជាអ្នកជួយឱ្យព្រះអង្គ

សម្រេចនូវបារមីដ៏ខ្ពង់ខ្ពស់ គឺបរមត្ថបារមី ដូច្នេះទើប ព្រះអង្គមានមេត្តាចំពោះសូម្បីតែបច្ចាមិត្ត ។

១៦.អនាគតនោះ យើងសាងដោយខ្លួនឯង ល្អឬ អាក្រក់ នៅត្រង់ខ្លួនរបស់យើង ។ ជីវិតជារបស់ដែល ធម្មជាតិប្រគល់ឱ្យ វាស្រេចតែយើងប្រើក្នុងផ្លូវល្អ ឬ អាក្រក់ប៉ុណ្ណោះ ។

១៧.អ្នកណាប្រមាទភ្លេចខ្លួនក៏ដោយចុះ យើងកុំ ប្រមាទ អ្នកណាដេកលក់សប្បាយក៏ដោយចុះ យើង ព្យាយាមភ្ញាក់ដឹងខ្លួនអប់រំទូន្មានចិត្ត ។ បុគ្គលឆ្លាតយល់ ដល់រឿងនេះហើយ រមែងស្ទុះលឿនទៅមុខ ដូចសេះជើង ល្អរត់ចោលសេះខ្ចកជើងដូច្នោះឯង ។

១៨.ត្រីរស់ក្នុងទឹក ព្រមហែលបញ្ច្រាសទឹកជានិច្ច មានតែត្រីងាប់ទេដែលអណ្តែតតាមបណ្តោយទឹកនោះ ។



មនុស្សត្រូវតស៊ូចំពោះឧបសគ្គ បុគ្គលដែលបណ្តោយជីវិត ទៅតាមជោគជតា ក៏ដូចត្រីស្លាប់ដូច្នោះឯង ។

១៩.នៅក្នុងសង្គម មនុស្សរមែងដល់នូវភាពជាធំ ទៅបាន គឺត្រូវឱ្យអ្នកដទៃលើកតម្កើង ប៉ុន្តែភាពជាធំខាង ផ្លូវចិត្តវិញនោះ គឺយើងត្រូវលើកដោយខ្លួនឯង ។

២០.ឧបនិស្ស័យមិនល្អ ដែលបុគ្គលសាបព្រោះ បណ្តុះឡើងខាងក្នុង ជាសត្រូវដ៏កាច នៅចាំទម្លាយ សេចក្តីចម្រើនរបស់មនុស្សជានិច្ច ដូចមេរោគដែលចូល ក្នុងខ្លួន មានតែទម្លាយសុខភាពឱ្យវិនាសដូច្នោះឯង ។

២១.ជីវិតជារបស់កណ្តាលៗ មានប្រយោជន៍ ក៏ មាន ឥតប្រយោជន៍ក៏មាន បើហ្វឹកហាត់អប់រំ រក្សាបានល្អ គឺមានប្រយោជន៍ តែបើខ្វះការហ្វឹកហាត់អប់រំ និងរក្សា មិនបានល្អទេ គឺពិតជាអត់ប្រយោជន៍ ។ ជីវិតមានខ្លឹមសារ ដូចចម្ការដាំក្រូច ជីវិតឥតប្រយោជន៍ដូចវាលដុះបន្លា ។

២២.« ការកើត » មាតាបិតាព្រមទាំងមនុស្សជុំវិញ សប្បាយរីករាយត្រេកអរ មានទាំងការរៀបចំពីធីអបអរសប្បាយរីករាយក្នុងពេលខ្លះទៀតផង តែការចាស់ ការមានរោគ ការឈឺ ការស្លាប់ និងការអ្វីៗដែលមិនល្អទាំងឡាយផ្សេងទៀត ដែលជាប់តាមមកជាមួយនឹង «ការកើត » មនុស្សត្រឡប់ទៅជាភ័យខ្លាចដ៏ក្រៃលែង ។ រឿងនេះគួរគិត ព្រះបរមពោធិសត្វឃើញទោសនៃការកើតពិតប្រាកដ ។

២៣.មនុស្សស្អាត ខ្ពើមរអើមរបស់ស្មោកគ្រោក ចំណែកមនុស្សល្អវិញ ខ្ពើមឆ្អើមអំពើបាបរបស់ខ្លួនឯង ។

២៤.ពេលប្រយុទ្ធត្រូវការមនុស្សខ្លាំងក្លា
ពេលមានបញ្ហាត្រូវការបណ្ឌិត
ពេលដែលមានទុក្ខត្រូវការធម៌ពិត
បានឃើញចិត្តមិត្តនៅពេលអន្តរាយ ។



២៥.មនុស្សជាមួយនឹងស្វា មានខួរក្បាលស្រដៀងគ្នា មនុស្សខ្លះមានខួរក្បាល តែប្រាសចាកបញ្ញា មិនចេះស្វែងរកទីពឹងឱ្យខ្លួនឯង គេហៅមនុស្សប្រភេទនេះថា មនុស្សខួរក្បាលស្វា ។

២៦.មនុស្សមិនល្អ ចេះគិតដល់មាតាបិតា និងអ្នកមាននូវឧបការគុណផ្សេងទៀត គឺនៅពេលណាដែលខ្លួនមានទុក្ខមកដល់តែប៉ុណ្ណោះ ផ្ទុយគ្នាពីមនុស្សល្អ ។ មនុស្សល្អ រមែងគិតដល់មាតាបិតានិងអ្នកមានឧបការគុណផ្សេងទៀត នៅពេលដែលមានសេចក្តីសុខ មានលាភ មានយស ហើយសប្បាយចិត្តដោយមានឱកាសបានតបគុណ ។

២៧.ឪពុកម្តាយ មានតែពាក្យថាឱ្យ... ឱ្យ... ឱ្យ... ជាមួយកូន ប៉ុន្តែមានកូនមួយជំពូក ម៉ែឪឱ្យប៉ុនណាក៏មិនចេះគ្រប់ ធ្វើខ្លួនជាមនុស្សឃ្លានរហូត កូនដូចនេះគេហៅថា កូនប្រេត ។

២៨-កើតជាមនុស្ស បើថាបង្អោនខ្លួនមកបម្រើអ្នកណាៗ ក៏ចូរធ្វើខ្លួនជាសេះឱ្យចៅហ្វាយនាយជិះគ្រប់ពេលវេលាទៅ ប៉ុន្តែបើចៅហ្វាយនាយគាត់មើលមកទុកដាក់យើងជាសេះ យើងត្រូវតែរើខ្លួនចេញជាប្រញាប់ ដើម្បីរក្សាកិត្តិយសយើងជាមនុស្សជាតិ ។

២៩-ពាក្យណែនាំល្អ អ្នកណាៗជាអ្នកឱ្យមិនសំខាន់ឡើយ ដូចជាដុំមាស សូម្បីសត្វតិរច្ឆានប្រគល់ឱ្យក៏ទទួលទៅ ព្រោះមាសគឺមាស ។

៣០-ពេលវេលាមានស្មើគ្នា ប៉ុន្តែអ្នកមានព្យាយាមភ្ញាក់ពីពេលមិនទាន់ភ្លឺ រមែងមានពេលវេលាច្រើនជាង ហើយម្យ៉ាងទៀត វាសំខាន់ត្រង់ការប្រើប្រាស់នូវពេលវេលានោះ បានប្រយោជន៍ ឬអត់ប្រយោជន៍ ប្រយោជន៍ខាងសប្បាយកាយ ឬប្រយោជន៍ខាងចម្រើនចិត្ត ។



៣១-ផ្កាយរាប់ពាន់ដួង ភ្លឺចាញ់ដួងខែ ដែលដួងខែមានតែមួយប៉ុណ្ណោះ ក៏ដូចជាមិត្តប្លមរាប់ពាន់នាក់ មិនអាចប្រៀបបាននឹងមិត្តល្អម្នាក់ ដូច្នោះដែរ ។

៣២-ភរិយានិងស្វាមី ពេលស្រឡាញ់គ្នាព្រមព្រៀងគ្នាបាន តែនៅពេលក្រោធ ត្រូវកុំក្រោធព្រមគ្នា ។

៣៣-ក្រោធដូចភ្នក់ភ្លើង ដូច្នេះកុំយកភ្លើងមកលត់ភ្លើង ត្រូវលត់ភ្លើងកំហឹងដោយទឹកមេត្តា ភ្លើងរលត់កាលណា ផ្ទះក្លាយជាវិមានកាលណោះ ដោយអំណាចមេត្តាភាវនាហ្នឹងឯង ។

៣៤-មើលសមត្ថភាពប្ដីពេលទុក្ខលំបាក
ពេលក្រ តោកយាក ឃើញចិត្តប្រពន្ធ ។

៣៥-ថ្នាំសំខាន់ពេលឈឺ ទឹកចិត្តសំខាន់ពេលក្រ ។

៣៦. ល្អព្រោះទឹកចិត្ត
ស្អាតពិតព្រោះចរិយា
ចាស់មានប្រយោជន៍ចាស់បញ្ញា
ខ្ចីមអលង្ការគឺខន្តី ។

៣៧. បុគ្គលពាលគិតថា គុណ ត្រូវសងឱ្យរួចគ្នា ដោយប្រាក់និងវត្ថុផ្សេងៗ ឯបណ្ឌិតវិញគិតថាគុណត្រូវតបស្នងដោយសប្បាយចិត្តអស់កាលជានិច្ច មិនមានថ្ងៃចប់ ។

៣៨. សាសនាក្នុងលោកនេះ មាន ២ គឺ ទេវនិយម និងកម្មនិយម ។ ទេវនិយម ប្រដៅឱ្យមនុស្សអរគុណព្រះជាម្ចាស់ តែកម្មនិយមប្រដៅឱ្យមនុស្សអរគុណមាតាបិតា និងអ្នកមានឧបការគុណដទៃទៀតទាំងអស់ ដោយកតញ្ញុតាធម៌ ។ កម្មនិយមមានបញ្ញាជាធំ ឯទេវនិយមមានជំនឿជាធំ ។



៣៩. សាស្តាក្នុងគ្រប់សាសនា ប្រដៅមនុស្សឱ្យវៀរអាក្រក់ ធ្វើល្អ តែព្រះសម្មាសម្ពុទ្ធវិសេសជាង គឺប្រដៅឱ្យមនុស្សសម្អាតចិត្តឱ្យស្អាតផូរផង់ រួចផុតចាកមន្ទិលសៅហ្មងទាំងពួង ។

៤០. ចិត្តដែលអប់រំល្អហើយ សភាវៈអាក្រក់រមែងចូលទៅមិនដល់ ដូចភ្លៀងដែលមិនអាចធ្លាក់ចុះចូលក្នុងផ្ទះដែលគេប្រក់ជិត ដូច្នោះឯង ។

៤១. មនុស្សធ្វើនូវអំពើអាក្រក់ រមែងក្តៅក្រហាយទាំងថ្ងៃទាំងយប់ ទាំងក្នុងលោកនេះ ទាំងក្នុងលោកខាងមុខ ចំណែកមនុស្សធ្វើនូវអំពើល្អរមែងផ្ទុយគ្នាអំពីនេះ ។

៤២. សូម្បីលើកផែនដីទាំងអស់ ឱ្យដល់មនុស្សអកតញ្ញូ ក៏មិនអាចធ្វើឱ្យគេដឹងគុណបានដែរ ។

៤៣-អ្នកនិយាយធម៌ ដោយមិនបានបដិបត្តិតាមធម៌ដែលខ្លួននិយាយនោះ រមែងមិនបានទទួលផលនៃធម៌នោះឡើយ ដូចអ្នកស៊ីឈ្នួលមើលគោឱ្យគេ រមែងមិនបានទទួលផលគឺទឹកដោះគោនោះឡើយ បានតែតម្លៃឈ្នួលបន្តិចបន្តួចប៉ុណ្ណោះ ។

៤៤-កាយនេះមិននៅយូរប៉ុន្មានឡើយ ។ ដុំពពុះទឹកនិងរូបកាយ មានលក្ខណៈដូចគ្នា ផ្សេងគ្នាតែពេលវេលាប៉ុណ្ណោះ ។

៤៥-ឈ្នះមនុស្សទន់ខ្សោយ ដោយការសង្គ្រោះ
ឈ្នះមនុស្សខ្ពង់ខ្ពស់ ដោយការគោរព
ឈ្នះមនុស្សស្មើគ្នាព្យាយាមថ្ងៃយប់
ឈ្នះសព្វឈ្នះគ្រប់ឈ្នះចិត្តខ្លួនឯង ។



៤៦-ជម្នះណា ដែលត្រឡប់ចាញ់វិញ ជម្នះនោះជាជម្នះធម្មតា តែជម្នះណាដែលមិនត្រឡប់ចាញ់វិញ ជម្នះនោះប្រសើរបំផុត ។

៤៧-ក្លិនក្រអូបគ្រប់យ៉ាង បញ្ច្រាសខ្យល់មិនបានឡើយ ប៉ុន្តែក្លិនសីល និងក្លិនកិត្តិយសកេរ្តិ៍ឈ្មោះរបស់មនុស្ស រមែងក្រអូបបញ្ច្រាសខ្យល់ដោយពិត ។

៤៨-មនុស្សល្ងង់ បើដឹងថាខ្លួនឯងល្ងង់ពិត នៅល្មមអាចបានទៅជាបណ្ឌិត ប៉ុន្តែបើល្ងង់ហើយសំគាល់ថាខ្លួនជាបណ្ឌិត គឺពិតជាល្ងង់រហូត ។

៤៩-មនុស្សល្ងង់នៅជិតបណ្ឌិតរហូតជីវិត ក៏មិនអាចបាននូវរសជាតិព្រះធម៌អំពីបណ្ឌិតដែរ ដូចវែកមិនដឹងរសសម្ល ។

៥០.មនុស្សឆ្លាតចូលជិតបណ្ឌិត សូម្បីតែមួយភ្លែត រមែងបានទទួលនូវធម្មរសយ៉ាងឆាប់រហ័ស ដូចអណ្តាត ដឹងរសសម្ល ។

៥១.បុគ្គលពាលល្ងង់ខ្លៅ ធ្វើខ្លួនឱ្យជាសត្រូវនឹង ខ្លួនឯង ដើរសាងបាបកម្មសព្វបែបយ៉ាង ដែលជាហេតុនាំ មកនូវសេចក្តីក្តៅក្រហាយ ។

៥២.មនុស្សអាក្រក់ ឃើញអំពើអាក្រក់ដូចទឹកឃ្មុំ ដរាបណាដែលអំពើអាក្រក់មិនទាន់ឱ្យផល លុះដល់កាល ណាអំពើអាក្រក់ឱ្យផល កាលនោះឯង មនុស្សអាក្រក់ រមែងជួបប្រសព្វនូវទុក្ខធំ ។

៥៣.អ្នកស្រែតែងបាចទឹកបញ្ចូលស្រែ ជាងឈើ តែងចាំងឈើ ជាងព្រួញតែងពត់ព្រួញ ចំណែកបណ្ឌិត រមែងទូន្មានខ្លួន ។



៥៤.ការមើលឃើញសេចក្តីល្អ ឬសេចក្តីអាក្រក់ របស់ខ្លួន ដោយខ្លួនឯង ល្អជាងដែលអ្នកដទៃគេឃើញ ។

៥៥.បើឃើញថាសេចក្តីល្អ គឺពិតជាល្អ ក៏ចូរធ្វើនូវ សេចក្តីល្អនោះឱ្យបានរឿយៗចុះ ថែមទាំងពេញចិត្តចំពោះ សេចក្តីល្អនោះផង ព្រោះការសន្សំនូវសេចក្តីល្អ ធ្វើឱ្យកើត នូវសេចក្តីសុខ ។

៥៦.មនុស្សអាក្រក់ឃើញអំពើអាក្រក់ថាល្អ រហូត ពេលវេលាដែលអំពើអាក្រក់មិនទាន់ឱ្យផល លុះដល់កាល ណាអំពើអាក្រក់ឱ្យផល ទើបឃើញអំពើអាក្រក់ថាជា សេចក្តីអាក្រក់ពិតមែន ។

៥៧.បុគ្គលមិនគួរមើលងាយសេចក្តីអាក្រក់ថា បន្តិចបន្តួចៗ ព្រោះបើធ្វើរឿយៗ ក៏នឹងក្លាយជាបុគ្គល ដែលពេញទៅដោយបាប ដូចក្អមដែលពេញទៅដោយទឹក

ដោយគ្រាន់តែទឹកស្រក់ចូល ម្តងមួយតំណក់ៗ តែប៉ុណ្ណោះ ។

៥៨.ការសាងផ្ទះ ត្រូវប្រើពេលវេលា ក្នុងការរៀបឥដ្ឋ បុគ្គលដែលបានជួបប្រសព្វនូវសេចក្តីសម្រេចក្នុងជីវិត ក៏ត្រូវប្រើពេលវេលាដូចគ្នាដែរ ។ សេចក្តីសម្រេច មិនមែនជារបស់ដែលមនុស្សអាចបានដោយងាយៗឡើយ បើប្រាសចាកនូវការតាំងចិត្តពិតៗនោះ ។

៥៩.រូបគ្រប់យ៉ាងដែលភ្នែកបានឃើញ និងសំឡេងគ្រប់បែបដែលត្រចៀកបានឮ គឺសុទ្ធតែជាអាចារ្យប្រដៅយើងទាំងអស់ ។ សេចក្តីដូចដែលពោលមកនេះ វានៅលើការធ្វើទុកក្នុងចិត្តនៃបុគ្គលនោះៗ ។

៦០.ការគិតនិងការធ្វើ ដូរផ្លាស់មនុស្សឱ្យទៅជាអ្វីក៏បាន ។ ព្រះជាម្ចាស់ មិនធ្លាប់បណ្តាលឱ្យអ្នកណាទៅជា



អ្វីនោះទេ តែការគិត និងការធ្វើរបស់ខ្លួនឯងតែប៉ុណ្ណោះដែលជាអ្នកបណ្តាល ។

៦១.បើម្សិលមិញក៏មាន ថ្ងៃនេះក៏មាន ស្អែកក៏មាននឹងបដិសេធថា ជាតិមុខមិនមាន បានយ៉ាងដូចម្តេចទៅ ព្រោះទាំងអស់នេះ វាជាតំណនៃវិញ្ញាណ និងព្រោះមានបច្ច័យ ។

៦២.ការមាននូវសេចក្តីគោរព និងការឱនលំទោនទន់ភ្លន់រាបសា នាំមកនូវសិរីមង្គលដ៏ឧត្តម ធ្វើឱ្យចៅ-ហ្វាយនាយ រមែងមានមេត្តាអនុគ្រោះ ឱ្យនូវវត្ថុនេះនោះខ្លះ និងឱ្យនូវឱវាទប្រៀនប្រដៅខ្លះ ។

៦៣.មាតាបិតាជាអ្នកមាននូវឧបការៈ ចិញ្ចឹមបីបាច់ថែរក្សា បង្ហាញលោកនេះដល់បុត្រ ។ ការធ្វើមាតាបិតាដែលមិនមានសទ្ធាឱ្យមានសទ្ធា ដែលមិនមានសីលឱ្យមាន

សីល ដែលមិនមានបញ្ញាឱ្យមានបញ្ញា ឱ្យចេះធ្វើទាន ឱ្យចេះស្តាប់ធម៌ បានឈ្មោះថា ជាការតបស្នង សងគុណមាតាបិតាដ៏យ៉ាងប្រសើរ ។

៦៤.សម្បត្តិក្នុងលោកនេះ មានពីរយ៉ាងគឺ វត្ថុសម្បត្តិ និងធម្មសម្បត្តិ តែធម្មសម្បត្តិសំខាន់ជាង ព្រោះជាសម្បត្តិរបស់ចិត្ត ធ្វើចិត្តឱ្យស្អាតផូរផង់ទៅបាន ។ ធម្មសម្បត្តិ អាស្រ័យបានទាំងក្នុងលោកនេះ ទាំងក្នុងលោកខាងមុខ ឯវត្ថុសម្បត្តិមិនមានខ្លឹមសារ ប៉ុន្តែអ្នកមានបញ្ញាអាចធ្វើវត្ថុសម្បត្តិឱ្យមានប្រយោជន៍ ទាំងក្នុងលោកនេះទាំងក្នុងលោកខាងមុខបាន ដូចគ្នាដែរ ។

៦៥.បុគ្គលដែលជាទីពឹង ធ្វើជាម្លប់ឱ្យត្រជាក់ដល់អ្នកដទៃទៅបាន ត្រូវតែជាអ្នកមានសេចក្តីអត់ធន់ចំពោះសេចក្តីលំបាកសព្វគ្រប់ប្រការ ដូចដើមឈើធំដែលនៅជាម្លប់ឱ្យមនុស្សសត្វបានជ្រក ទាំងដែលខ្លួនឯងទទួលនូវ



កម្តៅថ្ងៃយ៉ាងខ្លាំងដូច្នោះឯង ។

៦៦.ត្រីធំច្រើនតែនៅក្នុងសមុទ្រទឹកជ្រៅ បើយើងធ្វើខ្លួនជាទូកតូច នៅតែក្បែរៗមាត់ច្រាំង នឹងចាប់ត្រីធំបានយ៉ាងដូចម្តេចទៅ ។

៦៧.លាភដែលគ្រប់គ្នាប្រាថ្នា ត្រូវការដ៏ក្រៃលែងនោះ មុននឹងបានសម្រេចសឹងតែយកជីវិតទៅប្តូរ ។

៦៨.ប្រយោជន៍ធំឋិតនៅក្នុងជម្រៅធម៌បដិបត្តិ ។ បើមានត្រឹមតែសីល ៥ ប៉ុណ្ណោះ វានៅកៀក នៅក្បែរនឹងកាមគុណពេកណាស់ ត្រូវសមាទានឧបោសថ មាននូវនេក្ខម្មៈ មានការអប់រំចិត្ត និងចម្រើននូវបញ្ញា លះបង់រឿងរ៉ាវក្នុងលោកិយចូលកាន់ផ្លូវនៃជីវិតបរិសុទ្ធ មិនប្រាថ្នាភព ផុតចាកពីតណ្ហា នេះទើបជាការបានសម្រេចនូវប្រយោជន៍ធំ ។

៦៩.កិច្ចការទាំងឡាយ សម្រេចបានដោយការចុះដៃធ្វើ ព្រោះបើមិនធ្វើ ឱកាសដែលនឹងបានសម្រេចរមែងមិនមានដោយពិត ដូចជាការដើរផ្លូវ បើមិនដើរទេ ឱកាសដែលនឹងដល់ទិសដៅពិតជាមិនមាន ដូច្នោះឯង ។

៧០.សមត្ថភាពខ្លាំង ឬខ្សោយ គុណប្រយោជន៍ធំ ឬតូច ប៉ុនណាៗរបស់មនុស្ស គេមើលនៅត្រង់ផលនៃការងារ ដូចស្នាមបាទជើងរបស់សត្វ វាជាការបញ្ជាក់ប្រាប់ដល់ទំហំមាឌរបស់សត្វនោះដូច្នោះឯង ។

៧១.មនុស្សយើង មានដំណើរជីវិតទៅតាមប្រក្រតី មិនសាងសេចក្ដីក្ដៅក្រហាយឱ្យដល់ខ្លួនឯង និងអ្នកដទៃក៏រាប់បានថា ជីវិតរាល់ថ្ងៃបានធ្វើបុណ្យហើយ ។

៧២.ជីវិតក៏ដូចជាគ្រឿងយន្តដែរ តែងតែមានបញ្ហាជានិច្ច ។ ជាងគ្រឿងយន្តដែលឆ្លាត ដោះស្រាយ



បញ្ហាគ្រឿងយន្តបានដោយងាយយ៉ាងណា មនុស្សឆ្លាតក៏ដោះស្រាយបញ្ហាជីវិតបានដោយងាយដូចគ្នាដែរ ឯអ្នកល្ងង់ខ្លៅ មិនដឹងសភាពពិត រមែងមានការផ្ទុយគ្នាពីអ្នកឆ្លាត ។

៧៣.ការកើតនៃសព្វសត្វមាន ៤ ប្រភេទគឺ កើតក្នុងស៊ុត កើតក្នុងគភ៌ កើតក្នុងទឹកព្រាំ ឬទីដែលមានចំហាយស្អុយរលួយ និងកើតដោយឧបបត្តិធំស្រេចតែម្ដង ការកើតឡើងក្រៅអំពីនេះទៀតមិនមានឡើយ ។ សភាវៈជាធំក្នុងការបញ្ជូនសត្វលោកឱ្យកើតក្នុងភពនោះៗ ក៏គឺកម្មដែលសត្វនោះៗបានធ្វើហើយ ។

៧៤.ការសាងសេចក្ដីសង្ឃឹម ដើម្បីសេចក្ដីសម្រេចក្នុងជីវិតដោយការខ្ជិល គឺដូចគ្នានឹងការសាងវិមានក្នុងអាកាស ។

៧៥_ក្រមាសប្រាក់ចាយ មិនក្តៅក្រហាយ ដល់អ្នកដទៃ បើក្រទឹកចិត្ត ដូចរាំងស្ងួតដី មនុស្សសត្វឈើព្រៃ ជួបភ័យអន្តរាយ ។

៧៦_នៅក្មេងៗ ចូលចិត្តនិយាយរឿងបច្ចុប្បន្ន ដល់វ័យកំលោះក្រមុំចូលចិត្តនិយាយរឿងអនាគត ចូលដល់វ័យចាស់ចូលចិត្តនិយាយពីអតីត ឯបណ្ឌិតចូលចិត្តនិយាយអប់រំគ្រប់រឿងទាំងអស់ ។

៧៧_បក្សីនៅក្នុងទ្រុងមាសដែលមនុស្សសាងឡើងតាមពិតទ្រុងនោះធ្វើអំពីអ្វីក៏ដោយ គឺសុទ្ធតែជាទោសទាំងអស់ ព្រោះឃុំឃាំងហាមឃាត់សេរីភាព ។ មនុស្សដែលគិតថា ខ្លួនឯងឆ្លាតជាងសត្វ ប៉ុន្តែបែរជាត្រេកអរនឹងទ្រុងសម្បត្តិ ទ្រុងមាស ទ្រុងប្រាក់ ដែលខ្លួនឯងសាងឡើង ប្រព្រឹត្តទៅជាពន្ធនាការ (អាការចងរួបរឹត )ចំពោះខ្លួនឯងរហូតគ្រប់វេលា ។



៧៨_ដើមផ្កានៅក្នុងផើងធំ តែបើដើមផ្កានោះស្អុយឫសទៅហើយ ដីក្នុងផើងក៏មិនអាចផ្តល់ប្រយោជន៍អ្វីឱ្យដើមផ្កាបានដែរ ដូចមនុស្សយើងដែលមានមាតាបិតាឋិតនៅក្នុងឋានៈខ្ពង់ខ្ពស់ល្អ មានទាំងបណ្ឌិតសប្បុរសមានទាំងព្រះត្រៃបិដកគ្រប់គ្រាន់ទាំងអស់ ប៉ុន្តែបែរជាមានចិត្តខូច គឺពិតជាមិនអាចស្រូបយកនូវអ្វីៗដែលល្អ មកទំនុកបម្រុងខ្លួនបានឡើយ មិនខុសពីដើមផ្កាដែលរលួយឫសនោះឯង ។

៧៩_ការមានចរិយាមារយាទល្អ មានសីលគុណក្នុងជីវិតរស់នៅ ជីវិតពិតជាបានប្រសើរ គុណធម៌ផ្សេងៗទៀតរមែងចម្រើនជានិច្ច ដូចឫសឈើស្រូបយកជីវជាតិពីផែនដីដែលនៅជុំវិញដើម មកចិញ្ចឹមដើមមែកស្លឹកផ្លែផ្កាឱ្យលូតលាស់ដូច្នោះឯង ។

៨០_ការឈានទៅមុខ ការឈប់នៅមួយកន្លែងនិង

ការឈានថយក្រោយ អំពើទាំងនេះ រមែងឱ្យផលដល់មនុស្សយើង គឺធ្វើឱ្យស្ថិតនៅក្នុងកន្លែងផ្សេងគ្នា ។

៨១.សេចក្តីសុខទាំងឡាយ ដែលត្រូវអាស្រ័យវត្ថុខាងក្រៅ វាមិនមែនជាសេចក្តីស្ងប់ចិត្តនោះទេ ព្រោះសេចក្តីសុខដែលជាសេចក្តីស្ងប់ចិត្ត មិនត្រូវអាស្រ័យអ្នកណា១ ឬអ្វី១ ជាខាងក្រៅនោះឡើយ ។

៨២.ការមិនជំពាក់បំណុលគេ ជាសុខក្នុងលោក ដូច្នេះ បើចូលដេកដោយមិនមានអាហារល្ងាច វាប្រសើរជាងភ្ញាក់ឡើងមកជាមួយគ្នានឹងជាប់បំណុល ។ សេចក្តីនេះយ៉ាងណា បំណុលកាមក៏មានន័យយ៉ាងនោះដែរ ។

៨៣.មនុស្សល្ងង់មានទ្រព្យហើយ តែមិនប៉ិនប្រសប់ក្នុងការចាយវាយ លុះចាយអស់ទ្រព្យ កិត្តិយសក៏អស់ មិត្តក៏បាត់ ភ័យក៏មកដល់ រមែងជាទុក្ខក្តៅក្រហាយ



ដូចបក្សីជាប់អន្ទាក់ព្រាន ។

៨៤.ភ្លៀងធ្លាក់ហើយរាំង ប្រាំងហើយវស្សា នាឡិកាចេះតែដើរ ដំណើរជីវិតពិតជាមិនបង្អង់ សូម្បីមួយវិនាទី ទោះបីជួបប្រទះនូវគ្រោះកាច ឬគ្រោះជា ជីវិតត្រូវតែទៅមុខជានិច្ច ។

៨៥.ចំពោះការងារ ពេញចិត្តហើយធ្វើក៏បាន ពេញចិត្តហើយមិនធ្វើក៏បាន មិនពេញចិត្តហើយមិនធ្វើក៏បាន តែកុំឱ្យធ្វើទាំងមិនពេញចិត្ត ជាដាច់ខាត ។

៨៦.ការព្យាយាមហ្វឹកហាត់អប់រំខ្លួនឯង ការញុំាងសេចក្តីសុខស្ងប់ឱ្យដល់អ្នកដទៃ ការធ្វើចិត្តរបស់ខ្លួនឯងឱ្យសម្បូណ៌ទៅដោយគុណធម៌ និងមានការគ្រប់គ្រងដោយល្អ នេះជាបេះដូងរបស់អ្នកប្រាជ្ញ ។

៨៧.ការងារសាងមនុស្សឱ្យមានកិត្តិយស កេរ្តិ៍ឈ្មោះ ភាពមាំមួន និងសេចក្តីសុខ ប៉ុន្តែមុននឹងការងារសាងមនុស្សនោះ មនុស្សត្រូវសាងការងារជាមុនសិន ។

៨៨.យើងត្រូវជាអ្នកកំណត់ជោគជតា ឱ្យខ្លួនយើងមិនត្រូវរង់ចាំឱ្យជោគជតាមកកំណត់យើងឡើយ ។

៨៩.មោឃបុរស គឺមនុស្សដែលកើតមកហើយស្លាប់ទៅដោយមិនមានកប់សេចក្តីល្អនៅក្នុងចិត្តនៃខ្លួន ។

៩០.បុគ្គលដែលមិនមានការតស៊ូព្យាយាម បណ្តោយជីវិតមួយថ្ងៃៗ ឱ្យអស់ទៅ រស់នៅដោយគ្មានគោលដៅអ្វីសោះ នោះមិនខុសគ្នាពីសាកសពដែលដើរបានឡើយ ។

៩១.សេចក្តីសង្ឃឹម គ្រប់គ្នាតែងមានរហូតគ្រប់ពេលវេលា ប៉ុន្តែការសមតាមសេចក្តីសង្ឃឹម គ្រប់គ្នាបាន



សម្រេចម្តងៗប៉ុណ្ណោះ ។

៩២.បើមិនចង់ឱ្យខកចិត្ត ទាល់តែកុំសង្ឃឹម ។ បើមិនឱ្យមានការសង្ឃឹម ហាក់ដូចជាអត់កម្លាំងចិត្តក្នុងការងារ ដូច្នេះគ្រប់គ្នាគប្បីសិក្សាថា « អាត្មាអញ ធ្វើល្អព្រោះពេញចិត្តនឹងសេចក្តីល្អ » ។

៩៣.បើយើងធ្វើល្អ ព្រោះពេញចិត្តនឹងសេចក្តីល្អ យើងនឹងបានសេចក្តីល្អតបស្នងជានិច្ចគ្រប់ពេល ដូចព្រះពុទ្ធភាសិតថា « ធ្វើល្អ បានល្អ » ពាក្យថាបានល្អ គឺសេចក្តីល្អដែលខ្លួនធ្វើនោះឯង ។

៩៤.បើយើងធ្វើល្អដើម្បីលាភ យស សរសើរ សុខ យើងអាចនឹងខកចិត្ត ព្រោះពេលខ្លះ កាលដែលយើងធ្វើនូវសេចក្តីល្អហើយ ជំនួសដែលនឹងបានពាក្យសរសើរត្រឡប់ជាត្រូវនិន្ទា បានពាក្យបន្ទោសស្តីថា ឬជំនួសដែល

នឹងត្រូវបានសុខ ត្រឡប់ជាបានទុក្ខ ដូច្នេះជាដើម ។ កាលបើបែបនេះ យើងអាចនឹងយល់ខុសថា « ធ្វើល្អមិនបានល្អ » ហើយក៏មិនចង់ធ្វើល្អតទៅទៀត ។

៩៥-មនុស្សល្អ ធ្វើល្អព្រោះស្រឡាញ់សេចក្ដីល្អ ។ សេចក្ដីល្អជាសម្បត្តិរបស់ចិត្ត ជាខ្លឹមសារនៃជីវិត ជាទឹកលាងជម្រះនូវមន្ទិលសៅហ្មងរបស់ចិត្ត ជាសម្បត្តិដែលត្រូវសន្សំ ព្រោះនាំឱ្យសម្រេចនូវសេចក្ដីប្រាថ្នាគ្រប់យ៉ាងសមទៅតាមពេលវេលា ។

៩៦-ការសាងសេចក្ដីស្រឡាញ់ ឱ្យកើតឡើងក្នុងបេះដូង ប្រព្រឹត្តទៅក្នុងការងារ ទោះជាការងារអ្វីក៏ដោយដែលយើងត្រូវធ្វើ គឺពិតជាមានកម្លាំងខ្លាំង ឧបសគ្គធំមហិមាប៉ុនណា ក៏រារាំងការងារយើងមិនបានដែរ ។



៩៧-ឧបសគ្គ គឺជាគ្រឿងពិសោធកម្លាំងចិត្ត ដែលសេចក្ដីសម្រេចបានបញ្ជូនមក បើយើងអាចយកឈ្នះវាបាន សេចក្ដីសម្រេចក៏នឹងមកតាមក្រោយ ។

៩៨-តាមពិត សេចក្ដីសម្រេច នៅត្រង់ការឈ្នះឧបសគ្គហ្នឹងឯង ។ សេចក្ដីសម្រេចមិនមែនជារបស់ដែលត្រូវប្រគល់ឱ្យអ្នកណាៗ បានដោយងាយនោះឡើយ លុះត្រាតែបានពិសោធដឹងថា បុគ្គលនោះជាអ្នកសមគួរនឹងទទួលបាន ។

៩៩-រលកធ្វើឱ្យសមុទ្រស្អាត យ៉ាងណាឧបសគ្គក៏ធ្វើឱ្យជីវិតរុងរឿងស្រស់ល្អ ដូច្នោះដែរ បុគ្គលទើបមិនត្រូវចាញ់ជាមុនឡើយនៅពេលជួបឧបសគ្គ ។

១០០-ការច្រណែន រមែងទម្លាយលោកនេះ ឱ្យវិនាស រួមទាំងបុគ្គលអ្នកច្រណែននោះផង ។

១០១.បើយើងចង់មើលរបស់ល្អ គប្បីមើលខ្លឹមសារព្រះត្រៃបិដក ចំណែកអ្វីៗផ្សេងៗទៀត យើងមិនចាំបាច់ទាស់ចិត្តដោយគិតថា មិនល្អនោះទេ ខ្លួនយើងហ្នឹងឯង ដែលត្រូវរៀបចំឱ្យអ្វីៗបានល្អប្រសើរនោះ ។

១០២.តាមពិត វាមិនមានអ្វីដែលអាក្រក់សម្រាប់យើងទេ បើយើងមិនគិតថាអាក្រក់ទេនោះ អ្វីៗក៏យើងអាចបំពេញ ឱ្យសម្រេចបានជាបារមី ជាមួយនឹងអ្វីនោះដែរ ។ កាលបើដូច្នេះ តើយើងចង់ឱ្យរបស់អ្វីទៅជាអ្វីវិញ ទោះជាអ្វីនោះល្អប្រសើរគាប់ចិត្តយ៉ាងណា ក៏វាមិនល្អពូកែស័ក្តិសិទ្ធិដូចជាបារមីដែរ ។

១០៣.គួររកប្រយោជន៍ឱ្យបាន សូម្បីពីបុគ្គលដែលមិនមានប្រយោជន៍ ។



១០៤.អ្នកសិក្សាសាសនា គួរនាំយកចំណេះដឹងទៅប្រើ កាលដែលមានហេតុត្រូវប៉ះពាល់ដល់ចិត្តកើតឡើង ទើបអាចដឹងថា ខ្លួនបានទទួលប្រយោជន៍ពីសាសនាប៉ុនណា ឬអត់ទេ ។

១០៥.ខ្លួនយើងមិនប្រាថ្នារបស់ណា ចូរកុំធ្វើរបស់នោះជាមួយនឹងអ្នកដទៃ ចូរមានខ្លួនឯងជាឧបមា ។

១០៦.បណ្ឌិតតែម្នាក់សរសើរ ល្អជាងបុគ្គលពាលរាប់ពាន់នាក់សរសើរ ។

១០៧.អំពើដែលមិនល្អ និងមិនមានប្រយោជន៍ មនុស្សអាក្រក់ធ្វើបានដោយងាយ តែមនុស្សល្អធ្វើបានដោយកម្រ ។ អំពើដែលល្អផង មានប្រយោជន៍ផង មនុស្សល្អធ្វើបានដោយងាយ មនុស្សអាក្រក់ធ្វើបានដោយកម្រ ។

១០៨.សង្គ្រាមរវាងប្រទេស មានកម្លាំងទ្រព្យ និងកម្លាំងអាវុធសំខាន់ពិសេស តែសង្គ្រាមជីវិត មានកម្លាំងចិត្តសំខាន់ជាទីបំផុត ។

១០៩.ជីវិតដែលមិនមានប្រយោជន៍ គឺស្លាប់មុនដល់ពេលស្លាប់ ។ អ្នកប្រាជ្ញបានដាស់តឿនថា « សូមឱ្យអ្នករស់នៅរហូតក្នុងជីវិតរបស់អ្នក សូមកុំឱ្យអ្នកស្លាប់មុនដល់ថ្ងៃស្លាប់ » ។

១១០.អំណាច ប្រាក់ ធ្លាក់ទៅនៅជាមួយបុគ្គលអាក្រក់កាលណា កាលនោះវានឹងទម្លាយអ្វីៗគ្រប់យ៉ាង និងជាទីបំផុតវាក៏ទម្លាយនូវបុគ្គលអាក្រក់នោះឯង ។

១១១.អ្នកសាបព្រោះពូជ រមែងមិនបាននូវពូជនោះ តែត្រូវបាននូវផលរបស់ពូជ យ៉ាងណាមិញ អ្នកធ្វើទាន រមែងមិនបាននូវទ្រព្យដែលខ្លួនបរិច្ចាគនោះដែរ ប៉ុន្តែ



គប្បីបាននូវសេចក្ដីល្អកពូនក្នុងសន្ដាន និងទទួលបាននូវផលរបស់ទាននោះសមគួរតាមកាល ដូចជាការសម្រេចបាននូវផលរបស់ពូជដូច្នោះឯង ។

១១២.មានកូនអកតញ្ញូ ១០០ នាក់ មិនស្មើនឹងមានឈើច្រត់ ១ ឬដើមស្វាយ ១ ដើមឡើយ ។

១១៣.គប្បីឈ្នះមនុស្សនិយាយឡេះឡោះ ដោយនិយាយពាក្យពិត ឈ្នះមនុស្សអាក្រក់ដោយសេចក្ដីល្អ ។

១១៤.សេចក្ដីក្រោធជាហេតុនៃរោគផ្លូវកាយច្រើនមុខ ទាំងជាមេរោគក្នុងចិត្ត ដូច្នេះសម្លាប់សេចក្ដីក្រោធបាន រមែងនៅជាសុខ ទាំងអាចឈ្នះមនុស្សក្រោធបានដោយការមិនក្រោធទៀតផង ។

១១៥.ដែលឈ្មោះថាសេចក្ដីអាក្រក់ មិនថាបព្វជិត ឬគ្រហស្ថធ្វើឡើយ គឺវាអាក្រក់តែម្យ៉ាងហ្នឹងឯង ។

១១៦.ចិត្តជាធំ ចិត្តជាប្រធាន បើចិត្តអាក្រក់ហើយ ការនិយាយ និងការធ្វើ ក៏រមែងអាក្រក់ទៅផងដែរ ។

១១៧.សេចក្តីអាក្រក់ និងសេចក្តីល្អ ឱ្យផលមិនដូចគ្នាឡើយ សេចក្តីអាក្រក់ឱ្យផលជាទុក្ខ សេចក្តីល្អឱ្យផលជាសុខ ។

១១៨.អ្នកឃុំរកបុគ្គលដែលស្លាប់ទៅហើយ ជាមួយនឹងអ្នកឃុំព្រោះប្រាថ្នាចង់បានដួងចន្ទ និងដួងអាទិត្យ អ្នកទាំងពីរនាក់នេះ អ្នកណាល្ងង់ជាងអ្នកណា ។

១១៩.ការចងចិត្តទុកជានិច្ចថា អ្នកនេះបានជេរយើង អ្នកនោះបាននិន្ទាយើង ឯអ្នកនោះទៀតបានលួចទ្រព្យរបស់យើង ជាដើមយ៉ាងនេះ ពៀរនឹងរម្ងាប់បានយ៉ាងណា ។



១២០.ពៀររម្ងាប់បានដោយការមិនចងពៀរ គឺមិនអាចរម្ងាប់បានដោយការចងពៀរឡើយ ។

១២១.ដើរផ្លូវម្នាក់ឯង ល្អជាងរួមដំណើរជាមួយមនុស្សអាក្រក់ ព្រោះភាពជាមិត្តសម្លាញ់ រមែងមិនមានក្នុងបុគ្គលពាលទេ ។

១២២.មិនសេពគប់ មិនមែនបានន័យថាស្អប់នោះទេ ត្រូវប្រយ័ត្នបុគ្គលពាលក្លាយជាសត្រូវ ។

១២៣.មនុស្សមានបញ្ញា មានចិត្តមាំទាំ ធ្វើការងារដោយការតាំងចិត្តឱ្យសម្រេច រមែងមិនញាប់ញ័រនឹងឧបសគ្គដែលមកប៉ះខ្ទប់ ដូចភ្នំថ្មតាន់មិនរលំនឹងខ្យល់ព្យុះ ។

១២៤.អ្វីៗដែលកើតឡើង រមែងតាំងនៅនិងរលត់ទៅ យើងខ្លួនឯងក៏មិនអាចគេចផុតពីសភាពបែបនេះដែរ។

១២៥.សេចក្ដីល្អ រមែងតាមគ្រប់គ្រងរក្សាចំពោះអ្នកធ្វើល្អ ដូចឆត្រតាមបាំងការពារភ្លៀង ឬក្ដៅ ចំពោះអ្នកបាំងឆត្រ ដូច្នោះឯង ។

១២៦.មនុស្សយើងកើតមក រមែងប្រាថ្នាក្នុងរបស់ផ្សេងៗ មានទ្រព្យសម្បត្តិ មាសប្រាក់លុយកាក់កែវកងជាដើម ក្នុងបណ្ដារបស់ទាំងអស់នោះ សេចក្ដីសុខជាកំពូលនៃសេចក្ដីប្រាថ្នាទាំងពួង ។

១២៧.ក្នុងលោកនេះ មានហេតុនៃសេចក្ដីសុខច្រើនណាស់ ដូចជាការមានសទ្ធា ការមិនធ្វើបាបបៀតបៀនអ្នកដទៃ ការសន្សំបុណ្យ ការមានសីល ការសេពគប់នឹងសប្បុរស ការស្ដាប់ព្រះសទ្ធម្មជាដើម ជាពិសេសការអប់រំទូន្មានចិត្ត ។

១២៨.សត្រូវជួបសត្រូវ រមែងធ្វើនូវសេចក្ដីវិនាស



ឱ្យដល់គ្នា តែការតម្កល់ចិត្តខុស រមែងធ្វើនូវសេចក្ដីវិនាសឱ្យដល់ខ្លួនឯង ក្រៃលែងជាង ។

១២៩.ជនជាទីស្រឡាញ់ទាំងឡាយ មានមាតាបិតាជាដើម រមែងសាងសេចក្ដីល្អ ធ្វើល្អក្នុងបុគ្គលដែលខ្លួនស្រឡាញ់ ប៉ុន្តែចិត្តដែលតម្កល់ត្រូវហើយ រមែងធ្វើនូវសេចក្ដីចម្រើនឱ្យដល់ខ្លួនឯងយ៉ាងពិសេសក្រៃលែងជាង។

១៣០.កូនល្អដែលមាតាបិតាទំនុកបម្រុងហើយ រមែងចម្រើនដុះដាលដោយចំណេះដឹង ចរិយាមារយាទ ។ល។ ឱ្យដូចជាកូនឈើដែលគេស្រោចទឹកដាក់ជីដូច្នោះដែរ ។

១៣១.ធម៌សប្បុរស និងធម៌អសប្បុរស រមែងឆ្ងាយអំពីគ្នា ជាងត្រើយមហាសមុទ្រពីម្ខាងទៅម្ខាងទៀត ។

១៣២.អ្នកមានបញ្ញា សូម្បីអត់ទ្រព្យក៏រស់នៅបានល្អ ចំណែកអ្នកដែលមានទ្រព្យតែប្រាសចាកបញ្ញាវិញនោះ រមែងរស់នៅដោយលំបាក ។

១៣៣.អ្នកមានបញ្ញា មានចិត្តមាំទាំ រស់នៅមួយថ្ងៃ ប្រសើរជាងអ្នកអត់បញ្ញាមានចិត្តរាយមាយ រស់នៅសូម្បីអស់រយនៃឆ្នាំ ។

១៣៤.បុគ្គល បានអាស្រ័យនៅក្នុងម្លប់ឈើណា មិនគួរទម្លាយសូម្បីគ្រាន់តែមែកនៃដើមឈើនោះ នេះជាឱវាទដាស់តឿនមិនឱ្យទ្រុស្តមិត្ត ។

១៣៥.ការអួតខ្លួនឯង និងមើលងាយអ្នកដទៃ ជាអាការនៃមនុស្សអាក្រក់ បណ្ឌិតមិនប្រព្រឹត្តឡើយ ។

១៣៦.បើអ្នកខ្លាចទុក្ខ និងមិនពេញចិត្តចំពោះទុក្ខទេ ចូរអ្នកកុំធ្វើបាប ទាំងក្នុងទីវាល និងក្នុងទីកំបាំង ។



១៣៧.សព្វសត្វ មានការស្រឡាញ់ខ្លួនឯងដ៏ក្រៃលែង បណ្ឌិតដឹងសេចក្តីនេះហើយ រមែងមិនបៀតបៀនសត្វដទៃណាៗទាំងអស់ ។

១៣៨.អ្នកគ្រប់គ្រងផ្ទះ គប្បីសង្រួមក្នុងកាមទាំងឡាយ ត្រូវតែសន្តោសចំពោះភរិយារបស់ខ្លួន មិនត្រូវទៅជ្រមុជជ្រមុលនឹងស្រីពេស្យា និងមិនត្រូវទាក់ទងស្នេហាចំពោះភរិយារបស់អ្នកដទៃជាដាច់ខាត ព្រោះវាជាផ្លូវរបស់បិសាច ។

១៣៩.ភាជនៈដីដែលស្មូនឆ្នាំងធ្វើហើយ មានការបែកធ្លាយជាទីបំផុត យ៉ាងណាមិញ ជីវិតរបស់សត្វទាំងឡាយ ដែលជាងគឺកម្មបានសាងឡើងហើយ ក៏រមែងបែបធ្លាយយ៉ាងនោះដែរ ដូច្នេះទើបមិនគួរប្រមាទ ។

១៤០.បុគ្គលគប្បីហ្វឹកហាត់ខ្លួនឱ្យបានល្អ ព្រោះខ្លួនជាទីពឹងនៃខ្លួនឯងដ៏ពិសេសក្រៃលែង ។

១៤១.ជាតិត្រកូល មិនមែនជាគ្រឿងវាស់ថាល្អ ឬអាក្រក់ឡើយ ការធ្វើនូវកម្មផ្សេងៗទើបជាវាស់មនុស្សថាល្អ ឬអាក្រក់ពិតប្រាកដ ។

១៤២.វង្វេងផ្លូវនាំឱ្យខូចពេល និងបង់ខាតអ្វីៗបន្តិចបន្តួចទៀត មិនខូចខាតច្រើនដូចជាការវង្វេងផ្លូវនៃជីវិតឡើយ ។

១៤៣.សេចក្តីសុខជារឿងរបស់ចិត្ត មនុស្សក្រអាចមានសេចក្តីសុខដូចតែអ្នកមានដែរ បើចេះស្វែងរក ។

១៤៤.ធម្មជាតិទាំងអស់ជាកន្លែងសិក្សា បញ្ញានាំឱ្យបរិសុទ្ធពិត ជីវិតជាក្បួនតម្រា ។

១៤៥.បើមិនចាំបាច់កុំនិយាយ កាលចាំបាច់ត្រូវនិយាយ គប្បីនិយាយដោយធម៌ ។

១៤៦.កម្ចាត់បង់កិលេស ទើបជាការងារពិសេសរបស់មនុស្ស ។

១៤៧.ចែកកិលេសចេញពីខ្លួនប្រាណ ទើបក្លាហានហ៊ានសម្លាប់កិលេស ។ មនុស្សយើងកាលណាយល់ថាកិលេសជាខ្លួន ឬខ្លួនជាកិលេសហើយ ទើបមិនឃើញកិលេសដែលជិះចិត្តខ្លួនឯង ម៉្លោះហើយត្រូវកិលេសបោកប្រើរហូត ។ មនុស្សយើងយល់ថា ខ្លួនជាសត្វប្រសើរខ្ពង់ខ្ពស់ ប៉ុន្តែដែលពិតគឺជាទាសៈដ៏ស្មោះត្រង់ មានភក្តីដ៏ក្រៃលែងចំពោះកិលេស ។ កិលេសតែម្យ៉ាងប៉ុណ្ណោះដែលពូកែជាងមនុស្ស ទើបគ្របសង្កត់ចិត្តមនុស្សទុកប្រើអស់កាលជានិច្ច ។

១៤៨.ប្រសិនបើមានអំនួតក្នុងចិត្តកើតឡើង គិតថាខ្លួនឯងពូកែ នេះជាចំណុចខ្សោយមួយ មិនយូរប៉ុន្មាននឹងបានជួបការពិត គឺចំណុចអន់របស់ខ្លួន ។ នេះព្រោះ

មកអំពីចំណុចខ្លាំងពុកែក្នុងលោកមិនមានទីបំផុត ប៉ុន្តែបើយើងមិនអួតខ្លួនឯង ហើយក៏មិនមើលងាយខ្លួនឯងដែរ នោះ វាជាការសមរម្យហើយ ។

១៤៩_គេនិយាយថា

## ឱ ! បុណ្យចូលឆ្នាំថ្មីអើយ

បុណ្យចូលឆ្នាំថ្មីសិរីមង្គល តែបើឃើញយល់សង្វេគអស្ចារ្យ
ជុំគ្នាលេងបៀទទួលទេវតា ក្លែមសាច់ផឹកស្រាទទួលឆ្នាំថ្មី ។
ក្រមុំគប់ទឹកតម្រង់កំលោះ បុរសបន្លំចាប់ប៉ះស្រីៗ
គប់គេចចុះឡើងជួបនឹងគ្រោះភ័យ តើចូលឆ្នាំថ្មីសិរីត្រង់ណា ។
បុណ្យចូលឆ្នាំថ្មីដែលប្រពៃពិត ជួបជុំញាតិមិត្តមាតាបិតា
ធ្វើបុណ្យដាក់បាត្រស្តាប់ធម៌ទេសនា ចម្រើនមេត្តាដល់គ្នានឹងគ្នា ។
ព្រោះពេលរស់នៅមានតិចតួចណាស់ អាចស្លាប់ព្រាត់ប្រាសគ្រប់ពេលវេលា
ម្យ៉ាងក្មេងឥឡូវច្រើនមិនសូវជា គ្រោះថ្នាក់គ្រាំគ្រាស្លាប់ច្រើនជាងចាស់ ។
ព្រោះតែភ្លើតភ្លើនភ្លាំងភ្លាត់ស្មារតី ទាំងប្រុសទាំងស្រីពុំសូវរៀនខ្ពស់
មិនស្តាប់ម៉ែឪមិនគោរពចាស់ ពូកែខ្លាំងណាស់ខាងអនាចារ ។
អ្នកនាំរីកវរបង្កជម្លោះ អ្នកនាំរងគ្រោះដល់ជាតិសាសនា
ស្រុកភូមិរីកវរព្រោះក្មេងឫស្យា មាតាបិតាខ្លោចផ្សាព្រោះកូន ។
សូមចូលឆ្នាំខ្មែរប្រែមានរស្មី ទទួលសិរីកុំបីសាបសូន្យ
ជួបជុំសាច់ញាតិសង្គ្រោះបងប្អូន ម៉ែឪជួបកូនសប្បាយដោយធម៌ ។
ដោយអ៊ំប្រុស **គុយ សុធន**

-១១៧-

# បារមីក្រៅព្រះពុទ្ធសាសនា

ទឹកចិត្តស្នេហាកាប់ឆ្ការវណ្ណៈ ទឹកជន់ហូរចាក់ទម្លាក់ច្រាំងដី
ផ្លូវចាស់បាក់ទៅបង្កើតផ្លូវថ្មី មនុស្សនិងផែនដីអ្នកណាជាម្ចាស់។
អតីតអស់ទៅតែនៅបច្ចុប្បន្ន អនាគតមកទាន់តើសល់អ្វីខ្លះ
ចុងក្រោយគឺស្លាប់ចោលដីស្រឡះ អ្នកណាជាម្ចាស់យូរណាស់មកហើយ។
កាលដើមធ្លាប់ល្បីលើទ្វីបលោកា ដើរខុសមួយក្តារសង្គ្រាមឥតស្បើយ
ដំរីក្លាយជាស្រមោចភ្លើងហើយ ប្រឹងទៅពៅអើយក្រែងជួបដុំស្ករ។
ប្រាសាទបុណ្យអើយចាំដល់ណាទៀត ផុសមកជួយជាតិខ្ញុំសូមអង្វរ
ឱ្យខ្ញុំបានទាន់ជំនាន់មនុស្សល្អ រស់មានសីលធម៌ចេះគោរពគ្នា។
ដ្បិតរោគជរាវាមកទាន់ហើយ ក្រែងលោកពុំស្បើយពុំមានវេលា
ពុំបានរស់ទាន់ជាតិរួបរួមគ្នា មច្ចុទាមទារជារៀងរាល់ថ្ងៃ។
សូមភ្នំដងរែកដែលមានបារមី ជួយថែដែនដីដែលមានតម្លៃ
កោះកុងលយក្នុងសមុទ្រទឹកប្រៃ អ្នកកុំកាឡៃប្រពៃណីជាតិ ។
អូរជ្រៅកុំរាក់លាក់ព្រំដែនចាស់ កុំធ្វើផ្តេសផ្តាសឱ្យព្រំចាកឃ្លាត
ប៉ោយប៉ែតសូមអ្នកកុំនាំវិវាទ រក្សាធម្មជាតិព្រៃចែកដែនដី ។



ប៉ៃលិនត្បូងពេជ្រលង់លិចដល់បាត តើលោកយាយយ៉ាតកំពុងធ្វើអ្វី
សូមឱ្យដូនពេញបញ្ចេញរស្មី បំភ្លឺផ្ទៃដីដែនកម្ពុជា ។
គិរីវង់អើយកុំរត់ចោលស្រែ កេរពីឪម៉ែត្រូវតែការពារ
ស្រុករមាសហែកស្រុកកំចាយមារ រំដួល ចន្ទ្រា បារិតភិតភ័យ ។
វើនសៃ តាវែង រតនគិរី ព្រៃភ្នំជាទីជម្រកសត្វព្រៃ
មណ្ឌលគិរី អូររាំង អូរផ្លៃ ឧត្តរមានជ័យក្រចេះស្ទឹងត្រែង។
សូមមុនីឥសីដែលជាគ្រូខ្ញុំ ជួយដាស់អាគមដាស់យ័ន្តកន្សែង
ដាស់លេខអក្ខរាសីមាកំផែង អថ៌នកំហែងបាតស្ទឹងសង្កែ។
មន្តមហាទន្សាយស្រឡាយដំរី បាំងចុកបាំងវាយបាំងទាំងដួងខែ
មន្តបំបាំងកាយកួចដើមស្រង៉ៃ អញ្ជើញគ្រូស្នេហ៍លិនថោងសារិកា។
គ្រូសក់កណ្តាញ់ទាំងតូចទាំងធំ ទាំងគ្រូសំណុំទាំងគ្រូសង្ហារ
គ្រូផ្ចិតរមួល ទាំងស្នូមេបា អារក្សអ្នកតាដំឡើងរាសី ។
ពួកម្រេញគង្វាលនិងព្រាយកុមារ ក្រមួនគោបាព្រាយក្បាលប្រាំបី
ម្ចាស់ភូមិម្ចាស់ស្រុកដែលមានបារមី រួមកម្លាំងដៃនឹងឥសីមុនី ។
ប៉ែតដានសាដានសាដោះបញ្ហា ថ្លែងវិជ្ជាការសម្តែងឫទ្ធី
ចុចម្រាមជើងមួយរំជួយធរណី ចុចម្រាមជើងពីររន្ទះពេញមេឃ។
ចុចម្រាមជើងបីបែងភាគបាំងខ្លួន ចុចម្រាមជើងបួនអាកាសរហែក
ចុចម្រាមជើងប្រាំធ្លាក់ភ្លៀងពីមេឃ លើកដៃបាំងភ្នែកភ្លៀងរាំងថ្ងៃរះ។

តន្រ្តីជើងម្ខាងសត្រូវរក់រី　　តន្រ្តីជើងពីរបានជ័យជំនះ
មាត់ស្លូត្របួងសួងដៃផ្តិសំពះ　　យកជ័យជម្នះឈ្នះមារសត្រូវ ។
នេះគ្រាន់តែជាការគិតស្រមៃ　　បច្ចុប្បន្នសព្វថ្ងៃពូកែអ្វីទៅ
គ្រាន់តែរោគអេដស៍ក៏ពេទ្យអស់ផ្លូវ　រស់ចាំថ្ងៃទៅនៅទាំងអួអាប់ ។
តែទោះពូកែមានឫទ្ធិក៏ដោយ　　រឿងរ៉ាវចុងក្រោយក៏ត្រូវតែស្លាប់
កុំអាងមានឫទ្ធិបំពានលើច្បាប់　　អ្នកកើតតែងស្លាប់ជាច្បាប់ធម្មជាតិ ។
ក្រោយពេលដែលបានស្លាប់ចែកស្ថានទៅ　បុណ្យបាបនាំផ្លូវរហូតឥតឃ្លាត
អ្នកដែលសាងល្អបុណ្យតាមជាញាតិ　　សាងបាបជួជាតិធ្លាក់ទៅអបាយ ។
ខ្ញុំសូមប្រមូលកងបុណ្យកុសល　　ឧទ្ទិសជូនដល់លោកអ្នកទាំងឡាយ
សូមឱ្យអានហើយមានចិត្តរសាយ　　សប្បាយសុខស្ងប់រហូតតទៅ ។
ពេលមានកង្វល់ធុញទាល់គំនិត　　សូមឱ្យជួបមិត្តដែលដឹងរាក់ជ្រៅ
រឿងណាសៅហ្មងគិតនាំអាស្រូវ　　ឈប់គិតវាទៅអានសៀវភៅវិញ ។
សៀវភៅជាមិត្តឥតកាត់ថ្លៃបាន　　កាន់អានថ្មើរម៉ោនឥតមានម្នោម្នេញ
គំនិតខ្វះខាតសៀវភៅបំពេញ　　បញ្ចេញភោគផលផ្តល់ឱ្យបញ្ញា ។

ដោយអ៊ំប្រុស **គុយ សុធន**



## នាមពុទ្ធបរិស័ទអ្នកមានឧបការៈ
## ក្នុងការទារធម្មទាន

១- ឧបាសក សំរ៉ង វណ្ណ　　២- ឧបាសក យន្ត សួន
៣- ឧបាសក គួង លាងផេង　　៤- ឧបាសក មួង យេន
៥- លោកគ្រូ រស់ សូផាត　　៦- ឧបាសក អ៊ិត ប្រាំង
៧- នាង ជា សុណារី　　៨- នាង ឃុន សូនីម៉ា
៩- ឧបាសិកា ហួនចាន់បូដា　　១០-ឧបាសក វ៉ាន់ ខុនណា
១១- ឧបាសក គុយ សុធន　　១២-ឧបាសក ជឹង វ៉េងអ៊ាវ
១៣- ឧបាសក ជឹម ជំនិត　　១៤-ឧបាសក ហាយ ចំរើន
១៥- ឧបាសិកា ប៊ុត ម៉ាលី　　១៦-ឧបាសិកា ហាយ ច័ន្ទធរី
១៧- លោកគ្រូ ជូ ប៊ុនយូ　　១៨-លោកគ្រូ លាក់ តុង
១៩- ឧបាសក ង៉ូវ គា

≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈

## រាយនាមពុទ្ធបរិស័ទក្នុងសហគមន៍ធម្មទាន ឧបត្ថម្ភប្រាក់ផ្សព្វផ្សាយព្រះធម៌ប្រចាំឆ្នាំ

១. ឧ.ស. យូស៊ាង-ងួនលី និង ឧ.សិ. លីម-ឃីម ..... ស.រ.អ.

២. ឧ.ស. ឆាយ-អ៊ីវស៊ាង និងឧ.សិ.ហុង-គឹមសែ .... ស.រ.អ.

៣. ឧ.ស. ឆាយអ៊ីវ-ស្រេងលីម និងឧ.សិ.ហួត-ឃីម... ស.រ.អ.

៤. ឧ.ស. ហៃ-ប៊ុនណារិន និងឧ.សិ.អោង-ស៊ីថាន់ ... ស.រ.អ.

៥. ឧ.ស. ហៀប-បេ និងឧ.សិ. ឡៅ-កែវម្លិះ ........ ស.រ.អ.

៦. ក្រុមឧ.ស. ឈុំ-កុសល និងឧ.ស. អ៊ុន-ឆាយគ្រី.... ស.រ.អ.

៧. ក្រុមឧ.ស. លឹម -ស៊ាង ( ហៅ ទូច ) ........ ស.រ.អ.

៨. ឧ.ស. យន្ត-សួន ឧ.សិ. តាំង ឈុងប៊ួយ និងបុត្រ .... ភ.ព.

៩. ឧ.ស.ប៊ុន-ហេង ឧ.សិ.ជុំ-សុខុម ព្រមទាំងបុត្រ... អូស្ត្រាលី

១០. ឧ.សិ.ឱម-លក្ខណា ព្រមទាំងបុត្រធីតា ......... អូស្ត្រាលី

១១. លោក យូណូស អាស៊ីស អ្នកស្រី ហុក ណារី +បុត្រ .បារាំង

១២. ឧ.ស.ង៉ូវ ជួនណារេត ឧ.សិ.ង៉ូវ សោភ័ណ+បុត្រ.....បារាំង

១៣. ឧ.ស. ម៉ៅ វង់ និង ឧ.សិ. ឆាន់ កាន់ជួង ....... ស.រ.អ.

១៤. ឧ.ស.សយ ស៊ីផាន់ណា និងឧ.សិ.ម៉ៅ សុផល +បុត្រ ភ.ព.

១៥. ឧ.សិ. ច័ន្ទ-បុប្ផាណា ព្រមទាំងបុត្រធីតា ........... ភ.ព.



១៦. ឧ.សិ. អ៊ា នៅ ព្រមទាំងបងប្អូនកូនចៅ ........ កាណាដា

១៧. ឧ.ស. ឡុក ប៊ុនអ៊ីវ និងឧ.សិ.តាន់ ស៊ីវឡាង+បុត្រ . បារាំង

១៨. ឧ.សិ.ប៊ិតថងខាំ និង ឧ.សិ.សាន គីន + ឧ.សិ.សាន ផល្លីន.

១៩. ឧ.ស. យូ ម៉េង ................................. ក.ព.ស.

២០. ឧ.ស.ម៉ៅ-សុគន្ធ ឧ.សិ.អ៊ឹង-យ៉េកហួយ និងបុត្រ .. ភ.ព.

២១. ឧ.សិ. អ៊ឹង-យ៉េកសាង ព្រមទាំងបុត្រ ........... បារាំង

២២. ឯ.ឧ. អ៊ិត-ប្រាំង និង ជ.ទ.ញ៉ែម-សេដ្ឋា +បុត្រ .... ភ.ព.

២៣. ឯ.ឧ. ធី តាឃី និង ជ.ទ. ហេង មុនីរ័ត្ន +បុត្រ ...... ភ.ព.

២៤. ឯ.ឧ.ចែម វីឌ្យ៉ា និង ជ.ទ.សុខា ស្វ៊ូលីវណ្ណ +បុត្រ ....ភ.ព.

២៥. ឯ.ឧ.ឧកញ៉ា ប៊ុត គឹមស៊ាន និងជ.ទ.ឈួន ទូច+បុត្រ ប.ប.

២៦. ឯ.ឧ.ប៉ុល-នាង និង ជ.ទ.គ្រៀល-ស៊ីយ៉ា +បុត្រ ..... ភ.ព.

២៧. ឧ.ស. ស៊ិន សុខា និងឧ.សិ. សុខា ផល្លី និងបុត្រ ... ភ.ព.

២៨. ឧ.សិ. ស៊ីវ យក់លុយ ........................... ស.រ.អ.

២៩. ឧ.ស. អ៊ុត-ផៃវ៉ាន ឧ.សិ. ផាន ស៊ុនលី និងបុត្រ .. ស.រ.អ.

៣០. ឧ.ស. ប្លោក-ងួនថៃ ឧ.សិ.ផាន ត្រលុច និងបុត្រ . ស.រ.អ.

៣១. ឧបាសិកា អ៊ឹង ស៊ីវន ............................ ស.រ.អ.

៣២. ឧ.សិ.ហេង-ស៊ីវខេង +ម្តាយឈ្មោះ អៀង-ហ៊ុគិច ..កណ្តាល

៣៣. ឧ.ស.ឃឹម-ស៊ីមុន្នី ឧ.សិ.យូ-ប៉ូលីន និងបុត្រ ........ ភ.ព.

៣៤. ឧ.ស. ឡាយ-សុខុម ឧ.សិ. សួន-ចន្ថា និងបុត្រ .......ភ.ព.

៣៥. ឧ.ស.ង៉ឹម-ញាណ ឧ.សិ. កាំង-ប៉ូលីន និងបុត្រ ...ភ.ព.ស.
៣៦. ឧបាសិកា អ៊ំ-អ៊ន់
៣៧. ឧ.សិ. ប៉ូអាន-ស៊ីវុត្ថា ................................ ភ.ព.
៣៨. ឧ.សិ. ប៉ូ ផារ៉ាណ ...................................ភ.ព.
៣៩. ឧ.សិ. ម៉ៅ សុន្ទា ....................................ភ.ព.
៤០. ឧ.សិ. សាក់-ស៊ាងអេង ព្រមទាំងបុត្រ
៤១. ឧ.សិ. ជា-ផាត ព្រមទាំងបុត្រ
៤២. ឧ.ស. ស៊ីវ សៅរ៍ និង ឧ.សិ. ស្រៀង វូចលាង
៤៣. ឧ.ស.ស្វ ហុកឡុង ឧ.សិ.កាន់ ឈីវហា ........... ស.រ.អ.
៤៤. ឧបាសិកា គា-ស៊ីន ................................ ប.ប.
៤៥. ឧ.ស.អ៊ុក-សាម៉ាណារ៉ា ឧ.សិ.ហ៊ាប-តេង និងបុត្រ ...ភ.ព.
៤៦. ឧ.ស. ម៉ៅ-ស្រ៊ុន ឧ.សិ. ទូច-ស៊ីនហ៊ន និងបុត្រ...... ភ.ព.
៤៧. ឧ.ស.ពុធ-ប៉ោលាង ឧ.សិ. ហ៊ុន-ស៊ីវអៀង ...... កាណាដា
៤៨. Chhem Sokreth et Puth Kunthea ....... កាណាដា
៤៩. ឧ.ស. ឡោ សេងជ្រុន ឧ.សិ.ផាំង លី និងបុត្រ...... បារាំង
៥០. ឧ.ស. ម៉ែន-សឿន ឧ.សិ. អៀង ណារី និងបុត្រ .... ភ.ព.
៥១. ឧ.សិ. សយ វណ្ណា និង ស្វាមី ព្រមទាំងបុត្រ ........ ភ.ព.
៥២. ឧ.សិ.ហេង បូរីស្រីនាថ និងកូនឯមភក្តី+ភរិយា+បុត្រ ភ.ព.
៥៣. ឧ.សិ. ចំណាន ព្រមទាំងក្រុមគ្រួសារ ........ កាណាដា



៥៤. ឧ.សិ. លី វ៉ន ព្រមទាំងក្រុមគ្រួសារ ............ កាណាដា
៥៥. ឧ.ស. ហួន ច៉ាន់ ឧ.សិ. ថៃ នាថ និងបុត្រ
៥៦. លោក ស៊ា រស់ អ្នកស្រី ញ៉េប ដារ៉េត និងបុត្រ
៥៧. លោក រឿង សេដ្ឋា អ្នកស្រី នាង ជូនអេង និងបុត្រ
៥៨. លោក សែន-សុវណ្ណរិទ្ធ និងភរិយា .................. ភ.ព.
៥៩. ឧ.ស. ប៉ូច បូរី ព្រមទាំងបុត្រ
៦០. ឧ.ស. អៀង ឆាយ និងឧ.សិ. អៀ-កេសរ +បុត្រ... ស.រ.អ.
៦១. លោកតា តាន់-ឈីវហា និងលោកយាយ ស្វ-ចិន្ត្រា
៦២. ឧ.សិ. តែ-សាយជូ ព្រមទាំងកូនចៅ
៦៣. ឧ.សិ. តាន់-ជាលី និងពុទ្ធបរិស័ទខេត្តសៀមរាប ..... ស.រ.
៦៤. ឧ.សិ. ឯម សុខន ព្រមទាំងបុត្រ និងចៅ ............. ភ.ព.
៦៥. ឧ.សិ. ម៉ុល-យ៉ែម ................................. ស.រ.អ.
៦៦. ឧ.សិ. កង-ភីម
៦៧. ឧ.សិ. ម៉ក់-នាង
៦៨. ពុទ្ធបរិស័ទ ចាន់ នារីសុខ និងក្រុមគ្រួសារ ......... ស.រ.អ.
៦៩. ពុទ្ធបរិស័ទ ភឿក-កុំ
៧០. ឧ.សិ. ជុំ ឆាយ
៧១. ឧ.សិ. ស៊ីវ យក់លី .................................. ភ.ព.
៧២. ឧ.ស. ជាន យ៉ែត ឧ.សិ. សុក ចេង ព្រមទាំងបុត្រ ...ភ.ព.

៧៣. ឧ.ស. សោម រតនៈ ឧ.សិ. ស៊ិប វណ្ណា ព្រមទាំងបុត្រ ព.វ.

៧៤. ឧ.ស. ហេង សម្បូរវឌ្ឍ ឧ.សិ. ស៊ិនគន្ធា ............. ភ.ព.

៧៥. ញោមប្រុសនិងញោមស្រីរបស់សាមណេរ ជា សុភក្ត្រ.ភ.ព.

៧៦. ឧ.ស.សារឿន ឧ.សិ.លាប+ឧ.ស.ហ៊ីស៊ី ឧ.សិ.អាន ស.រ.អ.

៧៧. លោក សួន បូភា អ្នកស្រី ហួន ចាន់ផូ ព្រមទាំងបុត្រ

៧៨. លោកស្រី ហ៊ុយ សុខម៉ា និងស្វាមី ព្រមទាំងបុត្រ

៧៩. ឧបាសក តាំង ស៊ុនម៉ាប

៨០. ឧបាសិកា ចៅ សារួន

៨១. ឧបាសិកា ឱប រះ ............................. ...ស.រ.អ.

៨២. ឧ.ស.គង់ សុគន្ធ ហៅជូគឹមសែ +បុត្រីគន្ធច័ន្ទដារា....ភ.ព.

៨៣. ឧ.សិ. វណ្ណ មុនី ព្រមទាំងបុត្រ និងចៅ ............. ភ.ព.

៨៤. ឧ.សិ. លឹម ប៊ូ ព្រមទាំងបុត្រធីតា

៨៥. ឧ.សិ. ឈុន លន

៨៦. ឧ.ស. ស៊ុយ ជូ និងឧ.សិ. តាំង ទៀង

៨៧. ឧ.សិ. ព្រុំ សុភាព ................................ ភ.ព.

៨៨. ឧ.ស.ហេង គីមរិន ឧ.សិ. ហោ ចន្ធូ ព្រមទាំងបុត្រ...បារាំង

៨៩. ឧ.សិ. សុខ ភួង និង ឧ.សិ. សុខ ផៃ -២០៥-

៩០. ឧ.សិ. អ៊ួន ញ៉ ឧ.សិ. រស់ លីនណា និងបុត្រ ..... ស.រ.អ.

៩១. លោក ចក់ ឈុន និង អ្នកស្រី វណ្ណារី សុខ



៩២. ឧ.សិ. អ៊ុក លន់ និងក្រុមវេន ព្រមទាំងបុត្រ ......... ភ.ព.

៩៣. ឧ.សិ. ជា គីមហៀន ព្រមទាំងបុត្រ

៩៤. ឧបាសិកា អ៊ីវ ថា ព្រមទាំងក្មួយ និងចៅ

៩៥. ឧបាសិកា ឈុន តាំងសៀក ព្រមទាំងបុត្រ និងចៅ

៩៦. ឧ.សិ. ជា ម៉ាក់លាង

៩៧. ឧ.ស.ហ្វាន់ វ៉ាន់ហួ និងឧ.សិ.ហ្វាន់ យូលាង........ បារាំង

៩៨. ឧ.ស.លីម ងីនសួ ឧ.សិ. អ៊ឹង ឆាយហួ +បុត្រ. ... អូស្ត្រាលី

៩៩. ឧ.ស.ឡុង អ៊ាងលី ឧ.សិ. សេង ចិន្តា +បុត្រ ..... អូស្ត្រាលី

១០០. ឧ.សិ. ទិត នាង ............................... អូស្ត្រាលី

១០១. ឧ.ស. ប៉ុច វឿត ឧ.សិ.ញូង ស៊ាងម៉េង +បុត្រ .. អូស្ត្រាលី

១០២. ឧ.ស.ឌួង ឆែម ឧ.សិ.អ៊ុយ អ៊ាត និងបុត្រ ....

១០៣. ឧ.ស. ឡៀ សេង ឧ.សិ.លឹម យី និងបុត្រ .....

១០៤. ឧ.ស. សុខ សារឿន ឧ.សិ.ទូច ម៉ុម និងបុត្រ ..

១០៥. ឧ.សិ. ទូច លឹមអាំង និងឧ.សិ.ទូច សុផានី .....

១០៦. ឧ.សិ. គង់ ម៉ៃ ច្បារអំពៅ ......................... ភ.ព.

១០៧. ឧ.ស. កែវ ឆាត ឧ.សិ.កាន គីរីសុខា +កូនចៅ ..

១០៨. លោកយាយ ពិន សាត ......................... ស.រ.អ.

១០៩. លោក ចាន់ ម៉ល់ និងអ្នកស្រី ជា សុផា .......... ស.រ.អ.

១១០. ភិក្ខុ ឈម បូ (វិជ្ជាសម្បទា )..................... ស.រ.អ.

១១១. ឧ.ស.ឈឹម ហុកអ៊ាន ............................ បារាំង

១១២. ឧ.សិ.មុំ ទូច និងកូនឧ.សិ.សាមុល គឹមធន់ ........ ភ.ព.

១១៣. លោក ងួន បាន និងអ្នកស្រី លិន ដាណារី ...... ស.រ.អ.

១១៤. ឧ.សិ.រស់ សេរី និងឧ.សិ.សឿ ចន្ថា

១១៥. ឧ.សិ.លី ស៊ីវជូ ព្រមទាំងបុត្រ .................... ភ.ព.

១១៦. ឧ.សិ. ឈ គឹមស៊ីន និង ក្រុមគ្រួសារ .......... អូស្ត្រាលី

១១៧. លោក ជា ស៊ីវត្ថានា និង អ្នកស្រី យុន សូនីម៉ា .. ស.រ.អ.

១១៨. ឧ.សិ.លីប៉ូលីនស៊ីមប៉ូ ព្រមទាំងបុត្រធីតា ........ ស.រ.អ.

១១៩. ឧ.ស.ហាក់ ច័ន្ទសុផល ឧ.សិ.វ៉ាង ស៊ីណា+បុត្រ ស.រ.អ.

១២០. ឧ.សិ.ស្រង់ អៃ ................................ ស.រ.អ.

១២១. ឧ.ស.ស៊ុន ដារិន និង ឧ.សិ.ទូច ចន្ទី .......... ស.រ.អ.

១២២. ឧ.សិ.រស់ សុផល និងកូន ស៊ុន .............. ស.រ.អ.

១២៣. ឧ.សិ.ង៉ោ ស៊ូអេង ព្រមទាំងក្រុមគ្រួសារ ..... ស.រ.អ.

១២៤. ឧ.សិ.ស្រី រ័ត្ន ............................... ស.រ.អ.

១២៥. ឧ.សិ.សក់ សាន់នី និង ឧ.សិ.សក់ សាលី ..... ស.រ.អ.

១២៦. លោក សម ហ៊ន និង អ្នកស្រី ខាំ យ៉ាន ....... ស.រ.អ.

១២៧. ឧ.សិ.ថេង ម៉េងជូ ព្រមទាំងបុទ្រធីតា ........ ស.រ.អ.

១២៨. ឧ.សិ.សុផាណី ............................... ស.រ.អ.

១២៩. ឧ.សិ.សៀង ភាច ............................. ស.រ.អ.



១៣០. ឧ.សិ.ស៊ុន យួង +លោក គយ សេង និងគ្រួសារ ..........

១៣១. អ្នកស្រី គយ ហ្គេច ......................................

១៣២. អ្នកស្រី ផាន់ ណាលី និងក្រុមគ្រួសារ ....................

១៣៣. ឧ.សិ.ធុច ហួល ព្រមទាំងកូនចៅ .......................

១៣៤. ឧ.សិ.ម៉ម នាង .........................................

១៣៥. ឧ.ស.គឹម ចាន់ជា .......................................

១៣៦. ពុទ្ធបរិស័ទ វត្តសុរិយរង្សី ...................... ស.រ.អ.

១៣៧. ឧ.សិ.ស៊ុយ ជាវលី ព្រមទាំងកូនចៅ .......... កាណាដា

១៣៨. ឧ.ស.ឡាវ លាងថេង និង ឧ.សិ.ពឹង ឈីវអ៊ាន.កាណាដា

១៣៩. ឧ.សិ.គឹម មុយ ព្រមទាំងក្រុមគ្រួសារ ........... បារាំង

១៤០. ឧ.សិ.ទាវ គឹមហ៊ួន ព្រមទាំងកូនចៅ ............ បារាំង

១៤១. ឧ.សិ.ដៀប រុន ព្រមទាំងបុត្រធីតា ............. បារាំង

១៤២. ឧ.សិ.ឡោត កិណរី ព្រមទាំងក្រុមគ្រួសារ ....... បារាំង

១៤៣. ឧ.សិ.តា យូអេង ព្រមទាំងបុត្រ និងចៅ .......... ភ.ព.

១៤៤. លោក ម៉េង ហ៊ី អ្នកស្រី ម៉ាន ស៊ីសុថា និងបុត្រ ..ភ.ព.

១៤៥. ឧ.ស.ចៅ ហ្វា ឧ.សិ.ឡា គឹមសាន និងបុត្រ ... ភ.ព.

១៤៦. ឧ.ស.ជិន ដេត និង ភរិយា ព្រមទាំងបុត្រ ..... ភ.ព.

១៤៧. ឧ.សិ.វៀន គង់+ស្វាមី និង ឧ.សិ.អ៊ុច សានី+ស្វាមី ភ.ព.

១៤៨. ក្រុមឧ.ស.អ៊ុច សុខុន វេនប្រចាំខែវត្តសុវណ្ណបទុម. ភ.ព.

១៤៩. ក្រុមឧ.ស. មូង .យេន វត្តសំពៅមាស ......... ភ.ព.

១៥០. ក្រុមឧ.ស. ផាន់. សារី វត្តទួលទំពូង ............... ភ.ព.

១៥១. ក្រុមវេនចង្ហាន់ ១កើតសំពៅមាស ៦កើតចំបក់មានជ័យ
១១កើតសុវណ្ណបទុម ១រោចធុតង្គ ៦រោចនិគ្រោធវ័ន
១០រោចវេឡុវ័ន .................................. ភ.ព.

១៥២. មណ្ឌលសិក្សាព្រះពុទ្ធសាសនាមណីរត្ន ខេត្តពោធិ៍សាត់ ..

១៥៣. ក្រុមពុទ្ធបរិស័ទនៅទីក្រុងស៊ីតនី ប្រទេសអូស្ត្រាលី .......

១៥៤. ក្រុមពុទ្ធបរិស័ទស្រុកមង្គលបូរី+សិរីសោភ័ណ ... ប.ម.ជ.

១៥៥. ក្រុមពុទ្ធបរិស័ទចិត្តបុណ្យក្នុងសហគមន៍ធម្មទាន

≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈



# I

## ស្ថានីយវិទ្យុ ផ្សព្វផ្សាយព្រះធម៌ព្រះពុទ្ធសាសនា ដោយសហគមន៍ធម្មទាន នៃពុទ្ធបរិស័ទ

| ខេត្ត-ក្រុង | វេលាផ្សាយ | ស្ថានីយវិទ្យុ |
|---|---|---|
| រាជធានីភ្នំពេញ | -04h45 mn<br>-05h00 mn<br>-12h15 mn<br>-18h00 mn<br>-19h00 mn<br>-20h00 mn<br>-20h30 mn | -FM 98 MHz<br>-FM 99 MHz<br>-FM 96 MHz<br>-FM 95 MHz<br>-AM 918 KHz<br>-FM 98 MHz<br>-FM 96 MHz |
| ក្រុងព្រះសីហនុ | -05h30 mn<br>-06h00 mn<br>-13h00 mn<br>-20h00 mn | -FM100.5MHz<br>-FM 92 MHz<br>-FM 92 MHz<br>-FM100.5MHz |
| ខេត្តបាត់ដំបង | -05h30 mn<br>-06h00 mn<br>-18h00 mn<br>-18h30 mn<br>-19h30 mn | -FM103.2MHz<br>-FM 96 MHz<br>-FM 91 MHz<br>-FM 96 MHz<br>-FM103.2MHz |

**សុខោ បុញ្ញស្ស ឧច្ចយោ**

ការសន្សំបុណ្យ នាំមកនូវសេចក្តីសុខ

# II

## ស្ថានីយវិទ្យុ ផ្សព្វផ្សាយព្រះធម៌ព្រះពុទ្ធសាសនា
## ដោយសហគមន៍ធម្មទាន នៃពុទ្ធបរិស័ទ

| ខេត្ត-ក្រុង | ពេលាផ្សាយ | ស្ថានីយវិទ្យុ |
|---|---|---|
| ក្រុងប៉ៃលិន | -18h00 mn | -FM 90.5 MHz |
| ខេត្តសៀមរាប | -05h00 mn<br>-18h30 mn | -FM 98 MHz<br>-FM 100.5 MHz |
| ខេត្តពោធិ៍សាត់ | -06h00 mn | -FM 98.5 MHz |
| ខេត្តកំពត | -05h00 mn<br>-18h30 mn | -FM 93.25 MHz<br>-FM 103.5 MHz |
| ខេត្តកំពង់ចាម | -05h30 mn | -FM 100.5 MHz |
| ខេត្តព្រះវិហារ | -18h30 mn | -FM 99 MHz |
| ខេត្តបន្ទាយមានជ័យ | -05h20 mn<br>-17h30 mn | -FM 96.5 MHz |
| ខេត្តស្វាយរៀង | -05h30 mn | -FM103.75MHz |

**សុខា សទ្ធម្មទេសនា**

ការសម្តែងនូវព្រះសទ្ធម្ម នាំមកនូវសេចក្តីសុខ



## សៀវភៅដែលរៀបរៀងដោយ

### ✍ ខ្ញុំព្រះករុណា ខ្ញុំបាទ ប៊ុត-សាវង្ស ✍

១. ពន្លឺធម៌ព្រះពុទ្ធ
២. ជំនួយសតិភាគ ១ ដល់ភាគ ១០
៣. មនុស្សជាមួយនឹងការងារ
៤. សិក្ខាបទមនុស្សល្អ
៥. ពរ ៤ ប្រការ
៦. ព្រះពុទ្ធភាសិត ៤៣ គាថា
៧. ខ្លឹមសារគួរយល់ដឹង
៨. ព្រះពុទ្ធសាសនា
៩. កូនមាសឪពុក
១០. ម៉ែ !!!
១១. វិធីរម្ងាប់សេចក្តីក្រោធ
១២. សុខចិត្ត និងគុណភាពនៃជីវិត
១៣. មេរៀនជីវិត
១៤. ពាក្យពេចន៍ម៉ែឪ
១៥. បទពិចារណា

## ពាក្យឆ្លងឆ្លើយ

សៀវភៅ « ពន្លឺធម៌ព្រះពុទ្ធ » នេះ ខ្ញុំព្រះករុណាខ្ញុំបាទចាប់ផ្តើមសរសេរនៅប្រទេសអាមេរិក បន្តសរសេរនៅប្រទេសកាណាដា រហូតមកបញ្ចប់នៅប្រទេសខ្មែរ ក្នុង ព.ស.២៥៤៩ ។

មនុស្សយើង ប្រកបឡើងបានជាជីវិត ដោយសារមានចំណែកសំខាន់ ២ ផ្នែក គឺ កាយ និងចិត្ត ឋិតនៅជាបច្ច័យដល់គ្នាទៅវិញទៅមក ។ យើងបានឱ្យសេចក្តីសំខាន់ និងអស់ពេលវេលាជាមួយនឹងការទំនុកបម្រុងជីវិត ទៅលើរូបកាយយ៉ាងច្រើន ប៉ុន្តែខ្វះការយកចិត្តទុកដាក់ចំពោះជីវិតផ្នែកខាងចិត្ត ដែលចិត្តនេះអាចឱ្យសុខ ឱ្យទុក្ខដល់យើងយ៉ាងខ្លាំងក្លា ។

ព្រោះហេតុដូច្នេះ ជីវិតដែលជាចំណែកខាងក្នុងទើបខ្វះនូវភាពស្រស់បស់ ពោលគឺសភាពនៃចិត្តពេញទៅ



ដោយភាពក្រវល់ក្រវាយ ក្តៅក្រហាយ និងតក់ស្លុត ព្រមទាំងសោកសៅ សូម្បីមានទ្រព្យសម្បត្តិច្រើនយ៉ាងណាក៏ដោយ។

ដំណើរជីវិតពិតជាងងឹតព្រោះអវិជ្ជា ។ មនុស្សយើងស្វែងរកសេចក្តីសុខ ដោយមិនស្គាល់ទុក្ខពិតប្រាកដម្ល៉ោះហើយ វាបែរទៅជាគាំទ្រនូវទុក្ខ ដោយការសាងហេតុនៃទុក្ខក្នុងការស្វែងរកនូវសេចក្តីសុខនោះៗ ។

ដូច្នេះ ក្នុងដំណើរជីវិតដែលឆ្លងកាត់នូវភាពងងឹតគួរអ្នកដំណើរកាន់នូវប្រទីបគឺធម៌ព្រះពុទ្ធ ដើម្បីបំភ្លឺផ្លូវកុំឱ្យវង្វេង ។

ពន្លឺធម៌ព្រះពុទ្ធ ធ្វើឱ្យចិត្តភ្លឺស្វាង កាន់យកនូវប្រយោជន៍ពិត និងធ្វើឱ្យជីវិតមានខ្លឹមសារ ។

**ដោយបំណងល្អដ៏ក្រៃលែង**

**ប៊ុត សាវង្ស**

*ថ្ងៃ១៥កើត ខែមិគសិរ ព.ស.២៥៤៩*

## សារបណ្ណា

ឈ្មោះអត្ថបទ ទំព័រ


១.សិរីជាទ្រព្យដ៏ប្រសើរ............................. ១
២.ចំណុចខ្វះខាតនៃជីវិត ........................... ៥
៣.ការព្រមព្រៀងគ្នា ................................. ៩
៤.ត្រួតត្រាមើលខ្លួនឯង ............................ ១៤
៥.ឈ្នះនិងសុខ ................................... ១៨
៦.ឈ្នះនិងសុខ (ត) .............................. ២៣
៧.វាសនាបារមី .................................... ២៨
៨.មុទិតាចិត្ត ....................................... ៣២
៩.លក្ខណៈមនុស្សពូកែ ........................... ៣៦
១០.សុខនិងទុក្ខនៅក្នុងចិត្ត .......................... ៤០
១១.សុខនិងទុក្ខនៅក្នុងចិត្ត (ត) ................... ៤៤





១២.សទ្ធា .......................................... ៤៨
១៣.សីល ........................................... ៥២
១៤.សុតៈ ........................................... ៥៦
១៥.ចាគៈ ........................................... ៦០
១៦.បញ្ញា ........................................... ៦៤
១៧.សាងមនុស្ស .................................... ៦៨
១៨.បញ្ជាក់អត្ថន័យក្នុងពាក្យផ្សេងៗ ............... ៧៣
១៩.អនត្តានិងកម្ម .................................. ៧៨
២០.អនត្តាទំនាស់ជាមួយកម្មឬទេ .................. ៨២
២១.គុណសម្បត្តិនៃពុទ្ធបរិស័ទល្អ .................. ៨៦
២២.ទ្រទ្រង់ព្រះពុទ្ធសាសនា ........................ ៩០
២៣.បណ្តុះពូជមេត្តា ................................ ៩៣
២៤.ទន់ភ្លន់ ......................................... ៩៥
២៥.សម្បត្តិពិត ..................................... ៩៧
២៦.សម្បត្តិស្តេចចក្រពត្តិ .......................... ១០០
២៧.មរតករបស់ម៉ែឪ ............................... ១០៤

២៨. មេមាន់និងកូនមាន់ ........................... ១០៧

២៩. ស្រណោះមេអក .............................. ១១០

៣០. ប្រើសជាមួយគុម្ពព្រៃ ......................... ១១៤

៣១. ព្រះតេជ-ព្រះគុណ ........................... ១១៧

៣២. ឈប់ ......................................... ១២០

៣៣. រូបស្អាតក្លិនក្រអូប ........................... ១២២

៣៤. រាជសីហ៍មិនបរិភោគសាច់ស្អុយ .............. ១២៥

៣៥. បង្កួយបានមាស ............................. ១២៦